ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jun-2015, 10:56
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី២៩៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង
កញ្ញា រ៉ូប៊ីន្នី ក្រូហ្វត៍ *(Ms. Robynne CROFT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វីល្លៀម ស្មីត *(Mr. William SMITH)*
កញ្ញា សុង ឆវ័ន្ត
លោក សេង លាង
លោក ស្រ៊ា រតនៈ
លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ
លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD*

លោក ឡេ ផុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក សេង លាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក លីវ សុវណ្ណា | ខ្មែរ |
| លោក កែវ លឿ (2-TCW-932) | ខ្មែរ |
| លោក យាន លន់ (2-TCW-830) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក កែវ លឿ** (2-TCW-932)

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ........................................ទំព័រ ៣
សួរដោយកញ្ញា អង់តា ហ្គិសសេ ផ្តើមពី........................................ទំព័រ ៦
សួរដោយលោក គង់ សំអុន ផ្តើមពី ........................................ទំព័រ ២០

**ការសួរសំណួរទៅសាក្សី៖ លោក យាន លន់** (2-TCW-830)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ទំព័រ ២៣
សួរដោយលោក សេង លាង ផ្តើមពី ........................................ទំព័រ ២៧
សួរដោយលោក ឌេល លីសាក់ ផ្តើមពី ........................................ទំព័រ ៤១
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........................................ទំព័រ ៥១
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី........................................ទំព័រ ៥៩
សួរដោយលោក លីវ សុវណ្ណា ផ្តើមពី........................................ទំព័រ ៦៥
សួរដោយកញ្ញា អង់តា ហ្គិសសេ ផ្តើមពី........................................ទំព័រ ៦៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី កែវ លឿ បញ្ចប់ ហើយនិងចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-830 សម្រាប់អង្គហេតុការដ្ឋានទំនប់១មករា។

ក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក កែវ លឿ។ លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការ។ នៅថ្ងៃនេះមានសាក្សីបម្រុងចំនួនមួយរូប ដែលមានរហស្សនាម 2-TCW-830។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិពន្ធ ឬញាតិលោហិតជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីបានធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែករួចហើយកាលពីម្សិលមិញនេះ។ សាក្សីមានមេធាវីប្រឹក្សាគឺលោក មឿង សុវណ្ណ។ សូមអរគុណលោកប្រធាន។

[០៩:០៤:០៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ បានកត់សម្គាល់ ស្ថានភាពសុខភាពរបស់លោក នួន ជា ថាមានអាការៈឈឺចង្កេះខ្លាំង និងវិលមុខពេលអង្គុយយូរ និងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់សវនាការពេញមួយថ្ងៃនេះ។

បង្គាប់បុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៥:៣៩]

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីនេះ បន្តបញ្ចប់ ហើយអង្គជំនុំជម្រះ សូមជម្រាបរំឭកថា មេធាវីការទាំងពីរក្រុមនៅសល់ពេលវេលាមួយវគ្គនៃសវនាការព្រឹកនេះក្នុងការសួរសាក្សីរូបនេះ។

សូមអញ្ជើញក្រុមមេធាវីការពារក្តី!

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ សូមជម្រាបសួរលោកសាក្សី។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំមានសំណួរបន្ថែមបន្តិចទៀត ពាក់ព័ន្ធនឹងសក្ខីកម្មរបស់លោកកាលពីម្សិលមិញ និងកាលពីថ្ងៃសុក្រ។ កាលពីថ្ងៃសុក្រ និងកាលពីម្សិលមិញ លោកបាននិយាយយ៉ាងច្រើនអំពីមូលដ្ឋានដែលលោកបោះទីតាំងនៅក្រោយឆ្នាំ៧៥ គឺនៅឃ្មួញកប់ស្រូវ តែខ្ញុំគិត ជឿជាក់ថានៅខាងជើងពោធិ៍ចិនតុង។ តើលោកអាចរៀបរាប់អំពីការកងពលរបស់លោកដែលត្រូវបានប្តូរទៅអន្លង់ក្ងានដែរឬទេ?

[០៩:០៧:០៩]

**លោក កែ លឿ៖**

**ឆ៖** ខ្ញុំបាទសូមឆ្លើយជូនអង្គតុលាការ ការផ្លាស់ប្តូរទៅអន្លង់ក្ងាននេះ ក្រោយពេលដែលគេចាប់មេៗធំៗអស់ ហើយគេឲ្យទៅលត់ដំនៅអន្លង់ក្ងាន។ បាទ សូមអង្គតុលាការមេត្តាជ្រាប។

**ស៖** តើមុនពេលដែលមេបញ្ជាការចាប់ខ្លួនហ្នឹង តើកងពល៣១០ហ្នឹង មានអ្វីពាក់ព័ន្ធនៅអន្លង់ក្ងានដែរឬទេ? ខ្ញុំចង់និយាយមុនពេលចាប់ខ្លួនមេបញ្ជាការនោះ។

**ឆ៖** ខ្ញុំបាទសូមជម្រាបអង្គតុលាការ នៅមុនពេលចាប់ខ្លួនមេៗ ខ្ញុំបាទពុំបានដឹងទេ ទាន។

**ស៖** កាលពីម្សិលមិញ លោកបាននិយាយអំពីការប្រជុំ ដែលក្នុងការប្រជុំហ្នឹង គឺគេពិភាក្សាអំពីការបះបោរនៅកន្លែងមួយជិតវត្តភ្នំ។ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ទេ ថាតើទីកន្លែងហ្នឹងជាទីកន្លែងណាបញ្ជាក់ឲ្យច្បាស់លាស់ តើលោកចាំថា ឈ្មោះផ្លូវឈ្មោះអីអ្វីទេ? តើវាទីតាំងហ្នឹង វាមានចម្ងាយប៉ុន្មានម៉ែត្រ ប៉ុន្មានគីឡូម៉ែត្រពីវត្តភ្នំដែរ លោកអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចបានទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ នៅកន្លែងនោះ ខ្ញុំបាទពុំបានស្គាល់ទេ គ្រាន់តែដឹងថានៅជិតវត្តភ្នំ ខាងជើងវត្តភ្នំ។

**ស៖** តើលោកដឹងទេថា តាគឹម មានផ្ទះនៅជិតវត្តភ្នំ គឺគាត់នៅក្បែរវត្តភ្នំ គឺនៅខាងកើតវត្តភ្នំ តើលោកដឹងទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ ផ្ទះគាត់នៅជិតវត្តភ្នំ។

[០៩:១០:០៦]

**ស៖** តើលោកដឹងទេថា គាត់មានការប្រជុំជាមួយមេបញ្ជាការជាន់ខ្ពស់នៅក្នុងផ្ទះរបស់គាត់ នៅក្បែរវត្តភ្នំហ្នឹង គឺជាមួយមេបញ្ជាការដែលត្រូវបានគេចាប់ខ្លួននោះ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ សំណួរនេះខ្ញុំបាទមិនទាន់យល់ទេ សូមបញ្ជាក់ម្តងទៀត។

**ស៖** តើលោកដឹងដែរ ឬទេថា តាគីម មានប្រជុំជាមួយ អឿន ហើយនិងមេបញ្ជាការដទៃទៀត ដើម្បីពិភាក្សាអំពីការប៉ះបោរ។ តើលោកដឹងទេអំពីចំណុចនេះ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ ចំណុចនេះខ្ញុំបាទពុំបានដឹងទេ។

**ស៖** កាលពីម្សិលមិញ លោកនិយាយអំពីការបែងចែកអាវុធពីកងពល៣១០ ដើម្បីប្រើប្រាស់ -- គេប្រើប្រាស់អាវុធទាំងអស់ហ្នឹងដើម្បីធ្វើរដ្ឋប្រហារ ឬក៏ដើម្បីបះបោរ ហើយគេប្រាប់លោកឲ្យគិតតែខ្លួនឯង កុំចេះរឿងគេ។ តើលោកមានបានដឹងអំពីការបែងចែកស្រូវ ការស្តុកស្រូវទុកដើម្បីប្រើប្រាស់ស្រូវអង្ករ ផ្គត់ផ្គង់ទាហាននៅពេលដែលបះបោរ តើលោកដឹងអំពីចំណុចនេះទេ?

**ឆ៖** ខ្ញុំបាទពុំបានដឹងអំពីការស្តុកស្បៀងនោះទេ គ្រាន់តែដឹងថា ឃើញគេដឹកអាវុធ ហើយសួរគេ គេថា "កុំចេះ" តែប៉ុណ្ណោះ បាទ។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ តើលោកធ្លាប់ឮអំពីការស្តុកស្បៀងជាងមួយពាន់តោន នៅអន្លង់ក្ងានដែរឬទេ? គឺគេស្តុកស្បៀងដើម្បីផ្គត់ផ្គង់កងទ័ពដែលចូលរួមក្នុងការបះបោរ តើលោកធ្លាប់ឮទេ គឺជាងមួយពាន់ថាំង ការស្តុកស្បៀងជាងមួយពាន់ថាំងនៅអន្លង់ក្ងាន នោះ?

**ឆ៖** ការស្តុកស្បៀងជាងមួយពាន់ថាំងនោះ ខ្ញុំបាទពុំបានដឹងទេ។

[០៩:១៣:១៦]

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនលោក វ៉ិចទ័រ កូប៉េ!

សូមអញ្ជើញលោក ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ លោកអាចពន្យល់តុលាការបានដែរឬទេ តើមូលដ្ឋាននៃការចោទសំណួររបស់លោកនេះ គឺនៅត្រង់ណាដែរ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថា នេះគឺជាអ្វីដែលគាត់អាចធ្លាប់ឮ ព្រោះថានៅពេលដែល អឿន បានផ្តល់សក្ខីកម្មនៅពេលក្រោយមកទៀតនោះ គឺថាក្នុងពេលជាមួយគ្នាហ្នឹង គឺថាគាត់បានឃើញគេដឹកកាំភ្លើង គឺជាចម្លើយ

សារភាពកន្លងមក។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ លោកមេធាវី កូប៉េ សូមឲ្យហ្មត់ចត់បន្តិច លោកមានឯកសារយោងអីទេ សូមឲ្យមានការគួរសមបន្តិច។

**លោក វិចទ័រ កូប៉េ៖**

អត់មានទេ លោកចៅក្រម។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

អ៊ីចឹងបានន័យថា សំណួរទាំងអស់ហ្នឹង គឺចេញមកពីការប្រឌិតរបស់លោកផ្ទាល់តែម្តង ឬក៏យ៉ាងណា?

**លោក វិចទ័រ កូប៉េ៖**

ការស្រមើស្រមៃរបស់ខ្ញុំ វាធំទូលំទូលាយណាស់លោកចៅក្រម។

[០៩:១៤:៥៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ បញ្ហាគឺនៅក្នុងតុលាការ ការស្រមើស្រមៃហ្នឹង មិនមានន័យទេ យើងនិយាយអំពីអង្គហេតុ ហើយយើងត្រូវផ្អែកទៅលើឯកសារ ឬក៏ទៅលើភស្តុតាង។

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំសួរៗសាក្សីអំពីអ្វីដែលគាត់ធ្លាប់ឮ ធ្លាប់ដឹង ខ្ញុំមិនមានផ្អែកទៅលើអ្វីទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

តើលោកច្បាស់ដែរឬទេថាលោកពិតជាមិនបានអានឯកសារសារភាព នៅមន្ទីរ ស-២១ ដែលជាអ្វីដែលនាំឲ្យលោកចោទសំណួរយ៉ាងដូច្នេះនោះ?

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំអានចម្លើយសារភាពជាច្រើន មិនមែនតែមួយនោះទេ ហើយនិងភស្តុតាងទៃទៀតនៅក្នុងសំណុំរឿង។ ដូច្នេះ ខ្ញុំមិនបង្ហាញឯកសារណាមួយជូនដល់សាក្សីទេ ខ្ញុំគ្រាន់តែសួរសាក្សី បើគាត់ដឹងគាត់ឆ្លើយដឹង បើគាត់មិនដឹងគាត់ឆ្លើយថាមិនដឹង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បើសិនជាលោកមិនអាចជម្រាបជូនតុលាការ ថាតើលោកមានឯកសារយោង ឬឯកសារជាមូលដ្ឋានណានោះទេ លោកត្រូវតែបន្តទៅចូលប្រធានបទថ្មីផ្សេងទៀត។

**លោក វ៉ិចទ័រ កូប៉េ៖**

វាមិនប៉ះពាល់ដល់ពេលវេលាដែលបែងចែកឲ្យខ្ញុំនោះទេ ខ្ញុំចប់ហើយ។ សូមអរគុណលោកសាក្សី។

[០៩:១៦:៤១]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានៗ អនុញ្ញាតឲ្យខ្ញុំចោទសំណួរទេ?

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ខ្ញុំសូមចាប់សំណួរបន្ថែមទៅលោកមួយចំនួន។ ខ្ញុំនឹងសួរសំណួរជាក់លាក់ អ៊ីចឹង សូមលោកស្តាប់ដោយប្រុងប្រយ័ត្ន ប្រសិនជាលោកចង់ឲ្យខ្ញុំបំភ្លឺ សូមកុំអល់អែក ហើយខ្ញុំសូមឲ្យលោកឆ្លើយឲ្យបានច្បាស់លាស់ផងដែរ។ លោកបាននិយាយថា លោកស្ថិតនៅក្នុងកងពល៣១០ លោកក៏បាននិយាយអំពីកងអនុសេនាតូច៣១៧។ អ៊ីចឹងខ្ញុំចង់សួរលោកថា មុនឆ្នាំ១៩៧៥ តើលោកស្ថិតនៅក្នុងកងវរសេនាធំណាដែរ?

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបាទ សូមការបញ្ជាក់សាឡើងវិញទាន។

**ស៖** លោកបាននិយាយថា លោកស្ថិតនៅក្នុងកងពល៣១០ ហើយលោកបាននិយាយអំពីកងវរសេនាតូច៣១៧។ អ៊ីចឹងខ្ញុំចង់ដឹងថា តើឈ្មោះកងវរសេនាធំរបស់លោកហ្នឹងអ្វីដែរ មានឈ្មោះអ្វីដែរកងវរសេនាធំរបស់លោក?

**ឆ៖** ខ្ញុំបានសូមជម្រាបជូនអង្គសវនាការ អង្គភាព៣១៧ ផ្លាស់ទៅជា៧២៨ នៅក្នុងវរសេនាធំ៧៥។

**ស៖** តើលោកចាំថានៅក្នុងកងពល លេខ ៣១០ តើមានកងវរៈសេនាធំប៉ុន្មានដែរ ក្រៅពីកងវរៈសេនាធំលេខ ៧៥ នេះ?

**ឆ៖** ខ្ញុំបាននៅចាំបានថា ចំណុះកងពលគឺមានបីវរសេនាធំ តែវរសេនាធំដទៃ ខ្ញុំបាទពុំបានស្គាល់ -- ចាំបានទេទាន។

**ស៖** តែយ៉ាងហោចណាស់ នៅក្នុងចម្លើយរបស់លោកហ្នឹងលោកនិយាយថា មានកងវរសេនាធំចំនួនបួន ដែលចំណុះឲ្យកងពល៣១០ នេះ។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ បើតាមចម្លើយលោក?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ ខ្ញុំបាទភ្លេចភ្លាំងអស់ហើយទាន វាយូរឆ្នាំពេក។

**ស៖** ខ្ញុំដឹងហើយ។ ពេលនេះខ្ញុំនិយាយផ្ទៀបទៅនឹងអ្វីដែលលោកបាននិយាយនោះទេ លោកនិយាយថា លោកស្ថិតនៅក្នុងកងវរសេនាធំ៧៥ ទោះបីជាលោកមិនចាំអំពីកងវរសេនាធំទាំងបី ផ្សេងទៀតនោះក៏ដោយ តើខ្ញុំអាចសន្និដ្ឋានបានដែរឬទេថា ក្រៅពីកងវរសេនាធំ៧៥ ដែលលោកចំណុះឲ្យនោះគឺមានកងវរសេនាធំចំនួនបីទៀតដែលចំណុះឲ្យកងពល៣១០។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយពីកិច្ចប្រជុំមួយដែលលោកបាននិយាយជាមួយលោកចៅក្រម ឡាវ៉ែន៍ ហើយនិងជាមួយមេធាវី លោក នួន ជា គឺកិច្ចប្រជុំដែលមាន តាអឿន ជាប្រធាន ដែលនៅក្នុងកិច្ចប្រជុំនោះ គឺមាននិយាយអំពីគម្រោងធ្វើរដ្ឋប្រហារ។ តើនៅក្នុងឱកាសប្រជុំនោះ កងវរសេនាធំទាំងបួន ចំណុះឲ្យកងពលលេខ៣១០ នេះមានវត្តមានដែរឬទេនៅក្នុងកិច្ចប្រជុំហ្នឹង?

[០៩:២១:៤៣]

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ ខ្ញុំបាទពុំបានដឹងទេ ការប្រជុំរបស់ថ្នាក់កងពល។ ដឹងតែពីការដឹកកាំភ្លើងទៅហើយ គេថា "កុំចេះ"។ ក្រោយមក ទើបខ្ញុំបាទបានស្តាប់តាមរយៈដែលគេហៅទៅរៀនសូត្រឲ្យស្តាប់ខ្សែអាត់ ទើបបានដឹងថាគម្រោងរដ្ឋប្រហារ។ នេះសូមអង្គតុលាការមេត្តាជ្រាប។

**ស៖** ខ្ញុំគិតថា ប្រហែលជាយើងមិនយល់គ្នាហើយមើលទៅ។ ខ្ញុំកំពុងនិយាយអំពីការ មុនពេលចាប់ខ្លួនរបស់ តាអឿន។ ខ្ញុំនិយាយពីពេលម្សិលមិញនៅពេលលោកនិយាយជាមួយចៅក្រមឡាវ៉ែន៍ ដែលថា គាត់មានធ្វើកិច្ចប្រជុំមួយដែលគាត់បានពន្យល់ថា គាត់មានគម្រោង ឬផ្តួលរំលំរដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ។ លោកបាននិយាយអំពីកិច្ចប្រជុំហ្នឹងថា លោកបានឮដោយខ្លួនឯងផ្ទាល់ថា តាអឿនហ្នឹង អ្នកនិយាយនៅក្នុងកិច្ចប្រជុំហ្នឹងតែម្តង។ ខ្ញុំមិននិយាយអំពីពេលប្រជុំមួយទៀតដែលកើតឡើងក្រោយពេលចាប់ខ្លួន តាអឿន នោះទេ។ ខ្ញុំចង់និយាយពេលប្រជុំមួយដែលតាអឿន ហ្នឹងគាត់នៅទីនោះហើយគាត់បាននិយាយពីរឿងគម្រោងធ្វើរដ្ឋប្រហារនេះ។

**ឆ៖** និយាយអំពីគម្រោងធ្វើរដ្ឋប្រហារនេះ ខ្ញុំបាទមិនបាននៅស្ដាប់អង្គប្រជុំគេទេ។ នេះសូមអង្គតុលាការមេត្ដាជ្រាប ដូចខ្ញុំបាទបានឆ្លើយពីម្សិលហើយ។

**ស៖** ខ្ញុំសូមឱ្យលោកស្ដាប់សំណួរខ្ញុំឱ្យច្បាស់។ ខ្ញុំមិនសួរលោក ថាតើលោកដឹងព័ត៌មានលម្អិតពីរដ្ឋប្រហារនោះទេ។ សំណួរខ្ញុំ ចង់សួរថាតើដូចដែលលោកឆ្លើយទៅចៅក្រម ឡាវែន៍ ម្សិលមិញអ៊ីចឹង លោកនិយាយថា លោកមានវត្តមាននៅពេលដែល តាអឿន និយាយក្បែរវត្តភ្នំ កាលនោះគាត់និយាយនៅជិតវត្តភ្នំ។ តើខ្ញុំយល់ច្បាស់ដែរឬទេ គាត់និយាយពីរឿងផ្ដួលរំលំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនេះ គាត់និយាយនៅក្បែរវត្តភ្នំ។ ម្សិលមិញលោកនិយាយប្រាប់លោក ចៅក្រមឡាវែន៍ យ៉ាងដូច្នេះ។

**ឆ៖** ខ្ញុំបាទសូមជម្រាបអង្គតុលាការ ដូចខ្ញុំបាទបានជម្រាបហើយថា ការប្រជុំនេះ ខ្ញុំបាទពុំបានដឹងទេ ដឹងតែអំពីគេដឹកកាំភ្លើងទៅដាក់ហើយ គេប្រាប់ថា "កុំចេះ ពួកអស់ឯង អ្នកពិការនៅស្ងៀម" តែប៉ុណ្ណោះ។

[០៩:២៥:០៦]

**ស៖** ខ្ញុំមិនទាន់ចោទសំណួរលម្អិតនោះទេ។ ខ្ញុំមិន -- ខ្ញុំគ្រាន់តែចង់ដឹងថា តើនៅពេលប្រជុំនោះដែលធ្វើទៅក្បែរវត្តភ្នំនុំង មានកងវរសេនាធំទាំងបួននុំងដែរឬទេ ដែលចូលរួមប្រជុំនោះ?

**ឆ៖** ការប្រជុំទ័ពវរសេនាធំ គេចូលគ្រប់។

**ស៖** អ៊ីចឹងខ្ញុំត្រូវយល់ថាយ៉ាងម៉េច? យល់ថាកងវរសេនាធំទាំងបួនហ្នឹងចូលរួមប្រជុំ។ អ៊ីចឹងមែនទេ?

**ឆ៖** កងវរសេនាធំទាំងបួនគេចូលរួមប្រជុំ។

**ស៖** ខ្ញុំយល់ហើយថា លោកបានប្រាប់ហើយថា លោកមិនដឹងអំពីព័ត៌មានលម្អិតទាក់ទងនឹងគម្រោងធ្វើរដ្ឋប្រហារនេះទេ ក៏ប៉ុន្ដែនៅពេលដែលលោកសួរថា -- គេសួរលោកថា តើ -- លោកសួរគេថា យកកាំភ្លើងទៅណា? យកអាវុធទៅណា? គេប្រាប់លោកថា "កុំចេះ" ហើយកាលពីម្សិលមិញលោកឆ្លើយថា លោកបាននិយាយជាមួយនឹងមនុស្សម្នាក់ដែលដឹកអាវុធ។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកនិយាយជាមួយគាត់នៅកន្លែងណា? ហើយអ្នកដែលដឹកអាវុធនោះ ដឹកដោយអី មានយានជំនិះដឹក ឬក៏ស្ពាយដើរថ្មើរជើងនោះទេ? លីសែងតែប៉ុណ្ណឹងទេ?

**ឆ៖** ខ្ញុំបាទ សូមជម្រាបជូនអង្គតុលាការ នៅពេលដែលខ្ញុំបាទបានឃើញគេ គឺខ្ញុំបាទនៅនឹងមុខមន្ទីរពេទ្យកាល់ម៉ែតដែលកន្លែងខ្ញុំបាទនៅ។ ឃើញឡាន សេអ៊ីម គេដឹកកាំភ្លើង ហើយគេឈប់ក្បែរនោះ។

ហ្នឹងខ្ញុំបាទបានសួរគេហើយ គេថា "កុំចេះ"។ ហ្នឹងសូមអង្គតុលាការមេត្តាជ្រាប។

**ស៖** តើអ្នកបើកបរឡានធំហ្នឹងអ្នកប្រាប់លោក ឬក៏អ្នកផ្សេងទៀតជាអ្នកប្រាប់?

**ឆ៖** ខ្ញុំបាទបានសួរអ្នកបើកបរឡាន ឃើញគេឈប់នៅក្បែរនោះ សួរគេ។

**ស៖** តើលោកចាំឈ្មោះអ្នកបើកបរឡាននុ៎ងទេ?

**ឆ៖** ខ្ញុំបាទពុំបានចាំទេ យូរហើយភ្លេចអស់បាត់ហើយ។

**ស៖** តើថ្ងៃនោះៗ មានឡានច្រើន ឬមានឡានតែមួយទេ?

**ឆ៖** នៅពេលដែលខ្ញុំបាទឃើញ គឺឃើញឡានតែមួយបាទ។

[០៩:២៩:១៥]

**ស៖** តើលោកដឹងថាឡានហ្នឹងចេញមកពីណា ហើយទៅណាដែរឬទេ?

**ឆ៖** ឡាននោះឃើញចេញទៅពីទិសខាងជើង ហើយចូលទៅឈប់នៅកន្លែងក្បែរនោះបាទ។

**ស៖** ហើយតែកុង អ្នកបើកបរឡានដែលប្រាប់លោកថាកុំចេះហ្នឹង គឺគាត់ប្រាប់លោកមុនកិច្ចប្រជុំនៅក្បែរវត្តភ្នំហ្នឹង ឬក៏ក្រោយហ្នឹង?

**ឆ៖** អ្នកដែលបើកបរឡានដែលខ្ញុំបាទបានសួរគេ ហើយគេប្រាប់ថាកុំចេះនោះ គឺមុនពេលប្រជុំ។

**ស៖** ឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីកិច្ចប្រជុំនៅជិតវត្តភ្នំហ្នឹង តើនៅពេលដែល តាអឿនឡើងនិយាយ តើគាត់មានបាននិយាយ -- ពេលដែលគាត់ឡើងហ្នឹង តើគាត់មានបានប្រាប់ថា អង្គភាព ក-៤ នេះមានតួនាទីអ្វីដែរឬទេ នៅក្នុងផែនការធ្វើរដ្ឋប្រហារនេះ?

**ឆ៖** ខ្ញុំបាទសូមជម្រាបអង្គតុលាការ ដូចខ្ញុំបាទជម្រាបពីថ្ងៃម្សិលហើយថា អង្គភាពអ្នកពិការ ក-៤ គេគ្រាន់តែឲ្យជួយរៀបចំស្បៀងសម្រាប់ចាត់ចែងការងារប៉ុណ្ណោះ។

[០៩:៣១:២៧]

**ស៖** តើស្បៀងអាហារដែលលោកត្រូវចាត់ចែងហ្នឹងមកពីណាដែរ យកមកពីណាដែរ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ។ ខ្ញុំបាទអត់បានដឹងថាគេដឹកពីណាមកទេ គ្រាន់តែដឹងថា គេដឹកយកទៅដាក់កន្លែងក-៤ សម្រាប់ឲ្យអ្នកពិការហ្នឹងដាំបាយ ហើយវេចខ្ចប់ត្រៀមទុកការពារប៉ុណ្ណោះ។

**ស៖** ស្បៀងដែលលោកត្រូវវេចខ្ចប់នោះ តើលោកបានឃើញស្បៀងនោះមុនពេលប្រជុំនៅវត្តភ្នំ ឬក៏លោកឃើញនៅពេលណាមួយក្រោយទេ ឬក៏អាចមុននឹងទៅទៀត?

E1/317.1/Old-2

**ឆ៖** កាលដែលខ្ញុំឃើញ គឺមុនការប្រជុំនៅវត្តភ្នំ។

**ស៖** តើជាថ្ងៃតែមួយដែលលោកឃើញឡានដឹកអាវុធហ្នឹង ឬក៏លោកឃើញនៅពេលផ្សេងទេ?

**ឆ៖** កាលដែលខ្ញុំបាទឃើញឡានដឹកអាវុធ គឺមុនមួយថ្ងៃ។

**ស៖** តើស្បៀងទាំងអស់ហ្នឹងត្រូវបានដាក់ទុកនៅកន្លែងណា ដើម្បីឲ្យក្រុមលោកហ្នឹងវេចខ្ចប់?

**ឆ៖** ស្បៀងដែលត្រូវឲ្យវេចខ្ចប់ គឺកន្លែង ក-៤ កន្លែងយុទ្ធជនពិការ។

[០៩:៣៤:០៥]

**ស៖** តើនៅកន្លែងណាដែរ ឲ្យជាក់លាក់តែម្ដង? លោកអាចពន្យល់បានទេ នៅកន្លែង ក-៤ ហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** នៅកន្លែង ក-៤ គឺនៅកន្លែង ខ្ញុំបាទភ្លេចផ្ទះហើយកន្លែងនោះ បាទ។

**ស៖** តើនៅជិតពោធិ៍ចិនតុងដែរ ឬក៏យ៉ាងណា?

**ឆ៖** កន្លែងនោះ គឺនៅខាងជើងពោធិ៍ចិនតុង។

**ស៖** ឥឡូវ ខ្ញុំសូមចូលទៅនិយាយពីពេលវេលាមួយទៀត គឺក្រោយពេលដែលមេរបស់លោកទាំងអស់ត្រូវបានគេចាប់ខ្លួន។ អ៊ីចឹង ករណីជាក់ស្ដែង គឺតាអឿន និង តាគឹម។ លោកបាននិយាយពីកិច្ចប្រជុំមួយដែលគេបាននិយាយប្រាប់លោកអំពីការក្បត់របស់មេរបស់លោកទាំងអស់ហ្នឹង ហើយនៅក្នុងកិច្ចប្រជុំហ្នឹងដដែល គេបានចាក់ខ្សែអាត់សារភាពរបស់គាត់ ពួកគាត់ទាំងអស់គ្នា ហើយក្រោយពេលកិច្ចប្រជុំហ្នឹងនោះ តើលោកត្រូវបានគេសួរចម្លើយដែរឬទេ ទាក់ទងទៅនឹងផែនការក្បត់របស់កម្មាភិបាលផ្សេងៗទៀតនោះ?

**ឆ៖** ខ្ញុំបាទសូមបញ្ជាក់ជូនអង្គតុលាការ ថាក្រោយពីពេលដែលបានរៀនសូត្រ ហើយបានស្ដាប់ខ្សែអាត់របស់មេកងពលមក គឺអង្គភាព ក-៤ មានការរើសរុះចាត់តាំងថ្មីទៀត ដោយយកភូមិភាគនិរតីមកដាក់អបជាមួយ។

[០៩:៣៦:៣៤]

**ស៖** ខ្ញុំយល់ហើយរឿងនេះ ប៉ុន្តែសំណួរអម្បាញ់មិញនេះ គឺចង់ដឹងថាតើមានគេសួរសំណួរទៅកាន់លោក ទាក់ទង -- សួរថាតើលោកមានដឹងអំពីគម្រោង ឬផែនការក្បត់ហ្នឹងដែរឬទេ គឺនៅពេលដែលនៅក-៤នេះ តើកងពល៣១០ហ្នឹង មានចោទសំណួរទៅលោក សួរលោកថាតើលោកមានដឹងអំពីផែនការក្បត់របស់មេៗរបស់លោកទាំងប៉ុន្មានដែលត្រូវបានគេចាប់ខ្លួនហ្នឹងដែរឬទេ?

**ផ៖** ខ្ញុំបាទសូមបំភ្លឺ មិញស្តាប់មិនសូវបាន។

**ស៖** លោកបាននិយាយថា មានកិច្ចប្រជុំមួយដែលគេឲ្យលោកស្តាប់ខ្សែអាត់សារភាពរបស់មេរបស់លោកទាំងអស់ហ្នឹង។ អ៊ីចឹងសំណួររបស់ខ្ញុំហ្នឹង ខ្ញុំចង់សួរថាតើកម្មាភិបាលមកពីនិរតីដែលមកជំនួសមេៗរបស់លោកនោះ ក្នុងពេលណាមួយ តើកម្មាភិបាលមកពីនិរតីមានបានសួរយោធានៅក្នុង ក-៤ ឬនៅក្នុងកងពល៣១០ ដើម្បីឲ្យដឹងថា ពីផែនការ ឬក៏ដើម្បីដឹងឲ្យច្បាស់អំពីផែនការក្បត់ដែរឬទេ។ ខ្ញុំចង់សួរថាតើលោកផ្ទាល់ ឬក៏យោធានៅក្នុង ក-៤ របស់លោកនេះ ត្រូវបានពួកនិរតីសួរចម្លើយដែរឬទេ ទាក់ទងនឹងផែនការក្បត់ហ្នឹង?

**ផ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ ភូមិភាគនិរតីមកនេះ គ្រាន់តែជួយបំពាក់បំប៉នថាមេសមមិត្តទាំងអស់ក្បត់ហើយ យើងខំប្រឹងធ្វើការងារ។ តែគេមានភារកិច្ចមួយ គឺតាមដានយើងនៅភូមិភាគឧត្តរ។

[០៩:៣៨:៤៨]

**ស៖** ខ្ញុំព្យាយាមតាមរបៀបផ្សេងទៀត។ លោកសាក្សី តើលោកមានត្រូវបានកម្មាភិបាលមកពីនិរតី ឬក៏អ្នកណាម្នាក់ផ្សេងទៀតមកនិរតី សួរអំពីផែនការក្បត់ដែរឬទេ ឬក៏ពីមូលដ្ឋាននៃការចាប់ខ្លួនមេៗរបស់លោកនោះ?

**ផ៖** ខ្ញុំបាទសូមឆ្លើយបំភ្លឺ នៅពេលដែលគេចាប់មេៗអស់ ហើយគេយកភូមិភាគនិរតីមកនេះ គឺគេធ្វើប្រវត្តិរូបពីរថ្ងៃម្តង បីថ្ងៃម្តង ប្រវត្តិរូបនេះ មិនដែលមាននិយាយអំពីកិច្ចការងារអ្វីទេ។

**ស៖** ពេលដែលលោកនិយាយថាមិនមាននិយាយអ្វីទេ។ អ៊ីចឹងលោកចង់និយាយថា មិនមានណាសួរលោកទេ ទាក់ទងនឹងផែនការក្បត់ហ្នឹង ឬក៏យ៉ាងណា?

**ផ៖** គេពុំបានសួរអំពីផែនការក្បត់របស់មេៗទេ តែគេគ្រាន់តែប្រាប់ថា "សមមិត្តទាំងអស់ត្រូវខិតខំធ្វើការងារ ព្រោះពួកមិត្តៗទាំងអស់ជាប់និន្នាការនយោបាយ ព្រោះមេរបស់មិត្តក្បត់អស់ហើយ ដូច្នេះត្រូវតែលត់ដំកិច្ចការងារទាំងឡាយ ត្រូវតែខំប្រឹងប្រែង ហើយនិងធ្វើប្រវត្តិរូប"។ ដូចខ្ញុំបានជម្រាបបញ្ជាក់ជូនខាងដើមហើយ ថាពីរថ្ងៃម្តង បីថ្ងៃម្តង ប្រវត្តិរូបនេះ។

**ស៖** ខ្ញុំយល់ហើយចំណុចនេះ ខ្ញុំដឹងថាលោកអស់កម្លាំងហើយ ព្រោះមួយថ្ងៃៗសួរលោកច្រើនក៏ប៉ុន្តែខ្ញុំព្យាយាមសួរសំណួរជាក់លាក់ អ៊ីចឹងខ្ញុំសូមឲ្យលោកឆ្លើយមកសំណួរខ្ញុំឲ្យបានច្បាស់លាស់។ បន្ទាប់ពីការចាប់ខ្លួនរបស់មេៗរបស់លោកហ្នឹង លោកបាននិយាយថា៖ "លោកកាលណោះ ត្រូវទៅនៅ

ឃ្នួញ” (សូមទោសចំពោះអ្នកបកប្រែ គឺឃ្នួញ)។ លោកបាននិយាយថា “លោកត្រូវបានបញ្ជូនទៅឃ្នួញហ្នឹង” តើនៅឃ្នួញ លោកមានបានឃើញអ្នកបើកបរដែលលោកនិយាយជាមួយគាត់ហ្នឹងទាក់ទងនឹង -- តើគាត់ហ្នឹង អ្នកបើកបរឡានហ្នឹងទៅឃ្នួញហ្នឹងដែរ ហើយបានជួបលោក បានជាលោកសួរគាត់ថា “ដឹកអារុធធ្វើអីហ្នឹង” ហើយដែលគាត់ឆ្លើយវិញថា “កុំចេះ”។ តើនៅឃ្នួញហ្នឹង ឬក៏នៅកន្លែងណាដែលលោកជួបគាត់?

[០៩:៤២:២៤]

**ធ៖** ត្រង់ចំណុចនេះ ខ្ញុំបាទសូមឆ្លើយបំភ្លឺអង្គតុលាការ មិនមែននៅឃ្នួញកន្លែងខ្ញុំបាទលត់ដំទេ កាលណោះ ខ្ញុំបាទបានចែវទៅលេងភ្នំពេញ ហើយទៅដល់មុខមន្ទីរពេទ្យកាល់ម៉ែត ហើយឃើញគេក៏សួរគេប៉ុណ្ណឹងឯងបាទ ហើយគេថា “កុំចេះរឿងឯងដោយឯង រឿងគេដោយគេ”។

**ស៖** ខ្ញុំយល់ហើយ ខ្ញុំនិយាយអំពីរយៈពេលក្រោយការចាប់ខ្លួនរបស់មេៗរបស់លោកទេ។ អ៊ីចឹងខ្ញុំសួរលោកថា តើគេបញ្ជូនលោកទៅអប់រំកែប្រែនៅកន្លែងណាដែរ ទៅលត់ដំ?

**ធ៖** ដូចខ្ញុំបាទបានជម្រាបពីថ្ងៃមុនហើយថា នៅពេលដែលគេចាប់មេៗអស់ គេបញ្ជូនខ្ញុំបាទទៅលត់ដំកែប្រែនៅអន្លង់ក្ងាន។

**ស៖** អ៊ីចឹងលោកមិនដែលទៅឃ្នួញទេ ឬក៏យ៉ាងណា?

**ធ៖** នៅពេលដែលខ្ញុំបាទត្រូវគេបញ្ជូនឲ្យទៅលត់ដំកែប្រែនៅអន្លង់ក្ងាន គ្មានពេលមកឃ្នួញវិញទេបាទ។

**ស៖** តើនៅកន្លែងដែលគេអប់រំកែប្រែលោកនោះ មានអតីតកងវរសេនាធំទាំងបួនដែលចំណុះឲ្យកងពល៣១០ ដែរឬទេ?

**ធ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ ត្រង់ចំណុចនេះនៅអន្លង់ក្ងាន គ្មានវរសេនាធំទេ ចប់អស់ហើយ មានត្រឹមវរសេនាតូចខ្លះ ដែលទៅនៅកន្លែងលត់ដំ កែប្រែនៅកន្លែងនោះ។

[០៩:៤៥:១៦]

**ស៖** ក្រោយពីអប់រំកែប្រែហើយនោះ លោកនិយាយថា លោកត្រូវបានគេបញ្ជូនទៅកំពង់ឆ្នាំង នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាថ្ងៃទី១២ មិថុនា ឆ្នាំ២០១៥ ក្រោយម៉ោងដប់បួន ដប់ប្រាំមួយនាទីបន្តិច លោកបានរក្សាចម្លើយរបស់លោក ដែលលោកបានឆ្លើយនៅក្នុងកំណត់ស្តាប់ចម្លើយរបស់លោក ដែលលោកថានៅពេលទៅដល់កំពង់ឆ្នាំងភ្លាម លោកឃើញកងពល

ផ្សេងទៀតដែរ គឺមានកងពល៤៥០ជាដើម ទោះបីជាគេមិនអនុញ្ញាតឲ្យលោកជួបគ្នាក៏ដោយ។ តើលោកអាចពន្យល់ជូនតុលាការដែរឬទេ ថាលោកអាចបានជួបសមាជិកកងពល -- ទាហាននៅក្នុងកងពល៤៥០ហ្នឹង តាមរបៀបណាដែរ? យ៉ាងម៉េចបានជាបានជួបដែរហ្នឹង បានដឹងថាមានកងពល៤៥០ហ្នឹងដែរ បើគេមិនអនុញ្ញាតឲ្យជួបគ្នាផងនោះ?

**ឆ៖** ខ្ញុំបានសូមជម្រាបជូនអង្គតុលាការ នៅពេលដែលដឹងថាអ្នកនេះនៅកងពល៣១០ អ្នកនោះនៅកងពល៤៥០ នៅពេលដែលចេញពីកន្លែងដែលធ្វើការ អ្នកខ្លះក៏ដើរបណ្តោយបញ្ច្រាសគ្នា ឃើញគ្នាហើយសួរ តែមិនប៉ានឈប់សួរគ្នាទេ គ្រាន់តែសួរ "ហ្អុក! មិននៅខាងខាងណា" "ខ្ញុំនៅខាងនេះ" ក៏ហួសទៅ។ មួយទៀតជួបគ្នា គឺសួរថា "មិត្តនៅខាងណា?" ខ្ញុំថា "ខ្ញុំនៅខាងនេះ។ ចុះមិត្តនៅខាងណា?" "ខ្ញុំនៅខាងនោះ"។ ចង់ឲ្យឈរជជែកគ្នាអត់បានទេ ព្រោះគេត្រួតពិនិត្យ។

**ស៖** ទាក់ទងទៅនឹងកងពល៤៥០ តើលោកបានធ្លាប់ប្រយុទ្ធរួមដៃគ្នាជាមួយនឹងកងពល៤៥០នេះ មុនពេលដណ្តើមបានទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** នៅពេលដែលរួមប្រយុទ្ធក្នុងសមរភូមិ ខ្ញុំបាទមិនដែលបានជួបកងពល៤៥០ នេះទេ។

[០៩:៤៨:០៧]

**ស៖** តើលោកមានឈ្មោះ ប៉ុល ញ៉ុន -- សម្រាប់អ្នកបកប្រែជាភាសាបារាំង -- ឈ្មោះ ប៉ុល ញ៉ុន។ ខ្ញុំប្រើឯកសារ E3/5554។ លោកសាក្សី តើលោកស្គាល់ឈ្មោះ ប៉ុល ញ៉ុន នេះដែរឬទេ?

**ឆ៖** ខ្ញុំបាទ មិនបានចាំទេ ប៉ុល ញ៉ុន ព្រោះយូរហើយ ខ្ញុំបាទភ្លេចអស់ហើយបាទ។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ ដែលគាត់ឆ្លើយនៅមុខអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត គាត់បានលើកឡើងអំពីកងពល៤៥០ ហើយគាត់និយាយដូចតទៅនេះទាក់ទងទៅនឹងកងពល៤៥០នេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអភ័យទោស ខ្ញុំឲ្យលេខយោងខុសអម្បាញ់មិញនេះ។ ខ្ញុំសូមមន្ត្រីតុលាការជួយផ្តល់ឯកសារនេះទៅសាក្សី នូវចម្លើយរបស់មនុស្សម្នាក់ទៀតដែលឆ្លើយឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា គឺសាក្សី 2-TCW-901 ព្រោះសាក្សីនេះនឹងមកផ្តល់សក្ខីកម្មនៅទីនេះដែរ អ៊ីចឹងខ្ញុំសុំមិនឲ្យគាត់បញ្ចេញឈ្មោះទេ។

លោកប្រធាន ខ្ញុំសុំអនុញ្ញាតផ្តល់ឯកសារនេះឲ្យទៅសាក្សី ហើយសូមឲ្យមន្ត្រីតុលាការជួយយកឯកសារនេះទៅជូនគាត់។ លោកប្រធានសុំអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

ប្រាប់គាត់ទៅ ប្រាប់ខ្សឹបៗទៅ គាត់មិនមានលទ្ធភាពអានបានទេ គាត់មើលមិនច្បាស់ទេ។ ហើយកុំប្រាប់ -- កុំឲ្យគាត់បញ្ចេញឈ្មោះនុំង ចាំស្ដាប់សំណួរដែលមេធាវីសួរ។

[០៩:៥១:១០]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

មុននឹងខ្ញុំសុំឲ្យលេខឯកសារនោះ គឺឯកសាររបស់សាក្សីហ្នឹងគឺ D19.47, ERN ជាភាសាបារាំង 00823166, ERN ជាភាសាខ្មែរគឺ 00019667, ERNជាភាសាអង់គ្លេស 00680653។ ឯកសារអម្បាញ់មិញនេះគឺជាឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** លោកសាក្សីសំណួរទី១របស់ខ្ញុំ ខ្ញុំចង់សួរថា តើលោកមានស្គាល់ឈ្មោះដែលនៅលើឯកសារដែលខ្ញុំផ្ដល់ឲ្យអម្បាញ់មិញ ដែលមន្ត្រីតុលាការផ្ដល់ជូនលោកនេះ ឈ្មោះមានសរសេរនៅលើក្រដាសហ្នឹងហើយ លោកស្គាល់ឈ្មោះហ្នឹងទេ?

**លោក កែវ លឿ៖**

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ ខ្ញុំបាទភ្លេចអស់ហើយ អត់ចាំទេ។

**ស៖** គាត់និយាយអំពីកងពល៤៥០ ដូចតទៅនេះ ខ្ញុំអាន បន្ទាប់មក ខ្ញុំសួរសំណួរទៅលោក។ “នៅពេលនោះមានកងពលបីដែលមកព័ទ្ធទីក្រុងភ្នំពេញ គឺកងពល៣១០ និងកងពល៤៥០ និងកងពលមានដែលលេខសាមសិបប៉ុន្មានទេ ខ្ញុំភ្លេចហើយ។ តែខ្ញុំចាំពីកងពល៤៥០។ ក៏ប៉ុន្តែខ្ញុំភ្លេច ឈ្មោះប្រធានហើយនិងអនុប្រធានកងពលហ្នឹងហើយ”។ សូមបញ្ចប់ការដកស្រង់។ សំណួរទី១របស់ខ្ញុំ តើលោកនឹកឃើញឡើងវិញទេ គឺថាអង្កាល់នោះនោះនៅពេលដែលដណ្ដើមចូលទីក្រុងភ្នំពេញនោះ គឺកងពល៤៥០ ហើយនិងកងពល៣១០នេះ ប្រកៀកស្មាគ្នាដណ្ដើមយកទីក្រុងភ្នំពេញ វាយលុកចូលយកទីក្រុងភ្នំពេញ។ លោកចាំទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោក ចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បើខ្ញុំមិនច្រឡំទេ គឺថាសាក្សីនេះគាត់បានឆ្លើយជាច្រើនដងហើយថា គាត់បានរបួសជាច្រើនដង-

- គាត់ឆ្លើយជាច្រើនដងហើយ ថាគាត់បានរបួស គាត់មិនបានចូលរួមវាយដណ្ដើមចូលទីក្រុង--ដណ្ដើមយកទីក្រុងភ្នំពេញទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

អ៊ីចឹងខ្ញុំសូម -- អ៊ីចឹងខ្ញុំកែសំណួរខ្ញុំវិញ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** តើលោកដឹងថាមានកងពល៣១០ ហើយនិងកងពល៤៥០ នេះចូលរួមវាយដណ្ដើមយកទីក្រុងភ្នំពេញដែរឬទេ? លោកដឹងថាគេចូលមកវាយទីក្រុងភ្នំពេញនេះ ក្នុងលក្ខខណ្ឌយ៉ាងម៉េចដែរ ពីព្រោះថា លោកផ្ទាល់នោះ លោកជាសមាជិក ឬក៏ជាយោធាស្ថិតនៅក្នុងកងពលលេខ៣១០ដែរ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ ដូចខ្ញុំបាទបានជម្រាបជូនខាងដើមហើយថា ខ្ញុំបាទពុំបានដឹងថា កងពលណានៅខាងណាទេ ពេលខ្ញុំបាទរបួស គឺថ្ងៃ០១ ខែ០១ ឆ្នាំ៧៥ ចូលមកក៏របួសបណ្ដោយ។ ចាប់ពីពេលនោះមក ខ្ញុំបាទអត់បានដឹងថាទិសដៅគេវាយពីណាទៅណាទេ។ នេះសូមអង្គតុលាការមេត្តាជ្រាប។

[០៩:៥៥:១៥]

**ស៖** ក៏ប៉ុន្តែដោយសារលោករូបលោកផ្ទាល់ លោកបាននិយាយអំពីកងពល៤៥០នេះ នៅពេលដែលសហចៅក្រមស៊ើបអង្កេត -- អ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេតសួរលោក ហើយបន្ទាប់មកព្រះរាជអាជ្ញាក៏សួរលោកដែរ។ អ៊ីចឹងលោកៗមិនបានឮគេនិយាយថា កងពល៣១០ ហើយនិងកងពល៣៥០ និងបានចូលរួមប្រយុទ្ធដណ្ដើមទីក្រុងភ្នំពេញទេ។ ឥឡូវដើម្បីបំភ្លឺឲ្យកាន់តែច្បាស់ ខ្ញុំសូមដកស្រង់ចំណុចមួយទៀត គឺឯកសារជាភាសាបារាំង 00823167, ជាភាសាខ្មែរ 0001967-- ហើយជាភាសាអង់គ្លេសគឺ 00680653។ “កងពលលេខ៤៥០នេះ គ្រាន់តែជាមកជាជំនួយទេ។ សំណួរ៖ ចុះ៣១០ យ៉ាងម៉េចដែរ? ៣១០នេះមានបញ្ហា ៤៥០ត្រូវមកជួយ ហើយ៤៥០នេះ គឺបំបែកចេញពី៣១០នេះទេ”។ អ៊ីចឹងសំណួរខ្ញុំសួរដូចតទៅនេះ តើលោកដឹងដែរឬទេថាសមាជិកកងពល៣១០នេះ ដែលមានកងវរសេនាធំលោកជាដើមនោះ បន្ទាប់មកទៀតហ្នឹងក៏បំបែកទៅធ្វើ -- ទៅបង្កើតកងពលមួយទៀតគឺកងពល៤៥០ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ ខ្ញុំបាទពុំបានដឹងអំពីការបំបែកទ័ពយ៉ាងម៉េចទេ ទាន។ សូមអង្គតុលាការមេត្តាជ្រាប។

**ស៖** បើខ្ញុំយល់ចម្លើយលោកមិនខុសទេនោះ គឺថានៅពេលណាមួយលោកជាអនុប្រធាន -- អនុសេនាតូច។ តើនៅក្នុងការដំឡើងឋានន្តរសក្តិលោកនោះ គេមិនបានពន្យល់ប្រាប់លោកអំពីរចនាសម្ព័ន្ធយោធាទេឬ បំណែងចែកយោធា ហើយគេមិនបានប្រាប់លោកថានៅកងអនុសេនាតូចលោកនោះ ស្ថិតចំណុះឲ្យកងវរសេនាធំណា ឬក៏កងពលធំណាទេឬ?

[០៩:៥៨:១២]

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ កាលដែលខ្ញុំបាទបានទទួលឋានៈជាអនុកងតូចនៅពេលនោះ អង្គភាពដែលខ្ញុំបាទនៅគឺនៅក្នុង៣១៧ មិនទាន់ទៅ៧២៩នៅឡើយទេ។ បាទ សូមអង្គតុលាការមេត្តាជ្រាប។

**ស៖** ប៉ុន្តែសំណួរខ្ញុំនោះ គឺខ្ញុំសួរលោកថា នៅពេលដែលគេចាត់តាំងឲ្យលោកកាន់តំណែងអីមួយនោះ គឺគេមិនបានពន្យល់លោកអំពីរចនាសម្ព័ន្ធយោធាទេឬ? ឧទាហរណ៍ថាមានកងពល កងវរ-សេនាធំ អនុសេនាតូច វរសេនាតូចអីជាដើមនេះ។ តើគេអត់មានបង្រៀនប្រាប់លោកទេថា អង្គភាពលោកហ្នឹងចំណុះឲ្យអង្គភាពណាមួយ ហើយបំណែងចែកយោធាហ្នឹងយ៉ាងម៉េចហ្នឹង គេអត់មានពន្យល់ប្រាប់លោកទេ ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ កាលប្រកាសចាត់តាំងនេះ មិនបានពន្យល់ថា អ៊ូ! មិត្តឯងទៅខាងណាមកណា គឺគ្រាន់តែថា សមមិត្តនេះទទួលជាអនុកងតូចនៅក្នុងកងធំនេះ តែប៉ុណ្ណោះ។

**ស៖** តើលោកធ្លាប់បាននិយាយអំពីកងពល៦០៣ ដែរឬទេ?

**ឆ៖** ខ្ញុំបាទមិនបានចាំទេ។

**ស៖** លោកបានឆ្លើយថា លោកមិនចាំឈ្មោះ ប៉ុល ញ៉ូន នោះទេ។ ឥឡូវខ្ញុំអាចចម្លើយរបស់គាត់មួយ ហើយក្រោយមកខ្ញុំសួរសំណួរទៅកាន់លោក។ គឺឯកសារ E3/5554, ERN ជាភាសាបារាំងគឺ 00422422, ERN ជាភាសាអង់គ្លេស 00377401, ERN ជាភាសាខ្មែរគឺ 00373269។ គាត់និយាយអំពីកងពល៦០៦ដូចតទៅថា៖ “មានកងវរសេនាធំបីគឺ ១០១, ១០២, ១០៣។ ក៏ប៉ុន្តែកម្លាំងតែពីរកងវរសេនាធំទេ ដែលត្រូវបញ្ជូនទៅប្រតិបត្តិការនៅបូព៌ា។ មុន នោះជាមេបញ្ជាការនៃវរសេនាធំ១០២ ខ្ញុំជាអនុប្រធាន។ ហើយវរសេនាធំទៀតគឺ វរសេនាធំ១០១នោះត្រូវទៅព្រលានយន្តហោះកំពង់ឆ្នាំង។” សូមបញ្ចប់ការដកស្រង់។ សំណួរទី១របស់ខ្ញុំចង់ដឹងថា តើលោកមានបានជួប –នៅកំពង់ឆ្នាំងនោះ– ជួបអ្នកដែលមកពីកងពល៦០៣ ជាពិសេសគឺកងវរសេនាធំ១០១ ដែលគេបញ្ជូនឲ្យទៅសាងសង់ព្រលានយន្ត

ហោះកំពង់ឆ្នាំងហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំបាទមិនដែលបានស្គាល់កងពល៦០៣អីទេ បាទ។

[១០:០២:៣០]

**ស៖** តើជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថានៅក្នុងយោធា នៅពេលនោះ ថាពេលនោះលោកមិនបានទៅប្រយុទ្ធទេ គឺគេឱ្យលោកកសាងប្រទេស ឧទាហរណ៍ដូចជាដាំដំណាំ ឧទាហរណ៍ដូចនៅព្រលានយន្តហោះជាដើម គឺសាងសង់អគារអីជាដើម ដើម្បីប្រទេសជាតិ ឧទាហរណ៍ដូចជាសាងសង់ទំនប់អីជាដើម ឬក៏ការសាងសង់ព្រលានយន្តហោះហ្នឹងដែលលោកបានចូលរួម? អ៊ីចឹងចង់និយាយថា នៅពេលដែលយើងមិនបានទៅប្រយុទ្ធទេ តើតួនាទីរបស់យើងគឺត្រូវធ្វើការសាងសង់ប្រទេសហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ លោកមេត្តាជ្រាប។ ខ្ញុំបាទមិនបានទៅប្រយុទ្ធនៅជួរមុខទេ គឺគេឱ្យនៅធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំង គឺរួមចំណែកកសាងការពារមាតុភូមិ។ នេះសូមអង្គតុលាការមេត្តាជ្រាប។

**ស៖** សុំការបំភ្លឺមួយ តើលោកអាចជម្រាបជូនតុលាការបានឬទេ ថាតើឯកសណ្ឋានដែលលោកពាក់មុនខែមេសា ឆ្នាំ១៩៧៥ហ្នឹងយ៉ាងម៉េចដែរ? ហើយក្រោយខែមេសា ឆ្នាំ១៩៧៥ហ្នឹង តើឯកសណ្ឋានយោធាហ្នឹងខុសពីឯកសណ្ឋានមុនឆ្នាំ៧៥ ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ នៅមុនឆ្នាំ៧៥ គឺបើកខោអាវទ័ព។ តែក្រោយឆ្នាំ១៩៧៥ អ្នកធំៗគេបានអាវតេតារុង។ ចំណែកយុទ្ធជនសុទ្ធសាធ គឺអាវខ្មៅ ខោខ្មៅធម្មតា។

[១០:០៥:១៥]

**ស៖** អ៊ីចឹងបើលោក មានតែកម្មាភិបាលធំៗទេ ដែលមានឯកសណ្ឋានយោធា បើមិនអ៊ីចឹងទេយោធាផ្សេងៗទៀតនោះ សុទ្ធតែមានឯកសណ្ឋានខ្មៅទាំងអស់។ តែប៉ុណ្ណឹងទេ មានឯកសណ្ឋានខ្មៅទេដែលយោធាផ្សេងៗហ្នឹង។ តើលោកចង់និយាយថាអ៊ីចឹងឬយ៉ាងម៉េច?

**ឆ៖** ខ្ញុំសូមជម្រាបជូនអង្គសវនាការ ដូចខ្ញុំបាទបានជម្រាបហើយថា នៅពេលនោះគឺខ្ញុំបាទទាំងអស់គ្នា គឺស្លៀកខ្មៅ ពាក់ខ្មៅ គេបើកឱ្យខ្មៅ បាទ។

**ស៖** អ៊ីចឹង បើខ្ញុំយល់មិនច្រឡំទេ គឺថាមុន៧៥ ក៏ដូចជាក្រោយ៧៥ដែរ គឺលោកពាក់ឯកសណ្ឋានខ្មៅ។ អ៊ីចឹងមែនទេ?

**ផ៖** សូមមេត្តាអនុញ្ញាតជួយបំភ្លឺ ខ្ញុំបាទដូចស្តាប់បានថា មុន៧៥ និងក្រោយ៧៥ សូមបំភ្លឺ។

**ស៖** ខ្ញុំសួរលោកផ្ទាល់នេះ តើលោកពាក់ឯកសណ្ឋានពណ៌ខ្មៅហ្នឹងរហូត គឺថាមុនឆ្នាំ៧៥ ក៏លោកពាក់ឯកសណ្ឋានខ្មៅ ក្រោយឆ្នាំ៧៥ ក៏លោកពាក់ឯកសណ្ឋានពណ៌ខ្មៅដែរ ខ្ញុំចង់សួរអ៊ីចឹង?

**ផ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ មុនឆ្នាំ១៩៧៥ គឺស្លៀកពាក់ទ័ព តែក្រោយឆ្នាំ១៩៧៥ ខ្ញុំបាទស្លៀកខោខ្មៅ អាវខ្មៅ។

**ស៖** អ៊ីចឹងករណីនេះ សម្រាប់អនុវត្តសម្រាប់យោធាផ្សេងទៀតទាំងអស់ ក្រៅតែពីកម្មាភិបាលជាន់ខ្ពស់ទេឬ? ចង់និយាយថាកូនទាហានតូចតាចហ្នឹង មានឯកសណ្ឋានដូចលោកអ៊ីចឹង ហើយដល់ពេលកម្មាភិបាលជាន់ខ្ពស់ ឬក៏មេៗហ្នឹង គេមានឯកសណ្ឋានផ្សេង លោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

[១០:០៨:០៨]

**ផ៖** ខ្ញុំបាទចង់និយាយថា មេៗគេមានខោអាវតេតារុងស្អាតៗ។ យុវជន គឺមានខោផាឌិប អាវផាឌិបបាទ។

**ស៖** លោកនិយាយអម្បាញ់មិញគឺថាមានខោអាវធម្មតាហ្នឹង ផាឌិបហ្នឹង។ អ៊ីចឹងលោកចង់និយាយថាយ៉ាងម៉េចដែរ ពណ៌អីដែរផាឌិបហ្នឹង?

**ផ៖** ផាឌិប ពណ៌ខ្មៅ។

**ស៖** លោកបានឆ្លើយថា លោកបានឃើញមេដឹកនាំមួយចំនួនមកព្រលានយន្តហោះ។ សំណួរខ្ញុំចង់សួរថា តើលោកឃើញគាត់មកតាមមធ្យោបាយណាដែរ មកដោយជិះអីដែរ?

**ផ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ ដូចខ្ញុំបាទជម្រាបជូនពីថ្ងៃម្សិលហើយថា ថ្នាក់ដឹកនាំខ្ពស់ៗ ដែលទៅត្រួតពិនិត្យព្រលានយន្តហោះ គេទៅតាមដោយឡាន មានអ្នកការពារទៅជាមួយ បាទ។

**ស៖** លោកបានឆ្លើយថា មានរូងមួយដែលគេជីកដើម្បីលាក់យន្តហោះ។ តើលោកមានបានឃើញយន្តហោះទាំងនោះទេ ឬក៏យន្តហោះមួយចំនួនទេ នៅព្រលានយន្តហោះហ្នឹង?

**ផ៖** នៅពេលដែលធ្វើព្រលានយន្តហោះ ហើយនិងរូងយន្តហោះនេះ ពុំទាន់មានយន្តហោះទៅនៅកន្លែងនោះទេ គឺកំពុងទទេ កំពុងធ្វើបាទ។

**ស៖** តើនៅពេលណាមួយនោះ លោកបានឃើញឧទ្ធម្ភាគចក្រមកចុះចតលើព្រលានយន្តហោះហ្នឹងដែរឬទេ នៅការដ្ឋានការងារហ្នឹង?

[១០:១១:០៧]

**ឆ៖** នៅពេលដែលយើងខ្ញុំធ្វើព្រលាននោះ ថ្ងៃមួយគឺឃើញយន្តហោះចុះនៅព្រលានយន្តហោះ ហើយដើរត្រួតពិនិត្យមើល បាទ។

**ស៖** ខ្ញុំមិនមែននិយាយអំពីយន្តហោះទេ ខ្ញុំនិយាយអំពីកន្ទុំរុយ – ឧទ្ធម្ភាគចក្រ។

**ឆ៖** ដូចខ្ញុំបាទបានជម្រាបហើយថា យន្តហោះចុះនោះគឺ ឧទ្ធម្ភាគចក្រ តែខ្ញុំបាទមិនទាន់ស្គាល់ថាជាឧទ្ធម្ភាគចក្រយ៉ាងម៉េចផង ស្គាល់តែអាកន្ទុំរុយ។

[១០:១២:១៦]

**ស៖** តើលោកមានចាំទេថាអ្នកណាដែរដែលជិះឧទ្ធម្ភាគចក្រហ្នឹងមក កន្ទុំរុយហ្នឹងមកព្រលានយន្តហោះហ្នឹង?

**ឆ៖** ខ្ញុំបាទពុំបានចាំបានទេ ភ្លេចភ្លាំងអស់ហើយ។

**ស៖** ខ្ញុំសួរចប់ប៉ុណ្ណឹងហើយ ៗជាបន្តលោកមេធាវី គង់ សំអុន គាត់សុំសួរបួន ដប់នាទីទៀតក្រោយពេលសម្រាកលោកប្រធាន។ គាត់សុំសួរបួន ដប់នាទីបន្ត។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដោយសារតែយើងមានពេលបន្តិចបន្តួចហើយ ដូច្នេះ ខ្ញុំចង់ដឹងថាលោកត្រូវការពេលវេលាប្រហែលជាប៉ុន្មានដែរ?

**លោក គង់ សំអុន៖**

ខ្ញុំត្រូវការពេលមិនច្រើនទេ ប៉ុនបើអាចចង់បន្តឥឡូវក៏បាន បើថាអនុញ្ញាតឲ្យក្រោយពេលសម្រាកក៏ល្អបាទ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវីត្រូវការពេលវេលាប៉ុន្មានដែរ?

**លោក គង់ សំអុន៖**

វាអាចពីខ្ទង់ដប់នាទី។ វាអាស្រ័យទៅលើចម្លើយរបស់គាត់ ដូច្នេះវាពិបាកនៅក្នុងៗការសន្និដ្ឋានពេលវេលាជាក់លាក់បាទ។

[១០:១៤:១៩]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតឲ្យ ១០នាទីយ៉ាងយូរបំផុតចាប់ពីពេលនេះតទៅ។ ដល់១០នាទីភ្លាម

យើងនឹងផ្អាក់តែម្តង។

**សួរដោយលោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំសូមសួរបន្ថែមទៅលើសម្លៀកបំពាក់យោធា ខ្ញុំបានស្តាប់ឮតាំង -- លោកឆ្លើយតាំងពីថ្ងៃសុក្រនៅពេលរសៀលថា យោធាមានសម្លៀកបំពាក់ខុសពីអ្នកផ្សេងទៀត ហើយជាពិសេសលោកសំដៅទៅលើអ្នកយាម។ លោកអាចបញ្ជាក់អំពីសម្លៀកបំពាក់ជាក់លាក់ដែលលោកបានឃើញជាសម្លៀក-បំពាក់យ៉ាងម៉េចដែលខុសពីសម្លៀកបំពាក់ខ្មៅ? មុននេះ លោកបានឆ្លើយផងដែរអំពីកំណាត់តេតារុង ឬក៏កំណាត់ផាឱប។ អ៊ីចឹងលោកអាចបញ្ជាក់ពីស្ថានភាព ពី តាំងពីពណ៌ និងអាវរបៀប*(ឮមិនច្បាស់)* និងទម្រង់ឯកសណ្ឋានដែលលោកអាចសម្គាល់ឃើញថា មានលក្ខណៈខុសគ្នាហ្នឹង ខុសគ្នាយ៉ាងម៉េច?

**ឆ៖** ខ្ញុំបាទសូមបញ្ជាក់ជូន យោធាគឺស្លៀកពាក់យោធា ហើយអ្នកស្លៀកពាក់ខ្មៅដូចជាពួកខ្ញុំគឺស្លៀកខោខ្មៅ អាវខ្មៅធម្មតា។

[១០:១៦:០០]

**ស៖** បាទ ខ្ញុំចង់សួរបញ្ជាក់ឲ្យលោកឆ្លើយថា អាម៉េចទៅដែលហៅថា សម្លៀកបំពាក់យោធាហ្នឹង លោកអាចរៀបរាប់បានទេ?

**ឆ៖** សម្លៀកបំពាក់យោធា គឺខោគគីរ អាវគគីរ។ រីឯយើងខ្ញុំគឺ ស្លៀកខ្មៅ ពាក់ខ្មៅ។ មិនមែនខោគគីរ អាវគគីរទេ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងសន្តិសុខដែលលោកឃើញដើរយាមនៅពេលយប់ នៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹងគឺ ជាអ្នកដែលមានសម្លៀកបំពាក់ខោគគីរ អាវគគីរ។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូន អ្នកយាមនៅកំពង់ឆ្នាំង ស្លៀកខោគគីរ អាវគគីរ ហើយទឹនុយ។

**ស៖** បាទ សូមអរគុណ។ លោកឃើញច្រើនគ្នាទេ ប៉ុន្មាននាក់ដែរ ដែលប្រើប្រាស់ខោគគីរ អាវគគីរនៅពេលដែលគេចុះល្បាត ឬក៏ដើរយាមម្តងៗ?

**ឆ៖** ខ្ញុំបាទ សូមបញ្ជាក់ជូនត្រង់ចំណុចនេះ។ នៅពេលដែល-- ទីតាំងរបស់គេមិនដឹងនៅកន្លែងណា តែដែលឃើញដើរល្បាត គឺឃើញយ៉ាងច្រើនបីនាក់តាមក្រុមរបស់គេ។ នៅពេលដែលពួកខ្ញុំសម្រាកគឺឃើញដើរទៅ ដើរមកហ្នឹង មិនច្រើនលើសពីបីនាក់ទេ បាទ។

**ស៖** បាទ សូមអរគុណ។ បីនាក់ហ្នឹង លោកឃើញច្រើនក្រុម ឬក៏ឃើញតែមួយក្រុមដដែលៗ បីនាក់ហ្នឹង?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការ។ ការឃើញនេះ មុខមិនដូចគ្នាទេ ទៅម្ដងមុខផ្សេង ទៅក្រោយទៀត ឃើញមុខផ្សេង។ តែខ្ញុំបាទទាំងអស់គ្នាដែលនៅកន្លែងនោះ មិនសូវប៊ានមើលមុខគេទេ ហើយមិនប៊ាននិយាយរកគេផង បាទ។

**ស៖** បាទ សូមអរគុណ។ តាមការកត់សម្គាល់របស់លោក លោកឃើញមានប៉ុន្មានក្រុមដែរ បើតាមដែលលោកអាចចាំបាន?

**ឆ៖** បើតាមខ្ញុំបាទនៅចាំបាន មានពីរ ឬបីក្រុម ដែលឃើញមុខខុសៗគ្នានោះ បាទ។

[១០:១៨:៥៦]

**ស៖** បាទ សូមអរគុណ។ ពីរ ទៅ បីក្រុមនេះ គឺលោកឃើញក្នុងអំឡុងពេលណាជាក់លាក់ដែរទេ លោកអាចជម្រាបបានទេ ឬក៏តាំងពីលោកទៅធ្វើការនៅព្រលានយន្តហោះហ្នឹង គឺលោកឃើញតែពីរបីក្រុមនេះដដែលៗ?

**ឆ៖** ខ្ញុំបាទសូមបញ្ជាក់ជូនអង្គតុលាការបានជ្រាប ការឃើញពីរបីក្រុមនេះ ឃើញតែពេលយប់ ម៉ោងប្រាំបី ឬម៉ោងប្រាំបួនទៅ។ នេះឃើញគេដើរចុះឡើងៗ។

**ស៖** បាទ សំណួររបស់ខ្ញុំគឺក្នុងរយៈពេលណាដែរដែលលោកបានឃើញពីរបីក្រុមហ្នឹង? តាំងពីលោកចាប់ផ្ដើមទៅធ្វើការនៅកំពង់ឆ្នាំង រហូតដល់ចុងបញ្ចប់នៅពេលដែលវៀតណាមចូល?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនអង្គតុលាការបានជ្រាប ចាប់តាំងពីខ្ញុំបាទទៅនៅកំពង់ឆ្នាំង រហូតដល់ថ្ងៃ ៧មករា បែកគ្នា ទើបខ្ញុំបាទរត់គេចចេញទៅតាមប្រជាជនបណ្ដោយ បាទ។ នេះឃើញរាល់ថ្ងៃរាល់យប់បាទ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការងារវាស់វែងលោកបញ្ជាក់ហើយថា លោកបានទទួលការហ្វឹកហ្វឺនពីការវាស់វែង ហើយទៅធ្វើការងារខាងវាស់វែង។ ខ្ញុំចង់ -- ដោយសារលោកឆ្លើយអំពីការពិនិត្យលើរូងលាក់យន្តហោះ។ ខ្ញុំចង់សួរថា តើលោកបានទៅវាស់វែងធ្វើរូងលាក់យន្តហោះនេះដែរឬទេ?

**ឆ៖** ខ្ញុំបាទសូមបញ្ជាក់ជូនអង្គតុលាការ សូមមេត្តាជ្រាប ខ្ញុំបាទអ្នកវាស់វែងដីនៅព្រលានយន្តហោះ តែរូងយន្តហោះ គឺអ្នកផ្សេងទៀត ខ្ញុំបាទគ្រាន់តែបានឃើញគេតែប៉ុណ្ណោះ បាទ។

[១០:២១:00]

**សះ** លោកបានឃើញរូងហ្នឹងនៅពេលណាដែរ លោកអាចជម្រាបបានទេ នៅពេលដែលកំពុងតែធ្វើការ ឬមួយក៏ក្រោយមកទេ? បានន័យថាក្រោយ៧៩ហើយ?

**ឆះ** ខ្ញុំបាទ សូមជម្រាបជូនអង្គតុលាការ។ ខ្ញុំបាទបានឃើញនេះ ជិតដល់ថ្ងៃនឹងរត់បែកបាក់គ្នាហើយបាទ។

**សះ** ចុះពីមុនមកលោកមានបានដឹងថា មានក្រុមការងារនៅផ្នែកធ្វើរូងភ្នំហ្នឹងដែរទេ?

**ឆះ** ខ្ញុំបាទសូមជម្រាបជូនកាលពីមុនមក ខ្ញុំបាទ ពុំដែលឃើញទេ បាទ។

**សះ** បាទ អរគុណ។ អំមិញលោកអាច -- លោកបញ្ជាក់អំពីពេលវេលាថា លោកឃើញជិតបែកភ្នំពេញទៅហើយហ្នឹង រយៈពេលប៉ុន្មានថ្ងៃដែរ អាចៗបញ្ជាក់ពីពេលវេលាជាក់លាក់បានទេ?

**ឆះ** ត្រង់ចំណុចនេះ ខ្ញុំបាទសូមបញ្ជាក់ជូនអង្គតុលាការ ខ្ញុំបាទបានឃើញរូងភ្នំនេះ គឺថ្ងៃ០៧ មករា ព្រោះនៅពេលនោះ គឺមានអ្នកខ្សឹមខ្សាវគ្នាថា អ៊ូ! មានយួនចូលនៅក្រុងភ្នំពេញហើយ។ ពេលនោះមេៗក៏អត់ប៊ិានបង្ខំយើងខ្ញុំឲ្យធ្វើការងារអី។ ដូច្នេះមានការជំនុំគ្នាពីរឿងអ្នកខ្លះថា ទៅផ្ទះ អ្នកខ្លះថា ទៅនេះទៅនោះ បាទ។

**លោក គង់ សំអុនះ**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកសាក្សី។

**ប្រធានអង្គជំនុំះ**

បាទ ដល់ពេលនេះ សវនាការស្តាប់សក្ខីកម្មសាក្សី កែវ លឿ បានចប់ហើយ ហើយសវនាការជាបន្តនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-830 ដែលជាសាក្សីទាក់ទងទៅនឹងអង្គហេតុការដ្ឋានទំនប់ ១មករា សូមភាគី និងសាធារណជនជ្រាប។

អង្គជំនុំជម្រះអរគុណលោក កែវ លឿ ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សីក្នុងរយៈពេល២.៥ថ្ងៃកន្លងមកនេះ ហើយសក្ខីកម្មរបស់លោកហ្នឹងរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ ហើយការផ្តល់សក្ខីកម្មរបស់លោកដល់ពេលនេះបានដល់ទីបញ្ចប់ហើយ ហើយលោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកជួបតែសំណាងល្អ មានសេចក្តីសុខ សេចក្តីចម្រើន និងធ្វើដំណើរត្រឡប់ទៅវិញ ប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពសាក្សី និង អ្នកជំនាញ ក្នុងការជូនលោកសាក្សី លោក កែវ លឿ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ និងសែសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២៤ នាទី ដល់ម៉ោង ១០:៤១ នាទី)*

[១០:៤១:១២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការតទៅនេះ សម្រាប់ថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មដែលមានរហស្សនាម 2-TCW-830 ដែលជាសាក្សីទាក់ទងទៅនឹងអង្គហេតុការដ្ឋានទំនប់១មករា។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី រួមទាំងមេធាវីប្រឹក្សាសាក្សី មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១០:៤៣:៣៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី តើលោកឈ្មោះអី?

**លោក យាន លន់៖**

**ឆ៖** ឈ្មោះ យាន លន់។

**ស៖** អរគុណលោក យាន លន់។ តើលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំទេ?

**ឆ៖** អត់ចាំទេ។

**ស៖** ឆ្នាំនេះ លោកមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** ៧៣។

**ស៖** អរគុណលោក យាន លន់។ តើលោកចាំកន្លែងកំណើតរបស់លោកទេ លោកកើតនៅទីកន្លែងណា?

**ឆ៖** នៅភូមិខ្វែក ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ។

**ស៖** បាទ អរគុណ។ ចុះទីលំនៅបច្ចុប្បន្នរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** ភូមិខ្វែក ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ។

**ស៖** បាទ អរគុណ។ ហើយឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកគាត់ឈ្មោះអី?

[១០:៤៥:០៩]

**ឆ៖** ឈ្មោះ -- ឪពុកបង្កើតឈ្មោះ យាន លន់។ ម្ដាយឈ្មោះ ចេង – ប៉ែន ចេង។

**ស៖** ម៉េចបានជាឪពុកលោក ជាមួយនឹងឈ្មោះលោកដូចគ្នា យាន លន់?

**ឆ៖** ឈ្មោះ យាន – ប៊ុន យាន។

**ស៖** បាទ អរគុណ។ ហើយប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ឈុំ ឆេង។ កូនអត់មាន។

**ស៖** បាទ អរគុណលោក យាន លន់។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញថា តាមសមត្ថភាពដែលលោកអាចដឹង គឺថា លោកមិនមានជាប់ញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និង លោក ខៀវ សំផន និងបុគ្គលទាំងឡាយដែលត្រូវបានទទួលយកដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំនុំរឿង០០២ នេះទេ។ តើពិតមែនដែរទេ?

**ឆ៖** អត់មានជាប់។

**ស៖** ហើយថា លោកបានស្បថរួចហើយ មុខអ្នកតាដំបងដែកនៅខាងកើតសាលសវនាការនេះ មុននឹងកាល -- មុនពេលដែលលោកចូលមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ។ តើពិតមែនទេ?

**ឆ៖** ស្បថហើយពីម្សិលមិញ ស្បថរួចហើយ។

**ស៖** តទៅនេះយើងប្រាប់អំពីសិទ្ធិ និង ករណីយកិច្ចក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ លោក យាន លន់ ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធី ចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឲ្យលោកធ្វើអត្ថាធិប្បាយណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថាដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះ នាំឲ្យលោកនឹងទទួលការចោទប្រកាន់។ អំពីករណីយកិច្ច លោក យាន លន់ ក្នុងឋានៈលោកជាសាក្សី លោកត្រូវតែឆ្លើយតបទៅរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោកដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯងដូចយើបានប្រាប់អំពីសិទ្ធរបស់សាក្សីរួចហើយអម្បាញ់មិញនេះ។ ក្នុងឋានៈជាសាក្សីលោកត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិតដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬធ្វើបានធ្វើការសង្កេតដោយផ្ទាល់នៅព្រឹត្តិហេតុ និងហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាភី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

លោក យាន លន់ តើលោកធ្លាប់បានផ្ដល់សក្ខីកម្ម ឬផ្ដល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងពេលកន្លងមក? ហើយប្រសិនធ្វើ ធ្វើប៉ុន្មានដង? ធ្វើនៅទីកន្លែងណា? នៅពេលណា? លោកចាំដែរឬទេ?

**ឆ៖** ខ្ញុំបានធ្វើហើយជាមួយ សាក្សី -- អ៎! ជាមួយអង្គ --។

**ស៖** កន្លងមកបានផ្ដល់សក្ខីកម្មជាមួយអ្នកស៊ើបអង្កេតដែរទេ ពីប៉ុន្មានឆ្នាំកន្លងមក? លោកចាំទេ ថាលោកផ្ដល់សក្ខីកម្ម ឬក៏កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតដែរទេ?

[១០:៤៨:៥៦]

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** កុំអាល់ឆ្លើយតប! ពីពេលកន្លងមក អាចជាច្រើនឆ្នាំកន្លងមកហើយ តើលោកធ្លាប់បានផ្ដល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតអំពីរឿងរ៉ាវពាក់ព័ន្ធនឹងរឿងក្ដី ដែលដំណើរការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងដែរទេ?

**ឆ៖** អត់ដែលបានមើលទេ។

**ស៖** យើងមិនសួរថាមើលទេ ថាតើលោកបានដែលបានផ្ដល់សក្ខីកម្មនៅចំពោះមុខជាមួយនឹង

អ្នកស៊ើបអង្កេតដែលគេទៅសាកសួរឬ ឬក៏កោះហៅលោកមកសាកសួរអំពីរឿងហេតុទាំងឡាយដែលកើតឡើងជាមួយនឹងទំនប់ ១មករា ដែរទេ កន្លងមក?

**ឆ៖** បាទ មានបាទ។

**ស៖** អរគុណ ហើយលោកផ្តល់សក្ខីកម្មប៉ុន្មានដង ផ្តល់កិច្ចសម្ភាសន៍ហ្នឹង ជាមួយអ្នកស៊ើបអង្កេតហ្នឹងប៉ុន្មានដង? ហើយធ្វើនៅកន្លែងណាលោកចាំទេ?

**ឆ៖** បាទ នៅ ដែលទៅស៊ើបអង្កេតនៅភូមិខ្វែកហ្នឹង។

**ស៖** ហើយមុននឹងចូលមកដល់អង្គជំនុំជម្រះនៅពេលនេះ តើលោកបានពិនិត្យ ឬអាន បានអាននូវកំណត់ហេតុដែលលោកបានផ្តល់ចម្លើយជាមួយអ្នកស៊ើបអង្កេតកាលពីពេលមុននៅភូមិខ្វែកហ្នឹងដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បានអានតិចៗ ប៉ុន្តែខ្ញុំវាអត់ចេះអក្សរច្រើនទេ តិចៗ អានមិនរួចទេ តិតក់ៗ។

**ស៖** មានបានស្តាប់ការអានពីអ្នកណាម្នាក់ដែរឬទេ?

**ឆ៖** បានស្តាប់បាទ។

[១០:៥២:០២]

**ស៖** ហើយតាមសមត្ថភាពតាមដែលលោកអាចដឹង និង ចងចាំ ថាតើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុស្តាប់ចម្លើយដែលលោកបានស្តាប់ការអាន ដើម្បីរំឭកការចងចាំ គឺពិតជាត្រឹមត្រូវសមស្របស៊ីចង្វាក់គ្នា ទៅនឹងចម្លើយដែលលោកបានធ្វើកិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីមុន នៅភូមិខ្វែកនោះដែរឬទេ?

**ឆ៖** បាទ ចងចាំខ្លះ មិនចងចាំខ្លះ។

**ស៖** លោក យាន លន់ នៅពេលនេះអង្គជំនុំជម្រះបាន -- លោកបានទទួលជំនួយមេធាវីប្រឹក្សាដែលអង្គជំនុំជម្រះបានផ្តល់ឲ្យតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញតាមសំណើរសុំរបស់លោក គឺលោកមេធាវី មឿង សុវណ្ណ។ សំណួរសួរថា តើលោកបានប្រឹក្សាយោបល់ជាមួយនឹងមេធាវីរបស់លោករួចហើយឬនៅ មុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនេះ?

**ឆ៖** ខ្ញុំបានជំនុំជម្រះរួចហើយ ជាមួយមេធាវី។

**ស៖** បាន ពិគ្រោះៗ ពិភាក្សាជាមួយនឹងមេធាវី ឬក៏បានជំនុំជម្រះ?

**ឆ៖** បាន ពិភាក្សារួចហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី យាន លន់ មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសូមបញ្ជាក់ថា ភាគីសហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានពេលពីរវគ្គ នៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះ។ ហើយនៅព្រឹកនេះ អង្គជំនុំជម្រះបន្ថែមម៉ោងឲ្យ១០នាទី បានន័យថា រហូតដល់ម៉ោងដប់មួយ និងសែសិបនាទីទើបសម្រាក។

អញ្ជើញបាទ!

[១០:៥៩:០៨]

**លោក សេង លាង៖**

អរគុណលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម អស់លោក លោកស្រីទាំងអស់ដែលមានវត្តមាននៅក្នុងសាលសវនាការនៅពេលនេះ។

សូមគោរពលោក -- សូមជម្រាបសួរលោកសាក្សី ខ្ញុំបាទឈ្មោះ សេង លាង ជាសហព្រះរាជអាជ្ញារងជាតិនៃការិយាល័យសហព្រះរាជអាជ្ញា។ ថ្ងៃនេះ ខ្ញុំមានសំណួរមួយចំនួនចង់ចោទសួរទៅកាន់លោកសាក្សីឲ្យជួយបំភ្លឺដល់អង្គសវនាការពាក់ព័ន្ធនឹងការងារមួយចំនួននៅទំនប់ ១មករា។ ហើយបន្ទាប់មកសហការីរបស់ខ្ញុំនឹងមានសំណួរមួយចំនួននឹងចោទសួរទៅលោកផងដែរ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង លាង៖**

**ស៖** ដំបូង ខ្ញុំសូមលើកយកកិច្ចសម្ភាសន៍មួយរបស់លោកនៅក្នុងឯកសារ D166/156 ត្រង់ ERN ជាភាសាខ្មែរ 00321787 រហូតដល់ 88, និង ERN ជាភាសាអង់គ្លេស 00330720, ERN ជាភាសាបារាំង 00402983។ នៅក្នុងនោះលោកបានលើកឡើងថា លោកត្រូវបានគេចាត់តាំងឲ្យរែកដីនៅការដ្ឋានសង់ទំនប់ ១មករា អស់រយៈពេលបីខែ។ ខ្ញុំចង់ឲ្យលោកជួយបញ្ជាក់ថា តើលោកធ្វើការនៅកន្លែងណាឲ្យពិតប្រាកដនៅការដ្ឋានទំនប់១មករាហ្នឹង ហើយសូមបញ្ជាក់ប្រាប់បន្តិចអំពីភូមិ និងឃុំ និងផ្នែកណាមួយនៃការដ្ឋានសាងសង់ដែលលោកធ្វើការនោះ?

**លោក យាន លន់៖**

**ឆ៖** នៅនឹងទំនប់ ១មករា កន្លែងធ្វើការរែកដី។

**ស៖** តើស្ថិតនៅក្នុងភូមិ ឃុំណាដែរ លោកអាចបញ្ជាក់ប្រាប់បានទេ?

**ឆ៖** នៅតំបន់ភូមិស្មោ ឃុំកំពង់ថ្ម។

**ស៖** បាទ អរគុណច្រើនលោកសាក្សី។ តើអ្នកណាគេជាអ្នកចាត់តាំងឲ្យលោកទៅធ្វើការនៅទំនប់១មករាហ្នឹង? ហើយលោកធ្វើការនៅក្នុងកងអ្វីដែរ លោកអាចបញ្ជាក់បានទេ?

**ឆ៖** ប្រធានភូមិចាត់តាំងឲ្យទៅរែកដី។

**ស៖** ប្រធានភូមិឈ្មោះអី ហើយកងដែលលោកទៅធ្វើហ្នឹង ធ្វើនៅក្នុងកងអីដែរលោក?

[១០:៥៧:៤៤]

**ឆ៖** ប្រធានភូមិឈ្មោះ លី។

**ស៖** លោកធ្វើការនៅក្នុងកងអីដែរលោក អាចប្រាប់បានទេ?

**ឆ៖** កង១ចល័តបុរស១ នារី១។

**ស៖** លោកចង់បញ្ជាក់ថាកងចល័តបុរស ឬក៏កងចល័តនារី ដែលលោកធ្វើការនៅក្នុងនោះឲ្យច្បាស់មើលលោក?

**ប្រធានអង្គជំនុំ៖**

កុំអាលឆ្លើយតប រង់ចាំក្បាលមេក្រូហ្វូនប្រតិបត្តិការដោយឲ្យសញ្ញាភ្លើងក្រហមសិនណា។

**លោក យាន លន់៖**

**ឆ៖** បុរស និងនារី ក៏មានដែរ កងចល័តនោះ កងរែកដី ចម្រុះច្រើនណាស់។

**សួរដោយលោក សេង លាង៖**

**ស៖** តើលោកអាចប្រាប់បានទេនៅក្នុងកងរបស់លោកហ្នឹងមានមនុស្សប៉ុន្មាននាក់ដែរ?

**ឆ៖** ច្រើនណាស់ក្នុងកងរែកដីហ្នឹង ច្រើនមនុស្ស វារាប់រយនាក់។

**ស៖** តើលោកមានស្គាល់ឈ្មោះខ្លះដែរទេ លោកអាចប្រាប់បានទេ បើសិនជាលោកស្គាល់?

**ឆ៖** តំបន់ការដ្ឋានហ្នឹង ប្រធានមានឈ្មោះ កែ ពក។

**ស៖** ខ្ញុំចង់សួរអំពីកងរបស់លោកទេ ខ្ញុំអត់ចង់សួរអំពីប្រធានការដ្ឋានទាំងមូលទេ។ កងដែលលោកធ្វើការនៅក្នុងហ្នឹង តើលោកថា លោកធ្វើនៅក្នុងកងបុរស និងកងនារីហ្នឹង តើលោកមានស្គាល់

សមាជិកកងហ្នឹងខ្លះដែរឬទេ? អាចប្រាប់ឈ្មោះបានទេ ប្រសិនបើមានចាំ?

**ឆ៖** មិនចាំទេ បាទ។

**ស៖** តើមនុស្សដែលធ្វើការនៅក្នុងកងរបស់លោកហ្នឹង មកពីភូមិតែមួយជាមួយលោក ឬក៏មកពីភូមិផ្សេងទៀត ខុសគ្នា? អាចបញ្ជាក់បានទេ?

**ឆ៖** ចម្រុះច្រើនមួយស្រុកសន្ទុកហ្នឹង។ មនុស្សមួយស្រុកសន្ទុក ធ្វើទំនប់ហ្នឹងគឺមួយស្រុកសន្ទុកតែម្តង គឺច្រើនណាស់។ រាប់ភូមិមិនអស់ទេ។

**ស៖** លោកប្រាប់បានទេ អ្នកណាគេជាប្រធានកងរបស់លោក?

**ឆ៖** ប្រធានកង ឈ្មោះ យី។

**ស៖** លោកអម្បាញ់មិញនិយាយអំពីស្រុកសន្ទុកទាំងមូល តែខ្ញុំចង់សំដៅទៅលើកងរបស់លោក តើកងរបស់លោកមានមនុស្សប្រហែលប៉ុន្មាននាក់ដែរ អាចបញ្ជាក់ម្តងទៀតបានទេ?

**ឆ៖** ក្នុងមួយកងៗមាន ៣២, ៣៣ មួយកង។

**ស៖** តើមនុស្សក្នុងកងហ្នឹង គាត់មកពីភូមិតែមួយ ឬក៏ភូមិខុសគ្នាអាចបញ្ជាក់ម្តងទៀតបានទេ?

**ឆ៖** ចម្រុះភូមិ។

**ស៖** អរគុណលោក។ តើលោកចាំបានទេ នៅថ្ងៃណា ខែណា ឆ្នាំណាដែលលោកមកធ្វើការនៅទំនប់ ១មករា ហ្នឹង?

[១១:០៣:១៩]

**ឆ៖** ភ្លេច អត់ចាំ។

**ស៖** អរគុណលោក។ ភស្តុតាងកន្លងមកនៅក្នុងតុលាការហ្នឹង បានបង្ហាញថា ការសាងសង់ទំនប់ ១មករា ហ្នឹង ចាប់ផ្តើមនៅក្នុងខែធ្នូ ឆ្នាំ១៩៧៦ និងបញ្ចប់នៅចុងឆ្នាំ១៩៧៧។ អ្វីដែលខ្ញុំលើកឡើងនេះ តើអាចរំឭកការចងចាំរបស់លោកអំពីការងារដែលលោកធ្វើនៅការដ្ឋានទំនប់ ១មករា បានដែរឬទេ? តើលោកអាចចាំបានទេ?

**ឆ៖** គឺធ្វើការក្នុងនោះ គឺដែលធ្វើការនៅទំនប់ ១មករា នោះគឺ ធ្វើការនោះដោយគ្មានពេលឈប់ពេលឈរទេ គឺធ្វើទាំងយប់ ធ្វើទាំងថ្ងៃហ្នឹងឯង រែកដីហ្នឹង ទាំងខ្ញុំទាំងគេហ្នឹងរែក ម្ល៉ោះហើយពេលធ្វើហ្នឹងគឺវា វេទនាណាស់ វេទនាមែនទែន។ បានថា ក្នុងនោះគឺក្នុងរបបនោះ គឺប្រជាពលរដ្ឋដែលនៅធ្វើទំនប់ ១មករា ហ្នឹងគឺដោយវេទនា ហើយរងកម្មខ្លាំងទៀត។

**ស៖** អរគុណលោក តើលោកចាំបានទេ ពេលហ្នឹងដែលលោកធ្វើការហ្នឹងក្នុងរដូវប្រាំង ឬក្នុងរដូវវស្សា? អាចចាំអត់?

**ឆ៖** រដូវប្រាំង បាទ។

**ស៖** លោកនៅចាំបានទេ នៅពេលដែលគេចាត់ឲ្យលោកទៅធ្វើការហ្នឹង ភ្លាមក្រោយបែក ប៉ុល ពត ឬក៏ចុងរបប ប៉ុល ពត លោកអាចបញ្ជាក់ ឬក៏ពាក់កណ្ដាលរបបនុំង លោកអាចបញ្ជាក់បានទេ?

**ឆ៖** ខ្ញុំចាំថា មកពាក់កណ្ដាលហើយ បាទធ្វើហ្នឹងជិតមកពាក់កណ្ដាលហើយ។

**ស៖** ឥឡូវបែរមកការងារម្ដង តើលោកអាចពិពណ៌នាប្រាប់តុលាការបានទេ អំពីការងារដែលគេតម្រូវឲ្យលោកធ្វើនៅការដ្ឋាន ១មករា ហ្នឹងក្នុងមួយថ្ងៃគេឲ្យលោកធ្វើប៉ុន្មានដែរ?

**ឆ៖** អត់យល់ទេ សូមបញ្ជាក់។

[១១:០៦:២៨]

**ស៖** លោកបានលើកឡើងថា គេឲ្យលោកទៅធ្វើការងារនៅការដ្ឋានទំនប់ ១មករាហ្នឹង តើលោកអាចពិពណ៌នាអំពីការងារអ្វីខ្លះដែលគេឲ្យលោកធ្វើនៅពេលដែលលោកទៅធ្វើការងារនៅហ្នឹង? នៅទំនប់ ១មករា ហ្នឹងបានដែរឬទេ?

**ឆ៖** បាទ ព័ត៌មានដែលធ្វើពេលធ្វើទំនប់ ១មករា ហ្នឹង គឺជាដូចខ្ញុំលើកអំមិញ គឺពិសេសគឺគេចាត់តាំងឲ្យធ្វើហ្នឹងទាំងយប់ ទាំងថ្ងៃ ហើយម្យ៉ាងទៀត គឺមានបង្ខំឲ្យធ្វើ អត់មានម៉ោងមានវេលាអីទេ គឺធ្វើបង្ខំ គឺខ្លាំងតែម្ដង។

**ស៖** តើលោកអាចប្រាប់បានទេ ក្នុងមួយថ្ងៃគេតម្រូវឲ្យលោកជីកដី ឬកាប់ដី ឬក៏រែកដី ប្រហែលជាប៉ុន្មានដែរក្នុងមួយថ្ងៃ? ហើយផែនការគេដែលតម្រូវដាក់ហ្នឹង គេដាក់ប៉ុន្មានដែរ តម្រូវឲ្យមនុស្សម្នាក់ៗរែកហ្នឹង?

**ឆ៖** ក្នុងម្នាក់ៗបួនគូប បាទ។ ម្នាក់បួនគូប ឲ្យរួចមួយថ្ងៃហ្នឹង។ បួនគូបហ្នឹងឲ្យរួច ក្នុងមួយថ្ងៃ បើមិនបានបួនគូបទេ សុទ្ធតែរឿងហើយ។

**ស៖** រែក -- ជីក និងរែកដីបួនគូប។ តើលោកធ្វើដោយដៃផ្ទាល់ ឬក៏មានឧបករណ៍អីជួយលោកដែរ?

**ឆ៖** បាទ ជួយដោយចបកាប់ផ្ទាល់។ មានអីធំជាងចបកាប់ទេ ជំនាន់នោះ សំខាន់ណាស់។

[១១:០៨:២៩]

**ស៖** ក្រៅពីចបកាប់ តើមានគ្រឿងយន្តគ្រឿងអីជួយសម្រួលដែរឬទេ?

**ឆ៖** អត់មានទេ បាទ។

**ស៖** ជារៀងរាល់ថ្ងៃ តើគេត្រួតពិនិត្យយ៉ាងដូចម្ដេចទើបដឹងថា លោក ក៏ដូចជាសមាជិកកងនីមួយៗធ្វើគ្រប់តាមផែនការដែលគេតម្រូវឲ្យនោះ ជារៀងរាល់ថ្ងៃហ្នឹង? តើគេត្រួតពិត្យយ៉ាងដូចម្ដេច?

**ឆ៖** ប្រធានកងគេដើរត្រួតពិនិត្យមើលទៅ អាណាធ្វើបាន មិនបាន រួច មិនរួច គេឲ្យប្រឹង។ អ្នកណាធ្វើរួច អ្នកធ្វើមិនរួចឲ្យប្រឹងតាមហ្នឹង ឲ្យប្រឹងធ្វើតាមអ្នកដែលធ្វើបាន។

**ស៖** មានរឿងអ្វីកើតឡើងទេ ចំពោះអ្នកដែលនៅតែគេឲ្យប្រឹងធ្វើការហើយ ក៏ប៉ុន្តែនៅតែធ្វើមិនបាននោះ តើមានរឿងអីកើតឡើងចំពោះគាត់ដែរឬទេ?

**ឆ៖** បើធ្វើមិនបាន គឺគេដាក់ទារុណកម្មអី ឲ្យប្រឹងធ្វើទាល់តែបាន បាទ។ ម្ល៉ោះហើយ ប្រធានគេចេះតែគាបឲ្យប្រឹង ឲ្យជួយធ្វើហ្នឹង ទាល់តែកើត ទាល់តែរួច បង្ខំឲ្យធ្វើហ្នឹង។

**ស៖** តើលោកអាចប្រាប់បានទេ នៅការដ្ឋាន១មករាហ្នឹង គេតម្រូវឲ្យប្រជាជនធ្វើការចាប់ពីម៉ោងប៉ុន្មាន រហូតដល់ម៉ោងប៉ុន្មាន?

**ឆ៖** ធ្វើការចាប់ពីម៉ោងប្រាំព្រឹក ទល់ម៉ោងដប់មួយថ្ងៃ សម្រាកបាយ។

**ស៖** បន្តទៀត។

**ឆ៖** ម៉ោងប្រាំព្រឹក ទល់ម៉ោងដប់មួយ សម្រាកបាយ។

[១១:១១:១៧]

**ស៖** ចុះពេលថ្ងៃវិញ?

**ឆ៖** បាទ តាំងពីម៉ោងប្រាំព្រឹក ទល់ម៉ោងដប់មួយថ្ងៃ។

**ស៖** ខ្ញុំចង់សំដៅចាប់ពីក្រោយម៉ោងដប់មួយព្រឹក រហូតដល់ល្ងាច ឬយប់ តើមានធ្វើការងារដែរឬទេ?

**ឆ៖** ពេលព្រឹកអត់មានទេ -- អ៎! ចាប់ពីម៉ោងប្រាំព្រឹក ធ្វើទល់ថ្ងៃ -- អ៎! ម៉ោងដប់មួយថ្ងៃ។

**ស៖** លោកចង់និយាយថា ពេលរសៀល និងពេលយប់ អត់មានធ្វើការងារទេ ឬយ៉ាងម៉េច?

**ឆ៖** ដែលខ្ញុំនិយាយនេះ គឺពេលធ្វើការព្រឹក។ ពេលវេលាធ្វើការព្រឹក។ ព្រឹកធ្វើ ទល់ថ្ងៃ -- អ៎! ម៉ោងដប់មួយថ្ងៃ។ ហើយចាប់ពីហ្នឹងទៀត បាយរួច គឺចាប់ផ្ដើមធ្វើ ទាល់តែដល់ម៉ោងប្រាំពីរយប់។

**ស៖** ចុះពេលខ្លះ គេមានតម្រូវឲ្យកម្មករធ្វើការនៅពេលយប់ដែរឬទេ បើសិន--

**ឆ៖** ធ្វើយប់ ក៏ធ្វើ បាទ។ អ្នកធ្វើហ្នឹង ទាំងយប់ទាំងថ្ងៃហ្នឹង ធ្វើ បាទ។

**ស៖** ពេលយប់ធ្វើការរហូតដល់ម៉ោងប៉ុន្មានដែរ?

**ឆ៖** ពេលយប់ធ្វើការដល់ម៉ោងដប់ ដប់យប់ បាទ។

**ស៖** តើកម្មករដែលធ្វើការនៅពេលយប់នោះ គាត់ស្នាក់នៅកន្លែងណាដែរ លោកអាចប្រាប់បានទេ?

**ឆ៖** បាទ ធ្វើរោងតាមទំនប់តាមប្រឡាយហ្នឹង ធ្វើរោងស្នាក់នៅតាមហ្នឹង។ ស្នាក់តាមទំនប់ប្រឡាយហ្នឹង។

**ស៖** លោកអាចពិពណ៌នាបន្តិចបានទេ អំពីស្ថានភាពរោងហ្នឹង តើវាយ៉ាងម៉េច វាមានគ្រែ មានអី ឬក៏មានអីបិទបាំងអី ដំបូលអីជិតដែរ ឬក៏យ៉ាងម៉េច?

[១១:១៤:៣៣]

**ឆ៖** អានេះ ដែលបានខ្ញុំធ្វើផ្ទាល់ខ្លួនខ្ញុំ គឺដែលនៅចុះជាប់ជាមួយកម្មករទាំងអស់គ្នាធ្វើហ្នឹង គ្មានអីទេ មានតែដីហ្នងផ្ទាល់តែម្តង ស្ទើរតែគ្មានកន្ទេលទៅទៀត។ អត់មានទេកន្ទេល រឿងគ្មានហ្នង។ ក្រាលតែស្លឹកឈើអីចឹង កាច់ដេកអីចឹងទៅ អត់មានទេ។ អានេះរឿងខ្ញុំចុះផ្ទាល់ ឃើញ ខ្ញុំធ្វើខ្លួនខ្ញុំតែម្តង រឿងគ្មានកន្ទេលប៉ុន្មានទេ។ គ្នាអ្នកនេះទៅ ក៏បោសដីដេកអីចឹងតែម្តងទៅ។ អានេះខ្ញុំចុះជាប់ធ្វើតែម្តង ជាក់ស្តែងខ្ញុំ។ ខ្ញុំប្រឡូកខ្លាំងណាស់។

**ស៖** លោកចង់និយាយថា មិនមានគ្រែទេ ហើយកម្មករទាំងដេកនៅនឹងដី ហើយគ្មានកន្ទេល ហើយកាច់ស្លឹកឈើយកមកក្រាលដេក។ តើមានមុងដែរឬទេ?

**ឆ៖** គ្មានទេមុងបាទ គ្មានទេ។ និយាយរឿងមុង គឺចប់តែម្តង។

**ស៖** ចុះនៅពេលមានភ្លៀងនៅពេលយប់ ដែលលោកកំពុងសម្រាក ក៏ដូចជាកម្មករទាំងអស់កំពុងតែសម្រាកហ្នឹង តើគាត់ -- អ្នកដែលសម្រាកនៅក្នុងរោងនឹងទទឹកភ្លៀងដែរ ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទានអាលឆ្លើយតប។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំមិនជំទាស់ទេសំណួរនេះ គ្រាន់តែសូមធ្វើការកត់សម្គាល់។ សាក្សីបានបញ្ជាក់ថាគាត់ធ្វើការនៅខែប្រាំង អីចឹងសម្រាប់ខែប្រាំងនេះ ភ្លៀងវាហាក់ដូចជាពុំមែនជា

ចំណោទទេ ស្រុកខ្មែរ។ សូមអរគុណ។

**លោក សេង លាង៖**

អរគុណចំពោះការកត់សម្គាល់របស់លោកមេធាវី ប៉ុន្តែទោះបីនៅខែប្រាំង ឬខែវស្សា ជួនកាលក៏វាអាចមានភ្លៀងម្តងម្កាលដែរ។ ដូច្នេះ ខ្ញុំចង់សួរទៅលើអង្គហេតុដែលលោកសាក្សីជួបប្រទះថា តើបើសិនជាគាត់ដេកនៅក្នុងរោងហ្នឹង បើសិនជាមានភ្លៀង ពេលហ្នឹងតើវាទទឹកអត់។ បើសិនជាគាត់ដឹងគាត់អាចឆ្លើយ បើសិនជាគាត់អត់ដឹង រឿងខ្ញុំសួររឿងផ្សេងទៀត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយ!

**លោក យាន លន់៖**

**ឆ៖** ពេលនេះដែលពេល--

**សួរដោយលោក សេង លាង៖**

**ស៖** ខ្ញុំអាចសុំបញ្ជាក់សំណួរសាថ្មី ប្រសិនជាលោកមិនចាំ។ ខ្ញុំចង់សួរថា នៅក្នុងរោងប្រជាជន ឬក៏កម្មករដែរដេករោងហ្នឹង ពេលយប់ហ្នឹង ប្រសិនបើមានភ្លៀង តើទទឹកទឹកភ្លៀងឬក៏អត់?

**ឆ៖** អាខ្លះក៏មានដំបូល ខ្លះក៏ដំបូលរហែកអ៊ីចឹងទៅ។ ទទឹកហើយ បាទ។

[១១:១៨:០៥]

**ស៖** បើសិនជាទទឹកកម្មករទាំងអស់ហ្នឹង គាត់ធ្វើយ៉ាងម៉េចដែរ?

**ឆ៖** បាទ អត់ -- នៅតែកាប់ដី ភ្លៀងហើយក៏នៅតែកាប់ដី វាលែងរងាហើយដល់អ៊ីចឹងទៅ វាប្រឹងកាប់ កាប់អីទៅ វាលែង -- វាទៅជាវាបាត់រងាទៅ រែកដីខ្លាំងពេកទៅ។

**ស៖** ឥឡូវខ្ញុំចង់ឲ្យលោកបញ្ជាក់អំពីចំណីអាហារវិញ ដែលគេផ្តល់ឲ្យកម្មករនៅការដ្ឋានទំនប់ ១មករាហ្នឹងវិញ។ តើគេផ្តល់អាហារឲ្យលោកញ៉ាំក្នុងមួយថ្ងៃប៉ុន្មានពេលដែរ?

**ឆ៖** អាហារដែលញ៉ាំនោះ គ្មានទេ បបរ។ បបរ អត់មានបាយទេ។

**ស៖** គេឲ្យញ៉ាំមួយថ្ងៃប៉ុន្មានពេលដែរ លោកអាចប្រាប់បានទេ?

**ឆ៖** មួយថ្ងៃពីរពេល។

**ស៖** តើអាហារដែលគេប្រគល់ -- ដែលគេ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់!

លោកអត់ទាន់ឆ្លើយតបទេ។ លោកឆ្លើយតបនៅពេលក្បាលមីក្រូហ្វូន អត់ទាន់ប្រតិបត្តិការផង ស្មើនឹងអត់ឆ្លើយ ព្រោះប្រព័ន្ធសំឡេងរបស់លោកមិនទាន់ចូលទៅប្រព័ន្ធចែកចាយសំឡេងទាំងភាគីពាក់ព័ន្ធ អង្គជម្រះក៏ស្តាប់សំឡេងមិនបាន ហើយប្រព័ន្ធនៃការបកប្រែភាសាក៏ស្តាប់សំឡេងរបស់លោក និងបកប្រែទៅភាសាពីរទៀត គឺភាសាបារាំង និងភាសាអង់គ្លេស មិនបានទេ។

[១១:២០:០២]

**សួរដោយលោក សេង លាង៖**

**ស៖** សូមលោកបញ្ជាក់ម្តងទៀតមើលថាតើក្នុងមួយថ្ងៃគេឱ្យលោកញ៉ាំអាហារប៉ុន្មានពេលដែរ?

**ឆ៖** ញ៉ាំពីរពេល។

**ស៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

បើកក្បាលមីក្រូហ្វូន! បើកៗមីក្រូហ្វូន។

**លោក សេង លាង៖**

សុំទោសលោកប្រធាន ចុចហើយវាបិទវិញ។

**សួរដោយលោក សេង លាង៖**

**ស៖** សំណួររបស់ខ្ញុំគឺអ៊ីចេះ តើអាហារដែលគេឱ្យលោកហូបហ្នឹង គ្រប់គ្រាន់ដែរឬទេ ដើម្បីបំពេញការងារ តាមផែនការដែលតម្រូវឱ្យលោកធ្វើ ៤ម៉ែត្រគូបក្នុងមួយថ្ងៃនោះ?

**លោក យាន លន់៖**

**ឆ៖** បាទ មិនគ្រប់ទេ ម្ហូបអាហារនោះវា ណាស់ហើយ វាគ្មានសោះទៅហើយ។

**ស៖** តើនៅកន្លែងហ្នឹង គេមានផ្តល់ទឹកស្អាតឱ្យហូបដែរឬទេ? ឬក៏លោកទៅតែផឹកទឹកនៅកន្លែងណា?

**ឆ៖** ផឹកអណ្តូង អត់មានទឹកស្អាតទេ ផឹកអណ្តូង។

**ស៖** ដោយសារថាចំណីអាហារមិនគ្រប់គ្រាន់ តើមានអ្នកណាតវ៉ាដែរឬទេចំពោះការខ្វះខាតចំណីអាហារហ្នឹង?

**ឆ៖** គ្មានទេពីជំនាន់នោះ គ្មានពីណាតវ៉ាពីរឿងខ្វះខាតចំណីអាហារអី អត់មានដោះស្រាយទេ។ ប្រធានកងដោះស្រាយខ្លួនឯង។

**ស៖** តើប្រជាជនធ្វើការនៅទំនប់ ១មករាហ្នឹង មានជំងឺញឹកញាប់ដែរឬទេ?

**ឆ៖** មានឈឺៗច្រើនៗ ឈឺម៉្យាងទៀតក៏ឈឺល្មមចេះតែឲ្យទៅធ្វើទាំងឈឺហ្នឹងទៅ បាទ។ ធ្វើនោះធ្វើ មិនធម្មតាទេ ធ្វើទាំងឈឺ ធ្វើទាំងមិនឈឺហ្នឹងឯងបាទ។

[១១:២២:៥២]

**ស៖** បើសិនជាមានអ្នកជំងឺតើ នៅកន្លែងហ្នឹង គេមានផ្ដល់ការព្យាបាលដល់អ្នកជំងឺដែរឬទេ? បាទ ផ្ដល់ការព្យាបាល តើព្យាបាលយ៉ាងដូចម្ដេចដែរ?

**ឆ៖** មានពេទ្យដើរចាក់តាមរោងហ្នឹងឯង ពេទ្យដើរចាក់តាមរោងហ្នឹងបន្តិចបន្តួច កូនពេទ្យតូចៗបាទ។ ដើរចាក់តាមរោងតាមគ្រប់រោង អ៊ីចឹងទៅ ពេទ្យ។

**ស៖** មានថ្នាំពេទ្យគ្រប់គ្រាន់ដែរឬទេសម្រាប់ការព្យាបាលជំងឺ?

**ឆ៖** គ្មានទេថ្នាំពេទ្យនោះ គឺតិចណាស់ហូបមិនគ្រប់គ្រាន់ទេ ខ្វះខាតខ្លាំងណាស់ថ្នាំពេទ្យ។

**ស៖** នៅការដ្ឋានហ្នឹង តើនៅពេលដែលកម្មករទាំងអស់ហ្នឹង ចង់បត់ដៃបត់ជើងអី តើគេមានកន្លែងបត់ដៃបត់ជើង ត្រឹមត្រូវដែរឬទេ? ឬក៏ត្រូវទៅបត់ដៃបត់ជើងនៅកន្លែងណា?

**ឆ៖** គេធ្វើៗបង្គន់ តូចៗៗគ្រប់រោងហ្នឹងបាទ បង្គន់អនាម័យគ្រប់រោង តាមរោង បង្គន់រោង -- តូបអនាម័យហ្នឹង។

**ស៖** តើប្រជាជនទៅបត់ជើងនៅរោងបង្គន់អនាម័យហ្នឹង ឬក៏ទៅបត់ជើងនៅកន្លែងណាផ្សេងដូចជានៅក្នុងព្រៃអីជាដើម?

**ឆ៖** ខ្លះក៏ទៅក្នុងព្រៃ ខ្លះក៏គាត់តាមបង្គន់អ៊ីចឹង ខ្លះក៏តាមវាលស្រែអ៊ីចឹងទៅ។ វាកាលនោះវាគ្មានបង្គន់ គ្មានអីទេ គឺតាមវាលស្រែវាលអី ចេះតែបត់ទៅ គុម្ពោតព្រៃអីទៅ វាគ្មាននរណាយកចិត្តទុកដាក់ធ្វើបង្គន់អី ឲ្យបានដិតដល់ អត់ទេ។

**ស៖** តាមចម្លើយរបស់លោកៗអាចបញ្ជាក់បានទេ ថាតើមានបង្គន់ ឬក៏អត់? ហើយបើមានបង្គន់ តើបង្គន់ហ្នឹងមានស្ថានភាពរបៀបម៉េច ហើយមានចំនួនច្រើនដែរឬទេ?

**ឆ៖** បង្គន់ធ្វើដោយឈើតូចៗ បោះអ៊ីចេះទៅ រុំកន្ទេលអ៊ីចឹងទៅ បាំងបិទស្លឹកត្នោតអ៊ីចឹងទៅ។ អាហ្នឹងបង្គន់តាមរោងអ៊ីចឹង បាំងៗស្លឹកត្នោត ស្រាស់ៗស្លឹកឈើអីអ៊ីចឹងទៅ។

**សៈ** តើបង្គន់ហ្នឹងគ្រប់គ្រាន់ក្នុងការប្រើប្រាស់ដែរឬទេ?

**ធៈ** អត់គ្រប់ទេបាទ មិនគ្រប់ទេ អត់គ្រប់ទេ ខ្វះខាតច្រើនណាស់ បាទ តាមបង្គន់មួយៗគឺខ្វះខាត។

**សៈ** បាទ អ៊ីចឹង តើនៅការដ្ឋានហ្នឹង ពេលហ្នឹង តើមានសត្វរុយ ឬក៏សត្វល្អិតអីច្រើនដែរឬទេ?

**ធៈ** ភាគច្រើនៗមានពស់ខាំច្រើនណាស់ បាទ ពស់ខាំ ខ្ទួយ ក្អែបខាំ ពស់ ខាំច្រើន។

**សៈ** ខ្ញុំចង់បញ្ជាក់ថា តើមានៗសត្វរុយដែរឬទេ ពេលហ្នឹង មានសត្វរុយច្រើនដែរឬទេ?

**ធៈ** បើនិយាយពីរុយវិញ វាហួសនិយាយតែម្តង គឺខ្មៅទ្រុបលើបាយ លើសម្លហ្នឹងបាទ រុយធំជាងគេ ច្រើនជាងគេទៀតរុយ ហើយឈឺនោះ ក៏ឈឺដោយសារដែររុយវាទំបាយ ទំអី ទំសម្ល ទំអីហ្នឹងឯង បាទដែលឈឺទៅជាឈឺ។ ដែលមានកើតអាសន្នរោគ រាករូសក្នុងកន្លែងហ្នឹង ច្រើនណាស់បាទ។

[១១:២៨:១៣]

**សៈ** តើគេមានចាត់វិធានការអ្វីក្នុងការប្រឆាំងជាមួយនឹងសត្វរុយ និងសត្វល្អិតទាំងហ្នឹងដែរឬទេ?

**ធៈ** អត់មានទេបាទ គ្មានទេ គ្មានប្រឆាំងនឹងរុយ គឺអត់មានពីណាប្រឆាំងឲ្យស្លាប់រុយ គឺអត់ៗមាន។

**សៈ** តើលោកមានដឹងទេ ថាតើមានប្រជាជនណាម្នាក់ដែលស្លាប់ដោយសារជំងឺ ដោយសារការអត់ឃ្លាន ឬក៏ដោយធ្វើការហួសកម្លាំងនៅការដ្ឋានទំនប់១មករាហ្នឹង លោកមានធ្លាប់ដឹងដែរឬទេ?

**ធៈ** ការស្លាប់នោះគឺគ្មានទេ បើឈឺច្រើនបាទ បើស្លាប់អត់ដឹងទេ ខ្ញុំអត់ដឹងទេ គឺបើឈឺច្រើនភាគច្រើនឈឺ ប៉ុន្តែស្លាប់ មិនទាន់ឃើញថាស្លាប់ទេ ពេលដែលឈឺនោះ គេយកទៅមន្ទីរពេទ្យអីទៅឆ្ងាយៗបាទ។

**សៈ** លោកចង់និយាយថា អត់មានអ្នកស្លាប់ ឬក៏លោកអត់ដឹងថាមានអ្នកស្លាប់?

**ធៈ** ដែលឈឺៗហើយ ប៉ុនគ្មានស្លាប់ទេក្នុងនោះ ឈឺៗហើយក្នុងតំបន់ដែលធ្វើការហ្នឹង គឺឈឺហើយ។

[១១:៣០:០២]

**សៈ** ចុះតើលោកមានដឹងថា មានកម្មករណាម្នាក់ដែលស្លាប់ដោយសារថាគ្រោះថ្នាក់ ដូចជាដីបាក់អីជាដើម ដីបាក់សង្កត់អីជាដើម ដែលមានដឹងទេ?

**ឆ៖** អត់ដឹងទេ បាទ ព្រោះគ្មាន។

**ស៖** ឥឡូវខ្ញុំ ចូលទៅកាន់ប្រធានបទមួយទៀតស្តីអំពីទស្សនកិច្ចរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យទៅកាន់ការដ្ឋានការងារទំនប់ ១មករា ហ្នឹង។ តើលោកមាននៅចាំបានទេថា តើមានមេដឹកនាំខ្មែរក្រហមមកទស្សនកិច្ចនៅទំនប់ ១មករា ហ្នឹងដែរទេ?

**ឆ៖** ស្គាល់តែ កែ ពក។ កែ ពក, ចន ដែលដឹកនាំទំនប់ ហ្នឹងធ្វើទំនប់ហ្នឹង។ មេការដ្ឋានហ្នឹង។

**ស៖** ក្រៅពីពីរនាក់ ហ្នឹង តើមានមេដឹកនាំជាន់ខ្ពស់ណាផ្សេងទៀតដែលទៅដែរទេ?

**ឆ៖** មេដឹកនាំជាន់ខ្ពស់ទៀតដូច ខៀវ សំផន អីក៏ខ្ញុំមិនច្បាស់ទេ បាទ មិនច្បាស់ទេ។

**ប្រធានអង្គជំនុំ៖**

បើក១ ក្បាលមីក្រូហ្វូន។

**លោក សេង លាង៖**

ចេះតែចុច ហើយចេះតែដាច់វិញ លោកប្រធាន មិនដឹងយ៉ាងម៉េច។

**សួរដោយលោក សេង លាង៖**

**ស៖** ក្រៅពី -- លោកបានមានប្រសាសន៍ថា ចន និង កែ ពក ហ្នឹង ធ្លាប់ទៅមើលទំនប់ហ្នឹង។ តើគាត់ទៅពេលណាដែរ ហើយជាមួយអ្នកណាខ្លះ?

**ឆ៖** ទៅក្នុងពេលបើកការដ្ឋាន ក្នុងមួយថ្ងៃហ្នឹង។ ក្នុងពីរម៉ោង បីម៉ោង អត់ទៅរាប់ថ្ងៃទេ គ្រាន់តែទៅបើកការដ្ឋានថ្ងៃហ្នឹង គេទៅវិញអស់។

**ស៖** បើកការដ្ឋានហ្នឹងនៅឆ្នាំណាដែរ លោកចាំទេ?

**ឆ៖** ខ្ញុំអត់ចាំទេ ខ្ញុំភ្លេចហើយបាទ។

[១១:៣៣:២៤]

**ស៖** នៅក្នុងកិច្ចសម្ភាសន៍មួយរបស់លោកជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ D166/156 ត្រង់ ERN ជាភាសាខ្មែរ 00321788, ERN ជាភាសាអង់គ្លេស 00330720, ERN ជាភាសាបារាំង 00402983។ លោកបានលើកឡើងថា ខ្ញុំសូមដកស្រង់៖ "ខ្ញុំបានឃើញ ចន និង ខៀវ សំផន ទៅមើលការដ្ឋានទំនប់ ១មករា ផងដែរ។ ក្រោយពេលដែល ខៀវ សំផន មកពិនិត្យមើលការដ្ឋាននោះ ខ្ញុំបានឃើញគាត់ស្ថិតនៅចម្ងាយប្រហែល ២០ម៉ែត្រពីខ្ញុំ។ ខ្ញុំមិនចាំថា គាត់មកពិនិត្យការដ្ឋាននៅឆ្នាំណាទេ។ ប៉ុន្តែខ្ញុំគិតថា បានឃើញគាត់នៅឆ្នាំ១៩៧៨។ ខ្ញុំស្គាល់គាត់ជា ខៀវ សំផន

ដោយសារអ្នកដទៃទៀតនៅការដ្ឋានប្រាប់ខ្ញុំថាជា ខៀវ សំផន។ មានមនុស្សជាច្រើនដើរហែហមគាត់ ហើយខ្ញុំបានឮគាត់និយាយតាមមីក្រូបញ្ជាឈ្លបឲ្យបញ្ជាប្រជាជនធ្វើការឲ្យបានលឿន និងយ៉ាងប្រញាប់ប្រញាល់បំផុត"។ លោកបាននិយាយថា លោកស្ថិតនៅចម្ងាយ២០ម៉ែត្រពីលោក ខៀវ សំផន នៅពេលដែលគាត់មកទស្សនកិច្ចទំនប់ ១មករា ហ្នឹង តើលោកអាចពិពណ៌នាបានទេថា នៅទីណានៃការដ្ឋានទំនប់ ១មករា ដែលលោកឃើញ ខៀវ សំផន នុ៎ង?

**ផ៖** ខ្ញុំឮតែគេថា ផ្ទាល់ៗដែរ ខ្ញុំវាអត់បានឃើញផ្ទាល់នឹងភ្នែកខ្លួនឯង។ វាមិនស្គាល់ មិនច្បាស់ដែរ។

[១១:៣៦:០៨]

**ស៖** នៅក្នុងកំណត់ហេតុហ្នឹងលោកបានឆ្លើយថា លោកនៅប្រវែង ២០ម៉ែត្រពី ខៀវ សំផន។ តើលោកឆ្លើយតបយ៉ាងម៉េចដែរ ចំពោះ--?

**ផ៖** ពីកាលនោះ គឺខ្ញុំមិនស្គាល់បាទ។ មិនស្គាល់ ឮគេថា ក៏ចេះតែថាតគ្នាទៅបាទ។ លោក ខៀវ សំផន ហ្នឹង។ ឮតែគេនិយាយតៗគ្នាណ៎ា មិនដឹងអីណា ខៀវ សំផន អីណាអី?

**ស៖** លោកនិយាយថា គាត់និយាយតាមមីក្រូបញ្ជាឈ្លប ឲ្យបញ្ជាប្រជាជនឲ្យធ្វើការឲ្យបានលឿន និងឆាប់បំផុត។ តើគាត់និយាយជាមួយនឹងមីក្រូហ្វូន ឬក៏និយាយជាមួយនឹងប្រដាប់បំពងសំឡេង តើលោកអាចប្រាប់បានទេ?

**ផ៖** វាអត់ច្បាស់ទេ បាទៗ វាអត់ច្បាស់ថា មិនដឹងជាស្អី ហើយដីវាហុយក៏ហុយខ្លាំងរកមើលមនុស្សមិនឃើញទេ មិនដឹងជា--។

**ស៖** លោកបាននិយាយថា គាត់បញ្ជាតាមមីក្រូ និយាយតាមមីក្រូបញ្ជាឈ្លប ឲ្យបញ្ជាប្រជាជន។ តើគាត់និយាយតែជាមួយឈ្លបទេ ឬក៏និយាយជាមួយប្រជាជនដែរ?

**ផ៖** អាត្រង់ហ្នឹងឯង គឺអត់ច្បាស់ទេ។ ខ្ញុំមិនច្បាស់បាទ។

**ស៖** នៅពេលដែលលោកកំពុងធ្វើការនៅទីនោះ ហើយ ខៀវ សំផន បានទៅទស្សនកិច្ចនៅទីនោះ តើគេមានប្រាប់ឲ្យកម្មករទាំងអស់ឈប់សម្រាកទៅទទួលរាក់ទាក់ ខៀវ សំផន ឬក៏កម្មករធ្វើការជាធម្មតា?

[១១:៣៨:៣៧]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរចុងក្រោយរបស់តំណាងសហព្រះរាជអាជ្ញារងជាតិ ដោយការសង្ខេបរបស់លោកមិនត្រឹមត្រូវទៅលើអង្គហេតុ ដែលសក្ខីកម្មសាក្សីនេះបានរៀបរាប់ទេ។ ព្រោះសាក្សីនេះ មិនបានបញ្ជាក់ថា ឃើញលោក ខៀវ សំផន មកចូលរួមនៅក្នុងការដ្ឋាននោះ។ គាត់ឮគេថា ដូច្នេះ ត្រូវប្រើពាក្យនេះឲ្យច្បាស់។ បាទ សូមអរគុណ។

[១១:៣៩:១៥]

**លោក សេង លាង៖**

លោកប្រធាន ដោយសារថាកំណត់ហេតុនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ច្បាស់ ដោយសាក្សីថា គាត់បានឃើញ ខៀវ សំផន នៅពេលនោះ ហើយមានចមម្ងាយតែ ២០ម៉ែត្រ ហើយនៅពេលនេះ គាត់បានឆ្លើយថាគាត់មិនបានឃើញ។ ដូច្នេះ ខ្ញុំកំពុងតែធ្វើការដេញដោលដើម្បីរកឲ្យឃើញការពិត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**សួរដោយលោក សេង លាង៖**

**ស៖** និយាយថា គេប្រាប់លោកថា ជាខៀវ សំផន។ តើលោក ជា ខៀវ សំផន ពិតមែន ឬក៏យ៉ាងម៉េច?

**លោក យាន លន់៖**

**ឆ៖** បើតាមខ្ញុំយល់មើលទៅ ពិនិត្យមើលទៅដឹងទៅថាមិនមែនទេបាទ។ បើ កែ ពក និង ចន ហ្នឹងៗបានមែន បើ ខៀវ សំផន គឺគ្មានទៅទេបាទ។

**ស៖** ចុះបើតាមលោក តើអ្នកណាគេដែលជាអ្នកនិយាយបញ្ហាទៅឈ្លប ឲ្យបញ្ហាឲ្យប្រជាជនឲ្យធ្វើការឲ្យបានប្រញាប់ប្រញាល់ហ្នឹង?

[១១:៤០:៥៩]

**ឆ៖** ដែលបញ្ហាគឺមានថ្នាក់ ដូចជា កែ ពក ហើយនិង ចន ដែលនៅផ្ទាល់ហ្នឹង។ ពេលដែលៗ

ទៅហើយ លោកទៅហើយហ្នឹង បញ្ហាអត់ឲ្យឈប់ទេ គឺសែងដី។ ពេលដែលទៅហ្នឹង ឲ្យសែងខ្លាំង មនុស្សទាំងរាប់ពាន់នាក់ គឺឲ្យសែងឲ្យខ្លាំង សែងឲ្យខ្លាំងមែនទែន រត់សុទ្ធតែរត់ ប៉ែឡែសែងរត់ បង្គីរែក អាហ្នឹងពេលដែលគាត់ទៅចុះបើកហ្នឹងគឺបើកការដ្ឋានហ្នឹង គឺមនុស្សគឺរែករត់តែម្តង។ ហុយរកមើលគ្នាមិនឃើញទេ ហុយមើលគ្នាអត់ឃើញទេ មើលមនុស្សមិនឃើញទេ។ ឡាន២០ ក៏មិនស្មើហុយដល់ប៉ុណ្ណឹងទេបាទ។ អានេះ ដោយខ្ញុំនៅផ្ទាល់នៅហ្នឹងទេ។ ពេលបើកការដ្ឋាន។

**ស៖** នៅពេលដែលគាត់និយាយមីក្រូបញ្ហាហ្នឹង លោកចង់និយាយថា ពេលហ្នឹង ហើយនិងពេលបើកការដ្ឋានហ្នឹង ជាពេលតែមួយជាមួយគ្នា ឬក៏ពេលខុសគ្នា?

**ឆ៖** តែមួយថ្ងៃហ្នឹងឯងបាទ តែមួយថ្ងៃមួយហ្នឹង តែមួយហ្នឹង។ តែមួយថ្ងៃហ្នឹងឯង។

**ស៖** តើ ចន ហ្នឹងជានរណាលោកអាចប្រាប់បានទេ?

**ឆ៖** ចន ហ្នឹងបើតាមដែល ឮតែគេនិយាយៗហ្នឹង ថ្នាក់ភូមិភាគឧត្តរបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី។

បាទ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅបន្ទប់រង់ចាំខាងក្រោយសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៤៣ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ បន្តទៅនេះ ផ្តល់វេទិកាជូនទៅភាគីសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខដំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីនេះ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ តើលោកស្តាប់ខ្ញុំទេលោកសាក្សី? ខ្ញុំសូមចាប់ផ្តើមបន្តពីអ្វីសហការីខ្ញុំបាននិយាយនៅព្រឹកមិញនេះ។ លោកបាននិយាយអំពីមេដឹកនាំមកពីភូមិភាគឧត្តរដែលមកជាកែ ពក ចូលមកទំនប់ ១មករា ហើយគាត់ឈ្មោះ ឈន។ លោកសាក្សី យើងមានឯកសារ E3/2165 ជាបញ្ជីអ្នកទោសមកពីមន្ទីរ ស-២១ គឺជាអ្នកទោសមកពីភូមិភាគឧត្តរចាស់។ គឺលេខ២១ នៅក្នុងបញ្ជីនោះ គឺមានបុគ្គលម្នាក់ឈ្មោះ ហំ ចាន់ ហៅ ចន ដែលគេកំណត់ថាជាលេខាតំបន់៤២។ ដូច្នេះខ្ញុំចង់សួរលោកថា តើស្រុករបស់លោកស្ថិតនៅក្នុងតំបន់៤២ នៃភូមិភាគឧត្តរដែរឬទេ? ហើយតើលោកនឹកឃើញអំពីឈ្មោះ ចន ហ្នឹងដែរទេ? តើ ចន ដែលលោកនិយាយថា ឃើញនៅទំនប់១មករា គឺជា ចន ដែលជាប្រធានតំបន់៤២ មែនឬទេ?

**លោក យាន លន់**

**ឆ៖** កែ ពក នៅស្រុកបារាយណ៍ ខេត្តកំពង់ធំ នៅភូមិចាន់ល្អូង កែ ពក។ នៅភូមិចាន់ល្អូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ – កែ ពក។

[១៣:៣៥:១១]

**ស៖** ខ្ញុំសួរលោកអំពីមនុស្សម្នាក់ឈ្មោះ ចន ដែលមកជាមួយ កែ ពក នៅទំនប់១មករា។ តើម្នាក់នេះ គឺ ចន ម្នាក់នេះគឺជាមេបញ្ជាលេខាតំបន់៤២ នៃភូមិភាគឧត្តរនោះ តើមែនឬទេ?

**ឆ៖** ចន ហ្នឹង នៅភូមិភាគឧត្តរ ប៉ុន្តែខ្ញុំអត់ដឹងស្រុកភូមិគាត់ឯណាទេ ចន នោះ។ មិនដឹងជាស្រុកភូមិ គាត់នៅឯណាបាទ។

**សៈ** លោកសាក្សី តើលោកចាំអំពីពេលមួយ គឺជាមេដឹកនាំតំបន់នៅក្នុងភូមិភាគត្រូវបានគេចាប់ខ្លួន ហើយបាត់ខ្លួន បន្ទាប់មកត្រូវបានពួកខាងនិរតី គេមកជំនួសនោះ តើលោកចាំអំពីពេលនោះដែរឬទេ?

**ឆៈ** បាទ ខ្ញុំអត់ចាំ បាទមិនចាំ។

**សៈ** ឥឡូវនេះ ខ្ញុំសូមអាននូវសក្ខីកម្មរបស់លោកនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក គឺ D166/156 គឺឯកសារD166/156 ខ្មែរមានលេខ ERN 00321785, អង់គ្លេសមានលេខ 00330718, បារាំងមានលេខ 00402981។ នេះគឺជាអ្វីដែលលោកបានផ្ដល់ចម្លើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយនោះ។ "ខ្ញុំអត់ចាំឈ្មោះមេឃុំ នៅជំនាន់ខ្មែរក្រហមទេ ប៉ុន្តែពួកគេទាំងអស់ ត្រូវបានគេយកទៅសម្លាប់អស់ហើយ" សូមបញ្ចប់ការដកស្រង់។ ហើយនៅក្នុងទំព័របន្ទាប់ នៅក្នុងកិច្ចសម្ភាសន៍របស់លោកនោះ គឺលោកបានរៀបរាប់អំពីយុទ្ធជននៅក្នុងថ្នាក់ស្រុកដែលលោកបាននិយាយ។ ខ្ញុំសូមដកស្រង់៖ "ប្រធានកងត្រូវបានគេសម្លាប់នៅក្នុងរបបខ្មែរក្រហម" តើលោកអាចប្រាប់បានទេ ថាតើកម្មាភិបាលក្នុងស្រុក នៅក្នុងតំបន់របស់លោក ដូចជាប្រធានកង ឬក៏ថ្នាក់ស្រុក ថ្នាក់ភូមិដែលលោកនិយាយថាត្រូវបានគេសម្លាប់នៅក្នុងរបបខ្មែរក្រហមនោះ តើលោកចង់សំដៅទៅលើអ្វីដែរ?

[១៣:៣៨:១៤]

**ឆៈ** ប្រធានកងជំនាន់នោះ គឺគេសម្លាប់អស់ហើយ គឺគេចាប់យកទៅសម្លាប់ ប៉ុន្តែមិនដឹងគេយកទៅសម្លាប់ឯណាទេ។

**សៈ** តើសកម្មភាពទាំងអស់នេះកើតនៅពេលណា? កើតឡើងនៅពេលដែលលោកធ្វើការនៅទំនប់ ១មករា ឬក៏មុនពេលដែលលោកទៅធ្វើការនៅទំនប់១មករា ឬក៏នៅក្រោយពេលលោកទៅធ្វើការនៅទំនប់១មករា តើលោកអាចប្រាប់បានទេ ថាមនុស្សទាំងអស់នេះត្រូវបានគេសម្លាប់នៅពេលណា?

**ឆៈ** ក្រោយទំនប់១មករា បាទ ក្រោយធ្វើការទំនប់១មករា។

**សៈ** តើអ្នកណាជាអ្នកមកជំនួសមេឃុំ ហើយនិងប្រធានកងនោះ តើលោកដឹងទេ?

**ឆៈ** ឈ្មោះ ឃី, ឈ្មោះ លឹម, ឈ្មោះ ឃឿន, ឈ្មោះ មុំ។

**សៈ** តើបុគ្គលទាំងអស់នេះ គឺជាមនុស្សមកពីតំបន់របស់លោក ឬក៏ពួកគេមកតំបន់ផ្សេងទេ?

**ឆៈ** មកតំបន់ផ្សេងៗ ពីភូមិផ្សេងៗ ស្រុកផ្សេងៗ។

**សៈ** តើមានពួកគេណាខ្លះមកពីភូមិភាគនិរតី ដូចជាមកពីតាកែវ ឬកំពត ដែរឬទេ?

**ឆៈ** ខ្ញុំអត់ដឹងទេ អត់ដឹង។

[១៣:៤១:០៥]

**ស៖** ឥឡូវនេះ យើងនិយាយអំពីទំនប់១មករាវិញផង ហើយខ្ញុំចង់សួរលោកនូវសំណួរមួយចំនួនដើម្បីឱ្យលោកបញ្ជាក់បំភ្លឺអំពីតួនាទីរបស់ឃុំ គឺឃុំកំពង់ថ្មនៅក្នុងការងារសាងសង់ទំនប់១មករា និងទំនប់៦មករា។ ជាដំបូងខ្ញុំចង់ដឹងថា តើឃុំរបស់លោកគឺឃុំកំពង់ថ្ម គឺស្ថិតនៅភាគខាងត្បូងនៃស្ទឹងជីនិត ហើយខាងជើង គឺជាប់តាំងក្រសាំង។ តើអ៊ីចឹងមែនទេ?

**ឆ៖** ស្ទឹងជីនិត គឺខាងត្បូងវត្តកំពង់ថ្ម ស្ទឹងជីនិត។ អត់មានខាងជើងវត្តកំពង់ថ្មទេ ខាងត្បូងវត្តកំពង់ថ្ម។

**ស៖** ចុះស្ទឹងតាំងក្រសាំង ៗហ្នឹងស្ថិតនៅក្នុងឃុំរបស់លោក ឬក៏ស្ថិតនៅក្នុងឃុំផ្សេងទៀត?

**ឆ៖** នៅឃុំតាំងក្រសាំង នៅកន្លែងមន្ទីរស្រុកតាំងក្រសាំង។

**ស៖** ហើយក្រៅពីទំនប់ ហើយនិងស្ពានដែលគេសាងសង់នៅស្ទឹងជីនិត ថាតើមានទំនប់អ្វីផ្សេងទៀតទេដែលគេសាងសង់នៅក្នុងឃុំកំពង់ថ្មរបស់លោកនោះ?

**ឆ៖** អត់មានទេ។

**ស៖** តើលោកចាំទេ ថាតើមានមនុស្សប៉ុន្មាននាក់មកពីឃុំរបស់លោក ដែលបានចូលរួមធ្វើការនៅក្នុងទំនប់? ថាតើប្រជាជនដែលទៅទំនប់ -- ទៅធ្វើការនៅទំនប់ហ្នឹង គឺជា គឺភាគច្រើនទៅពីឃុំរបស់លោក ឬក៏មានតែមនុស្សតិចតួចទេដែលទៅពីឃុំរបស់លោកនោះ?

**ឆ៖** គ្រប់ឃុំទាំងអស់ គឺក្នុងស្រុកសន្ទុកទាំងមូល កម្លាំងរាប់ម៉ឺននាក់ក្នុងស្រុកទាំងមូល កម្លាំងធ្វើទំនប់១មករា នៅក្នុងស្រុកសន្ទុកហ្នឹងបាទ កម្លាំងច្រើនណាស់ទូទាំងស្រុកសន្ទុកទាំងមូល។ ទំនប់១មករាហ្នឹង ធំណាស់ ការដ្ឋានធំមែនទែន។ ដូច្នេះ គឺកម្លាំងហ្នឹងគឺ រាប់ម៉ឺនៗ ច្រើនណាស់។

[១៣:៤៤:៥២]

**ស៖** អ៊ីចឹងកម្មករមកពីស្រុកសន្ទុក ដែលលោកនិយាយហ្នឹង តើពួកគាត់ទាំងអស់ហ្នឹងមកធ្វើនៅក្នុងឃុំរបស់លោក គឺឃុំកំពង់ថ្មហ្នឹងមែនទេ?

**ឆ៖** ធ្វើនៅក្នុងឃុំកំពង់ថ្ម។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំមានសំណួរខ្លះទៀត ទាក់ទងទៅនឹងអ្វីដែលសហការីខ្ញុំបានសួរលោកកាលពីព្រឹក។ លោកនិយាយថា មានបន្ទប់ មានបង្គន់អនាម័យឈើតូចៗដែលគេកសាងនៅការដ្ឋានរបស់លោក។ តើលោកអាចប្រាប់បានទេ ថាតើកាកសំណល់ ឬក៏-- តើកាកសំណល់ដែលទទួល

ដែលបានមកពីបង្គន់គេយកវាទៅណាដែរ គេយកវាទៅចាក់ចោលនៅកន្លែងណា ឬក៏គេធ្វើយ៉ាងដូចម្ដេចដែរ?

**ផ៖** បាទ អត់មានយកទៅណាទេ សំរាមហ្នឹងនៅចោលហ្នឹង អត់មានយកទៅណាទេ អត់មានកន្លែងយកទៅចាក់ចោល ឬមួយប្រមូលបោសសម្អាតជាអនាម័យអីអត់មានទេ នៅគរនៅកន្លែងហ្នឹងបាទ។

**ស៖** ហើយសហការីរបស់ខ្ញុំបានអានទូវកំណត់ហេតុស្ដាប់ចម្លើយរបស់លោក ដែលនៅក្នុងកំណត់ហេតុនោះ លោកនិយាយថា មានមេដឹកនាំខ្មែរក្រហមម្នាក់ដែលលោកឃើញនៅការដ្ឋាននោះ គឺកម្មាភិបាលម្នាក់នោះ និយាយដាក់មីក្រូ ហើយគាត់បញ្ជាឲ្យឈ្លប បញ្ជាឲ្យប្រជាជនធ្វើការឲ្យឆាប់ជាងមុន។ នៅក្នុងសក្ខីកម្មនេះ លោកនិយាយអំពីឈ្លបនៅការដ្ឋាន។ ដូច្នេះ ខ្ញុំចង់ដឹងថាតើឈ្លបដែលធ្វើការនៅទំនប់ ១មករា ហ្នឹង គឺជាអ្នកណាដែរ?

**ផ៖** ឈ្លប គឺច្រើនបាទ។ ឈ្មោះ អ៊ុន ឆេង – ប្រធានឈ្លប អ៊ុន ឆេង។ ហើយក្រោយមកទៀតឈ្លបៗ ហ្នឹងច្រើននាក់ណាស់។

[១៣:៤៧:៤៧]

**ស៖** តើឈ្លបទាំងអស់ហ្នឹងគឺឈ្លប មកពីថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់តំបន់ ឬក៏ថ្នាក់ភូមិភាគដែរ? តើអ្នកដែលលោកហៅថា មេឈ្លប ហ្នឹង គឺជាមេឈ្លបរបស់ឃុំ ឬក៏មេឈ្លបរបស់ស្រុក? តើលោកអាចប្រាប់បានទេ ថាតើឈ្លបហ្នឹងមកពីថ្នាក់ណាដែរ? មកពីឃុំ ស្រុក តំបន់ ឬក៏ភូមិភាគ?

**ផ៖** ឈ្លបនៅក្នុងឃុំបាទ នៅឃុំកំពង់ថ្ម។

**ស៖** ដូច្នេះ មនុស្សដែលលោកហៅថាជាមេឈ្លបហ្នឹង អ៊ីចឹងគាត់ជាឈ្លបរបស់ឃុំកំពង់ថ្ម តើអ៊ីចឹងមែនទេ?

**ផ៖** បាទ មេឈ្លបឃុំកំពង់ថ្ម បាទ។

**ស៖** តើឈ្លបដែលធ្វើការនៅការដ្ឋានទំនប់ ១មករា ហ្នឹង តើពួកគេមានតួនាទី ឬក៏ភារកិច្ចធ្វើអ្វីដែរ?

**ផ៖** ឈ្លបហ្នឹងគេដើរយាម ប្រជាជនដែលធ្វើជីកប្រឡាយ ជីកទំនប់ -- រែកដី រែកអីហ្នឹងបាទ។

**ស៖** តើឈ្លបទាំងអស់នោះ មានកាន់អាវុធដែរឬទេ?

**ផ៖** ឈ្លបនុ៎ង គឺកាន់អាវុធកាប៊ីន កាំភ្លើងកាប៊ីន១ចិន។

**សៈ** ខ្ញុំនឹងសួរលោកនៅពេលក្រោយអំពីឈ្លប ប៉ុន្តែឥឡូវនេះ ខ្ញុំចង់និយាយអំពីប្រធានបទថ្មីមួយទៀត គឺជាប្រធានបទដែលលោកនិយាយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ គឺការចាប់ខ្លួនទាហាន -- អតីតទាហាន លន់ នល់ នៅក្នុងកិច្ចសម្ភាសន៍របស់ D166/156, ERN ជាភាសាខ្មែរមានលេខ 00321786, អង់គ្លេសមានលេខ 00330719, បារាំងមានលេខ 00402982។ លោកបាននិយាយថា លោកបានធ្វើការក្នុងនាមជាឈ្លបឃុំ នៅក្នុងឃុំកំពង់ថ្ម ហើយលោកបានផ្តល់សក្ខីកម្មដូចតទៅនេះ៖ "សំណួរ៖ នៅពេលដែលលោកធ្វើឈ្លបនៅពេលនោះ តើលោកបានឃើញប្រជាជនប៉ុន្មាននាក់ដែលត្រូវបានគេចាប់? ឆ្លើយ៖ ខ្ញុំបានឃើញគេចាប់ប្រជាជនចំនួនប្រហែលជា៥០នាក់ ខ្ញុំជឿថាមានប្រជាជនជាច្រើនដែលត្រូវបានគេចាប់ ត្រូវបានគេចោទថា ជាប៉ូលិស ជាទាហាន ឬក៏ជាគិញ"។ បញ្ចប់ការដកស្រង់។ ដូច្នេះ ខ្ញុំចង់សួរលោកថា តើឃុំកំពង់ថ្មហ្នឹង ធ្វើយ៉ាងណាទើបអាចកំណត់បានថាតើមនុស្សណាខ្លះជាអតីតទាហាន ជាអតីតប៉ូលិស ឬក៏ជាគិញជាដើម របស់របប លន់ នល់ ហ្នឹង? ខ្ញុំចង់ដឹងថា តើឃុំធ្វើយ៉ាងណាទើបអាចកំណត់អត្តសញ្ញាណរបស់ប្រជាជនទាំងនោះបាន?

**ឆៈ** អង្កាល់នោះ ដែលដឹងគឺក្នុងនោះ គឺគេបែងចែកប្រជាជនចាស់ថ្មី -- អ៎! ន៎ែ ប្រជាជនចាស់ប្រជាជនថ្មី។ ដូច្នេះ គឺដឹងត្រង់ហ្នឹង។ គេបែងចែកប្រជាជនចាស់ ប្រជាជនថ្មី បាទ។

[១៣:៥៣:១០]

**សៈ** ឥឡូវនេះ ខ្ញុំចង់សួរលោកអ៊ីចេះវិញ នៅពេលដែលប្រជាជនថ្មីមកដល់ឃុំរបស់លោក គឺក្រោយថ្ងៃ១៧ មេសា ៧៥ តើពួកគាត់ត្រូវផ្តល់ប្រវត្តិរូបដែរឬទេ?

**ឆៈ** អង្កាល់នុំងប្រធានឃុំគេដើរកត់ ប្រធានភូមិគេដើរកត់។ ខ្ញុំមិនដឹងដែរ មិនបានដើរកត់នឹងគេ។

**សៈ** នៅពេលដែលលោកនិយាយថា មនុស្សជាច្រើនត្រូវបានគេចាប់ខ្លួន ដែលជាប៉ូលិស ឬក៏ទាហាននោះ តើមនុស្សដែលគេចាប់ខ្លួនហ្នឹងគាត់មានឋានន្តរសក្តិពីកម្រិតណាដល់កម្រិតណាដែរឬទេ? ឬមួយក៏គេចាប់ខ្លួនឱ្យតែជាទាហាន និងប៉ូលិស គេចាប់ខ្លួនតែម្តង?

**ឆៈ** បាទ ដែលចាប់នោះ គឺមិនចាំតែប៉ូលិស មិនចាំតែជាទាហានទេ ជំនាន់នោះ។ គឺទោះបីប្រជាជនចាស់ ក៏ -- ឱ្យតែធ្វើខុសក៏នៅតែគេចាប់ដែរ មិនថាតែថ្មី-ចាស់។

**សៈ** នៅពេលដែលលោកនិយាយថា ឱ្យតែធ្វើកំហុសហ្នឹងគេចាប់។ តើកំហុសបែបណាដែលគេចាត់ទុកថាជាកំហុសនោះ?

**ឆ៖** បាទ កំហុសនោះគឺធ្វើដោយដូចថា គេប្រើប្រាស់ទៅយើងដូចថាឈឺស្កាត់ទៅមិនរួចអ៊ីចឹង គេចេះតែបង្ខំទៅ យើងមិនទៅៗ គេដាក់ទារុណកម្មអ៊ីចឹងទៅ។ បាទ គេថាយើងហ្នឹង វាទៅជាខ្ជិលច្រអូសប្រឆាំងនឹងគេអ៊ីចឹងទៅ។

**ស៖** ពេលដែលឈ្លបឃុំចាប់ខ្លួន ប៉ូលិសនិងទាហាន -- អតីតប៉ូលិសនិងទាហានហ្នឹង ខ្ញុំចឹងដឹងថា តើឈ្លបឃុំហ្នឹងចាប់ខ្លួនពួកគាត់ហ្នឹងយកទៅណាដែរ?

**ឆ៖** ដែលគេចាប់ហើយ ខ្ញុំបាទអត់ដឹងថាគេយកទៅណាទេ មិនដឹងទេ។

[១៣:៥៦:៣០]

**ស៖** ក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺខ្មែរមានលេខ 00321786 ដល់ 87, អង់គ្លេសមានលេខ 00330719 ដល់ 720 និងបារាំងមានលេខ 00402982 ដល់ 83។ លោកបានរៀបរាប់អំពីមន្ទីរសន្តិសុខមួយដែលមានទីតាំងនៅត្បែងកោងៗ ហើយលោកបាននិយាយផងដែរថាឈ្លបឃុំ បាន -- ដែលស្នាក់នៅកងសៅ ឬក៏ត្បែងកោង។ ដូច្នេះខ្ញុំចង់សួរលោកថា តើឃុំកងសៅ ថាតើមានមន្ទីរនៅទីនោះដែរឬទេ ឬមួយក៏វាមាននៅកន្លែងផ្សេងនៅពេលដែលលោកនៅឃុំកងសៅៗនោះ?

**ឆ៖** បាទ អត់ភូមិកង -- នែអត់មានឃុំទេកងសៅ គឺភូមិកងសៅ។ អត់មានឈ្លបឃុំអីទៅនៅភូមិកងសៅអត់ទេ គឺភូមិកងសៅ អត់មានឃុំកងសៅទេ។ ឃុំហ្នឹងឃុំត្បែងកោង នៅការដ្ឋាន។

**ស៖** ប្រហែលជាមានបញ្ហាយល់ច្រឡំតិចតួចក្នុងការបកប្រែ ខ្ញុំនិយាយអំពីភូមិកងសៅ ហើយលោកនិយាយថា ឈ្លបឃុំស្នាក់នៅភូមិកងសៅ។ ដូច្នេះខ្ញុំចង់ដឹងថា តើមានមន្ទីរនៅក្នុងភូមិកងសៅៗ ដែលឈ្លបឃុំហ្នឹងស្នាក់នៅដែរឬទេ?

**ឆ៖** អត់មានមន្ទីរទេបាទ ស្នាក់នៅតាមផ្ទះៗទេ។ អត់មានមន្ទីរឈ្លប។

**ស៖** តើភូមិកងសៅជាភូមិធំ ដែលមានប្រជាជនៗរស់នៅច្រើន ឬមួយក៏ជាភូមិតូចទេ?

**ឆ៖** ពីជំនាន់ហ្នឹងប្រហែលជា ៦០ខ្នង ភូមិតូចទេ ៦០ខ្នងបាទ។

**ស៖** តើលោកស្គាល់មនុស្សម្នាក់ឈ្មោះ អ៊ុត សេង មកពីភូមិកងសៅដែលធ្វើការនៅទំនប់ ១មករា ដែរឬទេ? តើលោកចាំឈ្មោះ អ៊ុត សេងដែរឬទេ?

[១៣:៥៩:៥៦]

**ឆ៖** ខ្ញុំអត់ស្គាល់ទេ បាទ។

**ស៖** អ៊ុត សេង ស្នាក់នៅក្នុងភូមិកងសៅ ហើយគាត់បានផ្តល់សក្ខីកម្មនៅតុលាការនេះ នៅ

ថ្ងៃទី០២ ទី០៣ ខែមិថុនា ឆ្នាំ២០១៥នេះ ហើយគាត់ចាំលោកច្បាស់។ គាត់ផ្តល់សក្ខីកម្មថា ភាគច្រើនគាត់ឃើញលោកធ្វើការនៅក្នុងភូមិ ប៉ុន្តែគាត់បញ្ជាក់ថា គាត់ធ្លាប់ឃើញលោកម្តងនៅការដ្ឋានទំនប់ ១មករា។ ហើយខ្ញុំសូមអានន្ទូវអ្វីដែលគាត់បានផ្តល់សក្ខីកម្មនៅទីនេះ គឺឯកសារ E1/309.1។ គឺ E1/309.1 នៅម៉ោង ១៣:៥៥:៥៤ វិនាទី គាត់បានផ្តល់សក្ខីកម្មដូចតទៅនេះ អំពីអ្វី -- អំពីពេលដែលគាត់ឃើញលោកនៅទំនប់ ១មករា។ ខ្ញុំសូមដកស្រង់៖ “ខ្ញុំឃើញគាត់ដើរកាត់។ គាត់ទទួលខុសត្រូវលើប្រជាជនមកពីភូមិសៅ។ ដូច្នេះ គាត់អាចដើរមើលការដ្ឋានដែលប្រជាជនគាត់ធ្វើការ។ ប្រហែលជាគាត់ទៅទីនោះ ដើម្បីមើលកម្មករមកពីភូមិកងសៅហើយមើលទៅ។” ដូច្នេះ ខ្ញុំចង់សួរលោកថា ក្នុងពេលដែលលោកធ្វើជាឈ្លបឃុំ ដែលលោកឈរជើងនៅភូមិកងសៅ តើលោកធ្លាប់ទៅការដ្ឋានទំនប់ ១មករា ដើម្បីទៅមើលកម្មករ ឬក៏ពលកម្មករមកពីភូមិរបស់លោកដែរឬទេ?

**ឆ៖** ក្នុងនោះដែលបានឃើញ អង្កាល់ដែលធ្វើ ខ្ញុំនៅធ្វើ រែកដីហ្នឹងឯង នៅនឹងឯង ដែលឃើញរែកដីទាំងអស់គ្នាហ្នឹង ឃើញបាទ។

**ស៖** តើពីភូមិកងសៅទៅកន្លែងដែលលោកធ្វើការនៅទំនប់១មករាហ្នឹង តើវាឆ្ងាយពីគ្នាចម្ងាយប៉ុន្មានដែរ?

**ឆ៖** ខ្ញុំបាទស្មានមិនត្រូវដែរ មិនដឹងប៉ុន្មានគីឡូ។

[១៤:០២:៥២]

**ស៖** ខ្ញុំចងអានន្ទូវសម្រង់មួយទៀតមកពីកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺ ខ្មែរ 00321786 អង់គ្លេសមានលេខ 00300719 និងបារាំង 00402982។ នេះ គឺជាអ្វីដែលលោកបានផ្តល់សក្ខីកម្មទាក់ទងថា តើប្រជាជនត្រូវបានគេចាប់ខ្លួនដោយរបៀបណា នៅពេលដែលលោកធ្វើជាឈ្លប។ ខ្ញុំសូមកស្រង់៖ “ការបញ្ជាឲ្យចាប់ឃុំត្រូវបានចេញពីថ្នាក់ស្រុក និងថ្នាក់ខេត្ត។ ពួកគេបានបញ្ជូនលិខិតមកឲ្យ ថ្លាង។ ហើយ ថ្លាង គឺជាមេឃុំ។ ហើយថ្លាង បានបញ្ជាមកខ្ញុំដោយផ្ទាល់មាត់។ នៅពេលណាខ្ញុំចាប់មនុស្ស ខ្ញុំត្រូវបានគេប្រាប់ឈ្មោះអ្នកដែលត្រូវចាប់នោះ។ ហើយមនុស្សដែលត្រូវបានគេចាប់នោះគឺត្រូវបានហៅមកប្រជុំនៅឃុំ ហើយអ្នកទាំងនោះត្រូវបានគេចង និងដាក់ចូលក្នុងឡាន និងយកទៅសម្លាប់ចោល។” សូមបញ្ចប់ការដកស្រង់។ ដូច្នេះ ខ្ញុំចង់សួរលោកថា តើលោកធ្វើយ៉ាងណា ដែលដឹងថាការបញ្ជាឲ្យចាប់ហ្នឹង មកពីថ្នាក់ស្រុក និងថ្នាក់ខេត្ត?

**ឆ៖** បាទ គឺបញ្ជាហ្នឹង គឺមកពីថ្នាក់ -- មិនដឹងជាថ្នាក់ណាទេ គេថាអង្គការថ្នាក់លើៗ គឺជំនាន់

នោះ គឺគេហៅអង្គការ។ មិនដឹងអង្គការអី ហើយមិនដឹងឯណាអង្គការ ដឹងណាអ្នកធំ ដឹងណាតូចធំ អង្គការៗទាំងអស់។ បាទ មកពីលើតែម្តង។ វាមិនដឹងណាតូច ណាធំ បាទ។ មួយក៏ហៅអង្គការៗ រួចមិនដឹងសម្រេចនរណាមួយឲ្យចាប់មនុស្ស មិនដឹងពីថ្នាក់ណាមក។

**ស៖** ពេលដែលលោកនិយាយថា ប្រជាជនដែលត្រូវគេចាប់ខ្លួន ត្រូវបានគេហៅឲ្យទៅចូលរួមប្រជុំនៅឃុំ។ ដូច្នេះ ខ្ញុំចង់ដឹងថាតើប្រជនទាំងអស់នេះ គេយកទៅណាដែរ យកទៅមន្ទីរឃុំ ឬក៏គេយកទៅកន្លែងណាដែរ?

[១៤:០៥:៤១]

**ឆ៖** គេយកទៅ -- បាទ គេយកទៅកន្លែងមន្ទីរឃុំបាទ គេបញ្ជូនទៅមន្ទីរឃុំ។

**ស៖** តើមន្ទីរឃុំហ្នឹង -- តើមន្ទីរឃុំកំពង់ថ្មហ្នឹង មានទីតាំងនៅកន្លែងណាដែរ?

**ឆ៖** នៅខាងក្រោមទំនប់១មករា ខាងជើងវត្តកំពង់ថ្ម កន្លែងកោង ខាងក្រោមទំនប់១មករា។

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរលោកបន្ថែមទៅលើប្រធានបទថ្មី គឺពាក់ព័ន្ធទៅនឹងប្រជាជនចាមនៅក្នុងឃុំរបស់លោក។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺ D166/156 ខ្មែរមានលេខ 00321787, អង់គ្លេសមានលេខ 00330719, បារាំងមានលេខ 00402982។ លោកបានបញ្ជាក់ថាមានជនជាតិចាមមួយចំនួនត្រូវបានគេជម្លៀសទៅភូមិរបស់លោក ហើយគ្រួសារចាមខ្លះត្រូវបានគេបញ្ជូនទៅកន្លែងផ្សេង ហើយអ្នកខ្លះទៀតត្រូវបានគេចាប់ខ្លួន ហើយខ្ញុំក៏ចង់អាននូវសម្រង់របស់ អ៊ុត សេង គឺមនុស្សម្នាក់មកពីភូមិកងសៅ គាត់បានផ្តល់សក្ខីកម្មអំពីគ្រួសារចាម។

នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់គឺ E3/5267 ខ្មែរមានលេខ 00271411, អង់គ្លេសមានលេខ 00282357 និងបារាំងមានលេខ 00482935។ គាត់បានផ្តល់សក្ខីកម្មអំពីគ្រួសារចាមដែលរស់នៅក្នុងភូមិកងសៅ ដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "ប្រជាជនចាមត្រូវបានគេសម្លាប់ផងដែរនៅក្នុងរបបនោះ។ ថ្ងៃមួយនៅពេលដែលខ្ញុំភ្ញាក់ឡើង ជនជាតិចាមទាំងអស់នៅក្នុងភូមិរបស់ខ្ញុំបាត់ខ្លួនទាំងអស់តែម្តង។ មានគ្រួសារចាមចំនួន១០ នៅក្នុងភូមិរបស់ខ្ញុំ ហើយក្នុងចំណោម១០គ្រួសារនោះ គឺមានមនុស្សតែម្នាក់ប៉ុណ្ណោះដែលនៅរស់ ហើយនៅពេលនោះ គឺថាគាត់ទៅធ្វើការនៅក្នុងកងចល័តរបស់ស្រុក"។ លោកសាក្សី លោកគឺជាឈ្លបរបស់ឃុំ ហើយលោកបានផ្តល់សក្ខីកម្មថាមានចាមខ្លះត្រូវបានគេចាប់ខ្លួន ដូច្នេះ ខ្ញុំចង់ដឹងថាតើ អ្នកណាជាអ្នកបញ្ជាឲ្យចាប់ជនជាតិចាមនៅក្នុងឃុំកំពង់ថ្ម នោះ?

[១៤:០៩:០២]

**ឆ៖** បាទ ដែលបញ្ជាឲ្យចាប់នោះគឺពីថ្នាក់ៗតំបន់ ថ្នាក់ខេត្ត។ គាត់ប្រធានឃុំ ដល់ទៅរៀនមក គេយកមកអនុវត្តប្រាប់មកពីរៀន ពីខេត្តទៅ។

**ស៖** តើលោកចាំទេថាហេតុការណ៍នេះ កើតឡើងនៅឆ្នាំណាដែរ?

**ឆ៖** អត់ចាំទេបាទ។

**ស៖** តើលោកដឹងទេថា បញ្ជីឈ្មោះហ្នឹងគឺមានឈ្មោះជនជាតិទាំងអស់ ដែលរស់នៅក្នុងឃុំរបស់លោកមុនពេលដែលគេចាប់ខ្លួនដែរឬទេ?

**ឆ៖** អត់ដឹងទេ អត់ស្គាល់ឈ្មោះ អត់ដឹង។

**ស៖** សំណួរ ឬក៏ប្រធានបទចុងក្រោយមុនពេលដែលខ្ញុំប្រគល់វេទិកាទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណី គឺនិយាយអំពីតួនាទីរបស់លោកក្នុងនាមជាប្រធានឈ្លបឃុំ។ ដូច្នេះ ខ្ញុំចង់ឲ្យឆ្លើយទៅនឹងសក្ខីកម្មមួយចំនួន ដែលយើងបានដកស្រង់ចេញពីសក្ខីកម្មរបស់ អ៊ុត សេង។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់ អ៊ុត សេង ក្នុងឯកសារ E3/5267 ៗ, ERN ភាសាខ្មែរ 00271410, អង់គ្លេសមានលេខ 00282356 ដល់ 57, បារាំងមានលេខ 00482935។ គឺចំណុចនេះដែល អ៊ុត សេង ផ្ដល់សក្ខីកម្មអំពីលោក និងតួនាទីរបស់លោកនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំសូមដកស្រង់៖ "នៅក្នុងឃុំគឺមានបុគ្គលិកសន្តិសុខដែលគ្រប់គ្រង ពួកគេកាន់ដំបង ហើយនិងកាំបិត ហើយកាំបិត គឺមានប្រលាក់ឈាមដែលកកស្ងួតទៅហើយ។ ដូច្នេះជារួមគឺយើងខ្លាចស្លាប់ គឺមានឃាតករ -- មេឃាតករឈ្មោះ លន់ គាត់ជិះកង់ ហើយគាត់មានដាវនៅលើកង់របស់គាត់។ ឥឡូវនេះគាត់រស់នៅក្នុងភូមិខ្វែក ស្ថិតនៅក្នុងឃុំកំពង់ថ្ម ស្រុកសន្ទុក។ នៅក្នុងឆ្នាំ៧៩ នៅពេលដែលវៀតណាមមកដល់ លន់ ត្រូវបានចាប់ខ្លួន ហើយដាក់គុក"។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះ ខ្ញុំចង់សួរលោកគឺថា តើវាត្រឹមត្រូវដែរឬទេ ដែលថាលោកត្រូវបានគេចាប់ខ្លួន ហើយឃុំខ្លួនដាក់ពន្ធនាគារ ដោយតុលាការកំពង់ធំ ក្រោយពេលរបបខ្មែរក្រហមដួលរលំនៅក្នុងឆ្នាំ១៩៧៥នោះ -- ១៩៧៩?

[១៤:១៣:០៥]

**ឆ៖** បាទ អាហ្នឹងគេចោទខ្ញុំថា ខ្ញុំមេភូមិ ហើយនិងខ្ញុំមេខ្មែរក្រហម។ ដូច្នេះ គឺគេចាប់ខ្ញុំទៅដាក់គុកនៅកំពង់ធំ។

**ស៖** ហើយនៅក្នុងពេលដែលលោកធ្វើជាឈ្លបឃុំ នៅក្នុងឃុំកំពង់ថ្ម តើលោកមានតួនាទីអ្វីដែរ? តើមានពេលណាមួយដែលលោកក្លាយទៅជាប្រធានឈ្លប ឃុំកំពង់ថ្ម ទេ?

**ឆ៖** ខ្ញុំកាលណោះ អត់មានឈ្លបឃុំទេ បាទ។ ខ្ញុំ ឈ្លបខ្ញុំ ខ្ញុំធ្វើសម្រាប់តែភូមិខ្ញុំ ការពារភូមិខ្ញុំ អត់មានធ្វើឈ្លបឃុំអីទេ គឺការពារភូមិខ្ញុំតែម្តង។

**សៈ** លោកសាក្សី នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺ D166/156, ERN ជាភាសាខ្មែរមានលេខ 00321787, អង់គ្លេសមានលេខ 00330720, បារាំងមានលេខ 00402983។ លោកនិយាយថា លោកត្រូវបានចាប់ខ្លួន ខ្ញុំសូមដកស្រង់៖ "ខ្ញុំឈប់ធ្វើជាឈ្លបនៅក្នុងឆ្នាំ៧៧ ព្រោះថា ខ្ញុំមិនធ្វើតាមបញ្ជារបស់គេ។ ព្រោះគេបញ្ជាឲ្យខ្ញុំសម្លាប់មនុស្ស។ ខ្ញុំត្រូវបានគេបញ្ជាឲ្យឡើងជិះឡានជាមួយអ្នកដែលត្រូវបានគេចាប់មកមន្ទីរសន្តិសុខ នៅឃុំត្បែងកោង។ ខ្ញុំត្រូវបានគេបញ្ជាឲ្យសម្លាប់មនុស្ស ហើយខ្ញុំមិនធ្វើតាម"។ សូមបញ្ចប់ការដកស្រង់។ លោកសាក្សី នៅក្នុងកំណត់ហេតុស្តាប់ចម្លើយមួយទៀតរបស់លោកគឺនៅក្នុងទំព័រខាងមុខ ពាក់ព័ន្ធទៅនឹងបញ្ជាដែលលោកទទួលបានពីមេឃុំឲ្យចាប់មនុស្សហ្នឹងថាតើ នេះគឺជាអ្វីដែលលោកបានដកស្រង់ "ប្រសិនបើខ្ញុំមិនធ្វើ មិនស្តាប់បញ្ជាគេទេ ពេលខ្ញុំទៅចាប់ខ្លួនមនុស្សណាម្នាក់នោះ ខ្ញុំនឹងត្រូវគេសម្លាប់" សូមបញ្ចប់ការដកស្រង់។ ដូច្នេះ ខ្ញុំចង់សួរលោកថាតើវាជាការពិតដែរឬទេដែលថា ដើម្បីនៅរស់រានមានជីវិត លោកត្រូវតែស្តាប់ បញ្ជាគេទាំងអស់គឺបញ្ជាដែលទទួលបានពីថ្នាក់លើរបស់លោក រួមទាំងបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់មនុស្ស តើអ៊ីចឹងមែនទេ?

[១៤:១៦:១២]

**ឆ៖** បាទ គឺកាលនោះ គឺប្រាកដជាអ៊ីចឹងមែនគឺ ធ្វើ -- បើសិនថាមិនគោរពតាមវាបញ្ជាហើយបើយើងមិនធ្វើតាមខ្លួនយើងគឺអត់មានជីវិតរស់នៅទេ គឺ-- ហើយឲ្យតែនិយាយដូចថាមិនសមរម្យ និងដឹងរឿងអីពីវា គឺយើងហ្នឹងមិនរស់បានទេ មិនអាចរស់បាន អត់រស់បានទេ។ អានេះក្រោមការដឹកនាំជំនាន់ហ្នឹងគឺវាតាមយើង សម្លាប់យើងទាល់តែបាន។ បើថា ខ្វះ*(ឮមិនច្បាស់)* បើមិនគោរពបញ្ជាពីវាត្រូវតែងាប់បាទ អត់ទុកទេ បាទ ត្រូវតែងាប់។ ឧទាហរណ៍ដូចរូបខ្ញុំម្នាក់នេះ វាស្ទើរនឹងស្លាប់ ស្ទើរនឹងនៅ ស្ទើរនឹងរស់ វារស់ដោយពិបាក។ រត់មិនចេះចប់មិនចេះហើយ។

**សៈ** ខ្ញុំមានសំណួរមួយទៀត មុនពេលដែលខ្ញុំប្រគល់វេទិកាទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺជាសម្រង់ដែលខ្ញុំដកស្រង់។ លោកបាននិយាយថា លោកបានទទួលបញ្ជាមកពីមេរបស់លោកឲ្យសម្លាប់មនុស្ស។ ដូច្នេះខ្ញុំចង់ដឹងថាតើ មនុស្សប្រភេទណាដែលថ្នាក់លើរបស់លោកបញ្ជាឲ្យលោកសម្លាប់នៅក្នុងរបបខ្មែរក្រហមនោះ?

[១៤:១៧:៥០]

**ឆ៖** មនុស្សអត់ចាំមានប្រភេទទេបាទ អត់មានប្រភេទថាថ្មី ថាចាស់ ឱ្យតែធ្វើខុសបាទ មិនថាតែអ្នកថ្មីទេ ឱ្យតែធ្វើខុសៗ គឺគេសម្លាប់ហើយបាទ។ ឧទាហរណ៍ថា លួចស្រូវ លួចអង្ករ លួចដំឡូងអីដែលគ្នាឃ្លាន ទៅដកស៊ី ដកអី តែគេទាន់ងាប់ហើយមិនរស់ទេបាទ។ អានេះ ដែលខ្ញុំដឹង ខ្ញុំរស់នៅដឹងជំនាន់នោះគឺ ខ្ញុំតាមដានមកគឺអ៊ីចឹង។ ខុសគឺគ្មានខុសអីធំប៉ុន្មានទេ បាទ។ ខុសតែអារឿងក្រពះដែលសម្រាប់រស់រាល់ថ្ងៃបាទ។ មនុស្សយើងតែឃ្លានហើយ អត់ដឹងស្លាប់ ដឹងរស់ទេ។ វាអីធំជាងពោះ បាទ។ អីធំជាងបាយ អីធំជាងឃ្លាន។ មនុស្សត្រង់ហ្នឹងអត់ដឹង។ អ៊ីចឹងបានថា ជំនាន់ហ្នឹងវាមិនស្គាល់មនុស្សទេ គឺជាងសត្វទៅទៀតបាទ ជាងសត្វ។ សត្វវាស្គាល់ បើថាមនុស្សជំនាន់នោះ អត់ស្គាល់ទេ។ លែងស្គាល់ខ្មែរ លែងស្គាល់ឈាមខ្មែរអស់។ មនុស្សរស់នៅជំនាន់ហ្នឹងទល់មកនេះ បានម្នាក់ៗ គឺខ្ញុំថា សរសើរហើយ សរសើរអាយុជីវិតមែនទែន ថ្លៃណាស់ ថ្លៃមែនទែន ព្រោះកាលនោះ ដកដង្ហើមក៏ចង់មិនដល់គ្នា និយាយអីក៏គ្មានសិទ្ធិនិយាយកើតបាទ។ និយាយអត់កើត តែនិយាយដឹងពីខុស។

**ស៖** សូមអរគុណលោកសាក្សីដែលបានផ្តល់ចម្លើយដល់ខ្ញុំ។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមបញ្ចប់ការសួរសំណួររបស់ខ្ញុំហើយ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។

[១៤:២០:១៥]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ខ្ញុំជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរខ្លីៗទេ ពាក់ព័ន្ធទៅនឹងតួនាទីរបស់លោកជាឈ្លបនៅកំពង់ថ្ម និងតួនាទីរបស់លោកជាឈ្លបនៅការដ្ឋានសាងសង់ទំនប់ ១មករា។ សំណួរទី១ ខ្ញុំចង់សួរលោកថា តើគេជ្រើសរើសលោកយកមកធ្វើជាឈ្លបហ្នឹងតាមរបៀបណាដែរ?

**លោក យាន លន់៖**

**ឆ៖** បាទ មនុស្សជំនាន់ហ្នឹងធ្វើឈ្លបវាទាល់តែមនុស្សហ្នឹង ចេះគោរពវា ចេះដឹង។ ដឹងយ៉ាងម៉េច? ដឹងថា វាក៏មិនទុកចិត្តយើង យើងក៏មិនទុកចិត្តវា ម្ល៉ោះហើយវារើសមនុស្សណាដែលឆោត ដែលល្ងង់ បានវាយក។ បើមនុស្សចេះវាអត់យកទេ។ បើមនុស្សណាឆោតមិនចេះអក្សរដូចខ្ញុំអីបានវាយកសម្រាប់វាបំពាក់បំប៉នទៅវាឲ្យធ្វើនេះ ធ្វើនោះទៅ យើងអត់ដឹង។ អត់ដឹងខុស អត់ដឹងត្រូវ ដូចខ្ញុំអីចឹងបាទ។ អានេះ សាក្សីរបស់ខ្ញុំ ខ្ញុំដឹងអីចឹងតែម្តងបាទ ជំនាន់នុ៎ង។

**ស៖** លោកឆ្លើយជូនអ្នកស៊ើបអង្កេតនៅក្នុងឯកសារដែលយើងបានដកស្រង់តាំងពីព្រឹកមកនោះគឺ D156/156, ERN ជាភាសាអង់គ្លេស -- ជាបារាំងគឺ 00402981, អង់គ្លេសគឺ 00330719, ខ្មែរ 00321785។ លោកបានឆ្លើយថា គេបញ្ជូនលោកយកទៅកងយុទ្ធជន ក្រោយឆ្នាំ៧៥។ តើដើម្បីក្លាយជាឈ្លបហ្នឹង ទាល់តែពីមុនមកជាកងត្រូវធ្វើការនៅក្នុងកងយុទ្ធជនមែនទេ?

**ឆ៖** បាទ ក្នុងកងហ្នឹងវាមានដូចថា យើងធ្វើការអីចឹងទៅវាទុកចិត្តអីចឹងទៅ យើងដក គេដកមួយមកអីចឹង។ អាហ្នឹងអីចឹង វាដកដូចខ្ញុំថា ដកពីនេះ ដកពីនោះ។

[១៤:២៣:០៩]

**ស៖** ជាទូទៅ តើឈ្លបហ្នឹងមានអាយុប្រហែលប៉ុន្មានដែរ?

**ឆ៖** បាទ មិនដឹងទេ ពីអាយុឈ្លបនោះ មិនដឹង។

**ស៖** លោកទើបតែឆ្លើយថា ការជ្រើសរើសហ្នឹង គឺធ្វើក្នុងកងផ្ទាល់តែម្តង។ អីចឹងគឺមានន័យថានៅក្នុងកងការងារមែនទេ ដែលគេជ្រើសរើសយកឈ្លបនោះ?

**ឆ៖** ក្នុងកងការងារដែលធ្វើក្នុងកងចល័តកងអី ដកស្ទូង បាទ ដក។ ដូចថា កងចល័តភ្ជួររាស់ ដកស្ទូងអីចឹងទៅ បាទ។ ដកតាមកងស្ទូង កងចល័ត។

**ស៖** មុននេះបន្តិចលោកបានបញ្ជាក់ថា ឈ្លបកាន់កាំភ្លើងកាប៊ីន។ អីចឹងតើមុនពេលដែលចូលធ្វើជាឈ្លបហ្នឹង គេមានហ្វឹកហ្វឺនដល់អ្នកទាំងអស់ដែលគេត្រូវជ្រើសរើសហ្នឹងទេ?

**ឆ៖** បាទ អត់មានទេ អត់មានហ្វឹកហ្វឺនអីទេបាទ។

**ស៖** នៅក្នុងឯកសារដដែល គឺនៅ ERN ដដែល លោកបាននិយាយអំពីកងឈ្លបរបស់លោក លោកនិយាយថា មានគ្នា១២នាក់។ តើលោកអាចរៀបរាប់បានទេថា អ្នកទាំង១២ហ្នឹង ជាអ្នកណាខ្លះ? ហើយមកពីណាខ្លះ? មានអាយុប៉ុន្មានខ្លះ លោកអាចចាំទេ?

**ឆ៖** មិនចាំទេអាយុ បាទ បើចាំមនុស្សចាំបាទ ចាំខ្លះ ភ្លេចខ្លះ ព្រោះមនុស្សនៅច្រើនភូមិណាស់ ឈ្លបនោះមិនៗតែមួយភូមិទេ គឺវាចម្រុះ តាំងពីភូមិប្រាសាទ តាំងពីភូមិទក់ តាំងពីភូមិពន្សាវ តាំងពីភូមិត្រពាំងព្រីង ល្អក់ ទក់ មិនតែមួយភូមិៗទេ បាទ ច្រើនភូមិ ម្ល៉ោះហើយស្គាល់គេមិនសព្វទេបាទ។

**ស៖** នៅពេលដែលជ្រើសរើសធ្វើជាឈ្លបនោះ តើលោក ហើយនិងអ្នកផ្សេងទៀតហ្នឹង មានសិទ្ធិបដិសេធ មិនព្រមធ្វើទេ?

[១៤:២៦:២០]

**ឆ៖** បាទ កាលនោះ ខ្ញុំអត់ៗធ្វើទេ អត់ព្រមធ្វើទេ ប៉ុន្តែថាឥឡូវមិនធ្វើទៅខ្លាច ព្រោះគេអង្កាល់នោះ ខ្ញុំគេកំពុងតែតាមដានដែរ រឿងដូចថានៅជាមួយប្រជាជនហ្នឹងគឺខ្ញុំចេះន៎អាណិតប្រជាជនដែលអត់បាយ អត់ទឹកអី ខ្ញុំដូចថាធ្វើចោរចុះ ខ្ញុំធ្វើចោរចុះ បាទនិយាយអ៊ីចេះ។ ខ្ញុំធ្វើចោរដើម្បីលួចអង្ករសម្រាប់ប្រជាជនដែលអត់ឃ្លាន ដែលគ្នាមកពីធ្វើការហើយ គ្មានអង្ករ គ្មានអី មួយខ្ទះបីកំប៉ុងអី វាសុទ្ធតែទឹកសោះ ម្ល៉ោះហើយខ្ញុំដាក់ចិត្តប្រជុំ យាយតាទាំងអស់នៅភូមិហ្នឹង គាត់ថាអត់អីទេក្មួយ បើក្មួយឯងចេះធ្វើយ៉ាងម៉េចបានអង្ករហ្នឹងយកមកជូនប្រជាជនគឺប្រជាជនល្អណាស់ ល្អមែនទែនក្នុងភូមិកងសៅហ្នឹងបាទខ្ញុំគ្នាបីនាក់ ប្រធាន អនុប្រធាន ចាប់ផ្តើមខ្វងដែកខ្វងពីក្រោមៗជង្រុក អង្ករចេញមក មួយអាទិត្យយកមួយបាវៗ ចុកទៅវិញ ដើម្បីប្រជាជនរស់។ ភូមិកងសៅដែលខ្ញុំក្តាប់នៅភូមិកងសៅ គឺសុទ្ធតែគ្រូៗសុទ្ធតែថ្នាក់គ្រូនៅរស់ទាំងអស់បាទ។ នេះបើក្រៅពីភូមិខ្ញុំៗជម្រាបថា មិនរស់ទេ ប៉ុន្តែខ្ញុំៗ ចិត្តខ្ញុំៗដែលគេដកដាលទៅនេះ ទៅណោះ ដែលចាត់តាំងទៅធ្វើនេសាទអី គេសុំដក ខ្ញុំអត់ឲ្យដកដាច់ខាត គ្រូនៅគរគោក បាទសព្វថ្ងៃរស់នឹងខ្ញុំ រស់ច្រើនណាស់ គ្រូ ធ្វើគ្រូទើសសព្វថ្ងៃ ខ្លះធ្វើដល់តុលាការទៀតផងនៅកំពង់ធំ ដូចគ្រូរី អីបាទ រស់នឹងខ្ញុំច្រើនណាស់។ អានេះខ្ញុំដែលនៅភូមិកងសៅ ខ្ញុំក្តាប់ក្នុងហ្នឹង។ ខ្ញុំនិយាយដោយត្រង់ដែលខ្ញុំបានក្តាប់ចំពោះប្រជាពលរដ្ឋនៅភូមិកងសៅ។ ហើយអារឿងឈ្លប រឿងអីនេះ វាជាធម្មតាទេ បាទខ្ញុំក៏មើលការខុសត្រូវនៅក្នុងភូមិហ្នឹង ឈ្លបហ្នឹងសម្រាប់មើលតាមភូមិ តាមបាទមើលដូចថាមនុស្សមកពីណា ពីណីទៅ វាលួចសម្ភារៈ ដូចគោ ដូចក្របី មាន់ ទាអីទៅ វាភូមិមួយៗតែងតែមានសន្តិសុខអ៊ីចឹង មិនអត់ទេបាទ ដូចសព្វថ្ងៃអ៊ីចឹង បើគ្មានអាអស់ហ្នឹង ម៉េចៗនឹងកើត វាទាល់តែមាន ប៉ុន្តែថាមិនមែនទៅសន្តិសុខនោះសម្រាប់តែសម្លាប់មនុស្សទេ អត់ទេ ខ្ញុំនេះអត់ទេ មិនមែនសម្រាប់តែសម្លាប់មនុស្សទេ សន្តិសុខសម្រាប់ការពារអាយុជីវិតប្រជាពលរដ្ឋ បាទ។

[១៤:២៩:៣០]

**ស៖** សូមអរគុណ លោកសាក្សីដែលបានរៀបរាប់ដោយស្មោះត្រង់។ ការជ្រើសរើសឈ្លបហ្នឹងត្រូវបានធ្វើឡើងជាសម្ងាត់។ អ៊ីចឹងតើអ្នកភូមិ អ្នកធ្វើការហ្នឹង ដឹងថាអ្នកណាជាឈ្លប អ្នកណាមិនមែនជាឈ្លបទេ?

**ឆ៖** បាទ គឺក្នុងនោះ គឺក្នុងពេលនោះ ពេលដែលធ្វើ យើងអ្នកប្រធានភូមិហ្នឹង ក៏យើងមិនដឹងខ្លួនថាយើងស្លាប់ដែរ បានថាអ៊ីចឹង មានគេចាត់តាំងស្នូលសម្ងាត់មិនឲ្យយើងដឹងទៀត។ ប្រធានភូមិនេះមិនដឹងខ្លួនថាខ្លួនងាប់ទេ ហើយរស់នៅក្នុងជាមួយប្រជាពលរដ្ឋ តើប្រធានណាទៅហូបបាយ តែមិនទៅហូបបបរកន្លែងរោង គឺត្រូវតែប្រជាជនតាមដាន ត្រូវតែយើងងាប់។ អាហ្នឹងងាប់ដោយសារដៃប្រជាជនទៅវិញ បាទ ប្រជាជនរាយការណ៍ឲ្យសន្តិសុខឲ្យគេទៅ ប្រធានឃុំអីគេទៅ យើងត្រូវបាត់បង់ជីវិតអត់ដឹងខ្លួនទេបាទ មិនដឹងខ្លួន។ អ៊ីចឹងបានថាខ្ញុំរស់នៅក្នុងភូមិកងសៅ និយាយពីគេលើកបាយឲ្យស៊ីទៀតបាទ។ ក្មួយៗ ចៅៗស្រីៗលើកបាយទៅឲ្យខ្ញុំស៊ី ទៅឲ្យខ្ញុំស៊ី ខ្ញុំថា "ក្មួយអើយ កុំលើកមកឲ្យខ្ញុំ ខ្ញុំធ្លាប់ស៊ីតែបបរហ្នឹងរោងបាយទេ ឥឡូវក្មួយលើកមកឲ្យខ្ញុំ វ៉ៃមាន់ វ៉ៃទាមកឲ្យខ្ញុំស៊ី ខ្ញុំអត់ស៊ីទៀត"។ ខ្ញុំនៅហ្នឹងផ្ទះ សឿន រឿន មីងសឿន គាត់ថា "ហូបទៅក្មួយ វាមិនងាប់ទេ" ខ្ញុំអានេះឯងកន្លែងងាប់នោះ ព្រោះគេថាក្បត់ប្រជាជនអាត្រង់ហ្នឹងឯង សម្រាប់ងាប់ អាត្រង់ហ្នឹងឯង អាហ្នឹងកន្លែងងាប់។ ហើយខ្ញុំអត់បានហូបទេបាទ សុខចិត្តតត្រុកទៅហូបបបរជាមួយប្រជាពលរដ្ឋ បាទ។ អានេះខ្ញុំនិយាយខ្លួនខ្ញុំដែលអនុវត្តផ្ទាល់ បាទ។ អានេះល្បិច វាត្រូវសម្លាប់មនុស្សអ៊ីចឹង។

[១៤:៣១:២៣]

**ស៖** ខ្ញុំសុំកាត់លោក ខ្ញុំកាត់ពីព្រោះថាខ្ញុំមានពេលខ្លីណាស់លោកសាក្សី សូមលោកមេត្តាឆ្លើយឲ្យបានខ្លីៗតាមលទ្ធភាពដែលអាចធ្វើទៅបាន។ ខ្ញុំនឹងដកស្រង់ឃ្លាមួយនៃសក្ខីកម្មរបស់ អ៊ុត សេង ដែលយើងទើបតែនិយាយអម្បាញ់មិញនេះ គាត់ត្រូវបានស្តាប់ចម្លើយនៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ នៅចំពោះមុខតុលាការនេះ ខ្ញុំសូមដកស្រង់នូវចម្លើយរបស់គាត់៖ "យើងមិនអាចដឹងថា តើមានឈ្លបឬក៏អត់ទេ ពីព្រោះថាយើងពាក់សម្លៀកបំពាក់ខ្មៅទាំងអស់គ្នា មិនដឹងថាអ្នកណាជាអ្នកណានោះទេ"។ តើលោកអាចបញ្ជាក់បានទេថា ប្រជាជនមិនអាចបែងចែកថាអ្នកណាជាឈ្លប អ្នកណាមិនមែនជាឈ្លបទេ ព្រោះថាទាំងអស់គ្នាពាក់សុទ្ធតែខោអាវខ្មៅទាំងអស់គ្នា។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងហើយ។ ប្រជាជននិងឈ្លប ឯកសណ្ឋានដូចតែគ្នា ហើយជំនាន់ហ្នឹងគឺស្លៀកពាក់តែខ្មៅបាទ តែខោអាវខ្មៅ។ ប្រជាជនក៏ខ្មៅ ឈ្លបក៏សណ្ឋានខ្មៅ។ វាដូចតែគ្នាទេ វាគ្មានសណ្ឋាន

ណាឈ្លប គ្មានសណ្ឋានណាទាហាន ប៉ូលិស អត់មានទេបាទ។ បើទាហានគេក៏ខ្មៅ ទាហានក៏ខ្មៅ ស្ត្រីក៏ខ្មៅទាំងអស់ វាដូចអាឈុតខ្មៅទៅហើយបាទ កាលជំនាន់ហ្នឹងបាទ។

[១៤:៣២:៥៥]

**ស៖** តើឈ្លបហ្នឹង គេមានដាក់ចូលនៅក្នុងកងការងារជាមួយប្រជាជន ទៅបង្កប់ជាមួយប្រជាជនហ្នឹង បន្លំជាធ្វើការដូចប្រជាជនទេ?

**ឆ៖** ឈ្លបចុះធ្វើការជាមួយប្រជាជនហ្នឹងឯង ឈ្លបនោះបាទ មិនថាចាំតែឈ្លប ការងារឈ្លបទេ គឺស្ទូងដកទាំងអស់គ្នាបាទ។ កូនសុទ្ធ តែកូនអ្នកស្រែទាំងអស់ កូនប្រជាជនក្រីក្រទាំងអស់បាទ ឈ្លបហ្នឹងមិនមែនកូនអ្នកណាមកពីណាទេបាទ គឺអ្នកស្រែហ្នឹងឯង ឧទាហរណ៍ថា ដូចជាកូនខ្ញុំអីចឹងទៅ ធ្វើស្រែ ធ្វើចម្ការជាមួយតែគ្នាហ្នឹងឯង វាឈ្លប វាគ្មានទៅឈ្លបឯណាមានពិតប្រាកដទេបាទ។ ប៉ុន្តែគ្រាន់ឱ្យទៅពិនិត្យដូចថា មើលការខុសត្រូវចំពោះប្រជាពលរដ្ឋនៅហ្នឹងភូមិៗហ្នឹងអី ក្រែងលោវាឈ្លោះប្រកែកគ្នា ដោយស៊ីចុកហ្នឹងវាមិនឆ្អែតទៅ ក្រែងវ៉ៃគ្នា ចាក់គ្នា កាប់គ្នាទៅ។ ម៉្លោះហើយ វាតែងតែចាត់តាំងហ្នឹងឱ្យមើលខុសត្រូវទៅបាទ។ អាហ្នឹងពួកឈ្លប។

**ស៖** សូមអរគុណ។ នៅពេលដែលអ្នកស៊ើបអង្កេតសួរលោក គឺខ្ញុំយោងទៅលើឯកសារដដែល គឺ D166/156 គឺERN ដដែល ដូចដែលខ្ញុំបានលើកឡើងមុននេះ។ គឺលោកបាននិយាយថា លោកទទួលបញ្ជាឱ្យគ្រប់គ្រងកន្លែងហូបចុក ហើយនិងចាប់អ្នកណាដែលលួច។ តើលោក ចម្លើយរបស់លោកហ្នឹងគឺពិតជាអីចឹងមែនទេ គេមានបញ្ជាឱ្យឈ្លបយាមរោងបាយ ដើម្បីកុំឱ្យប្រជាជនទៅលួចហូបទេ? នេះជាភារកិច្ចរបស់លោកមួយដែរមែនទេ?

[១៤:៣៤:៥២]

**ឆ៖** បាទ គឺយាមហ្នឹងបាទ ក្រែងលោចោរមក អ្នកក្រៅអី តាស៊ី ហ្នឹងគេឱ្យបញ្ជាមើលអីចឹង។ ប៉ុន្តែខ្ញុំដែលខ្ញុំមើលការខុសត្រូវជាឈ្លបហ្នឹង ខ្ញុំមិនមែនធ្វើដូចអីចឹងទេ ឱ្យតែមនុស្ស ខ្ញុំឱ្យស៊ីហើយ ខ្ញុំលួចឱ្យស៊ីហើយបាទ ឱ្យតែមនុស្ស ព្រោះមនុស្សវាចង់រស់ មិនមែនចង់ស្លាប់ទេ បាទ។ ខ្ញុំលួចលាក់ឱ្យស៊ីទាល់តែបាននេះឯង ទោះបីមនុស្សមកពីណាក៏ដោយ។ រត់មកពីណា ទាហានក៏ដោយរត់ពីមុខ ពីក្រោយក៏ដោយឱ្យតែចូលកន្លែងខ្ញុំ គឺរស់ បាទ។ មិនស្លាប់ទេ បាទ។

**ស៖** តើឈ្លបមានទំនួលខុសត្រូវក្នុងការស្វែងរកអ្នកដែលគេចវេះពីធ្វើការ ហើយនាំយកមកធ្វើការវិញទេ នេះជាភារកិច្ចមួយរបស់ឈ្លបដែរឬទេ?

**ឆ៖** សព្វថ្ងៃឈ្លបវាងាប់អស់ច្រើនណាស់ បាទ អាឈ្លបហ្នឹងវាងាប់អស់រលីង នៅម្នាក់ពីរនាក់តែប៉ុណ្ណឹង។ ឆ្នាំ៧៩ ហ្នឹង គឺប្រជាពលរដ្ឋ គឺកាប់គ្មានសល់ អត់មានរត់រួចទេ បាទ។ ជាមួយដៃប្រជាជនដែលធ្វើមិនល្អ គឺអ៊ីចឹង។ ខុសជើង យកជើង ខុសដៃយកដៃ ដល់ពេលបរាជ័យទៅប្រជាជនកាប់ខ្ទេចរត់អត់រួច អាហ្នឹងត្រង់ហ្នឹងការងារដែលយើងដាច់ខាត យើងធ្វើមិនពិចារណាចំពោះមនុស្សៗលោក ខ្លួនមនុស្សដូចតែគ្នា មនុស្សដូចតែគ្នាយើងអត់គិតពិចារណា។ ត្រង់ហ្នឹងដល់បរាជ័យ ដល់ធ្លាក់ចុះទៅអត់រួចដៃប្រជាជនទេបាទ អត់រួចទេ ជំនាន់នុំងបាទ ប្រជាជនខឹងណាស់។ នេះជំនាន់របបប្រល័យពូជសាសន៍នេះ បើបងប្អូនណាកើតទាន់ៗ គឺត្រូវតែវេទនា។ ប៉ុន្តែជំនាន់នោះ គឺស្លាប់អស់ច្រើន នៅតិចទេទាន់ ហើយក្មេងក្រោយៗនេះ និយាយពីដែលអនុវត្តទំនប់ ១មករា នេះក្មេងសាក្រោយកើតមកថាមិនមែនមនុស្សរែកទេ ប្រាប់វាអត់ជឿទេ គឺសុទ្ធតែគ្រឿងចក្រទាំងអស់។ គ្រឿងចក្រអីណា ស្មារបស់ខ្ញុំនេះសុទ្ធតែរូង ដើរដួលព្រួសហើយចៅ ឲ្យស្គាល់កើតស្នឹង កើតអូរដោយសារស្នាដងចប អម្រែកបាទ។

[១៤:៣៧:៤៩]

**ស៖** សូមអរគុណ។ ខ្ញុំចង់និយាយអំពីភារកិច្ចរបស់ឈ្លប។ ខ្ញុំចង់ដកស្រង់នៅឃ្លារបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីដែលបានមកផ្ដល់សក្ខីកម្ម។ កាលពីមុនខ្ញុំនិយាយអំពី អ៊ុត សេង ប្រតិចារឹកគឺ E1/309.1។ សាក្សីនេះ គាត់បាននិយាយនៅប្រហែលជាម៉ោងប្រាំបួនសាមសិបនាទី។ ខ្ញុំសូមដកស្រង់ "នៅតាមភូមិនីមួយៗមានឈ្លប ដែលឃ្លាំមើលសកម្មភាពរបស់អ្នកភូមិ ហើយគេលបស្ដាប់នៅតាមទ្វារ ឬក៏ក្រោមផ្ទះ ជាពិសេស គឺពួក១៧មេសា។ គេស្ដាប់មើលការ -- ប្រជាជននិយាយគ្នា ប្រជាជន១៧ ពេលដែលនិយាយគ្នា គេលបស្ដាប់ ហើយឈ្លបហ្នឹងមើលទៅថា តើប្រជាជនមាននិយាយអំពីម្ហូបអាហារ ឬហូបចុកមិនគ្រប់គ្រាន់ ឬក៏អត់? ហើយនៅក្នុងសវនាការនេះ យើងក៏បានស្ដាប់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវិដា ខ្ញុំសូមយោងទៅលើប្រតិចារឹក E1/308.1 ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ បាននិយាយប្រហែលជាម៉ោងដប់សាមសិបប្រាំមួយនាទី។ គាត់និយាយថា មានឈ្លបនៅក្នុងភូមិ ពួកគេឃាមអ្នក១៧មេសា។ លោកសាក្សី នៅពេលដែលលោកធ្វើជាឈ្លប តើលោកភារកិច្ច និងទំនួលខុសត្រូវជាពិសេសក្នុងការតាមឃ្លាំមើលប្រជាជន១៧មេសា ដែរឬទេ?

[១៤:៣៩:១៧]

**ឆ៖** បាទ គឺកាលនោះ គឺដែលខ្ញុំនៅនឹងប្រជាពលរដ្ឋអ្នកថ្មី ដូចខ្ញុំនិយាយអំមិញនេះ គ្រូៗទាំងអស់គឺសុទ្ធតែនៅក្នុងទាហាន ប៉ូលិស ទាំងអស់នៅក្នុងរបប លន់ នល់ ទាំងអស់។ ដល់ជម្លៀសបានមក

នៅនឹងភូមិហ្នឹង ខ្ញុំទៅក្តាប់។ ម្យ៉ាងទៀតបងប្អូនដែលគ្រោះថ្នាក់ៗ ដែលត្រូវបាត់បង់ជីវិត វាមានអ៊ីចេះទៀត វាមានថាអ្នកចាស់ដូច -- អ្នកថ្មីដូចគ្នានេះ វារាយការណ៍ទៅប្រាប់ឃុំ ទៅប្រាប់ឈ្លបនេះ ដើម្បីសម្លាប់គ្នាឯងនេះ។ អានេះដែលខ្ញុំនៅហ្នឹងដឹង ខ្ញុំតាមដានច្បាស់។ មិនរាយការណ៍ឲ្យឈ្លបទេ វានោះទៅរាយឯឃុំអីនោះ ម្ល៉ោះហើយវាទំនាស់តែគ្នាឯងហ្នឹង។ អាខ្លះទៅរាយថា អានោះធ្វើទាហាន អានោះធ្វើប៉ូលិស អានោះធ្វើគិញ អ៊ីចឹងទៅ នែ៎ៗ ដោយសារងាប់ ងាប់អ៊ីចឹង រឿងអ្នកថ្មី។ តែគ្នាគាត់ហ្នឹងមិនមែនប្រជាជនចាស់ឯណាទៅតាមដាន ទៅរុករានអត់ទេ តែគ្នាគាត់ហ្នឹង យកតូចយកធំ ចង់ឲ្យវាបែកបាក់សាមគ្គី អត់ទេ។ អាហ្នឹងត្រង់ហ្នឹងទេ អានេះដែលខ្ញុំតាមដាន ខ្ញុំរស់នៅហ្នឹងភូមិហ្នឹង។ ហើយដូចខ្ញុំនិយាយហ្នឹង ភូមិកងសៅ ដែលខ្ញុំនៅតិចណាស់មនុស្សបាត់បង់ជីវិត។ គ្រូៗសុទ្ធតែគ្រូទាំងអស់បាទ នៅរស់សព្វថ្ងៃ ដោយសារអីដោយសារជំហរអ្នកដឹកនាំរឹងមិនឲ្យដកដាល។ និយាយពីដកដាលស្នើខ្ញុំហើយ ខ្ញុំទៅប្រជុំហើយ ស្នើហើយស្នើទៀត ស្នើថា ត្រូវតែដកពីរនាក់មួយមុខសញ្ញា ដូចថា នេសាទអ៊ីចឹង ដកពីរនាក់ អ៊ីចឹងទៅ។ ខ្ញុំថា នឹកក្នុងចិត្តខ្ញុំថា តែដកចុះដកឡើង មិនយូរនឹងងាប់ទេ។ ល្បិចវាឲ្យតែដកចុះ ដកឡើង គឺត្រូវតែងាប់អ៊ីចឹង។ ហើយខ្ញុំរឹងជំហរ ខ្ញុំអត់ដក។ សុទ្ធតែគ្រូទាំងអស់ នៅភូមិខ្ញុំ។ ហើយខ្ញុំស្មានថា បើសិនជា -- កន្លែងហ្នឹង បើសិនថាខ្ញុំកុំនៅ គ្រូហ្នឹងគឺរលាយហើយបាទៗ ព្រោះប្រជាជនខ្លះ គឺស្អប់ណាស់រឿងគ្រូ។ អ៊ីចឹងបានថា ខ្ញុំនៅកន្លែងនោះ គឺខ្ញុំមិនស្អប់ទេ គឺខ្មែរដូចគ្នា ឈាមខ្មែរដូចគ្នា ខ្ញុំអត់ស្អប់សោះ បាទ អត់ស្អប់។

[១៤:៤១:៣៦]

**ស៖** សូមអរគុណលោកសាក្សី។ តុលាការនឹងកត់ត្រាទុកអំពីសកម្មភាពល្អរបស់លោក នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំមានសំណួរមួយចុងក្រោយពាក់ព័ន្ធទៅនឹងតួនាទីរបស់លោក ខ្ញុំសូមដកស្រង់នូវសក្ខីកម្មរបស់សាក្សីមួយរូបដែលបានមកផ្តល់សក្ខីកម្មនៅថ្ងៃ២៦ ឧសភា ២០១៥ គឺឯកសារ E1/305.1 បុគ្គលរូបនេះគាត់និយាយអំពីតួនាទីរបស់ឈ្លប ពាក់ព័ន្ធទៅនឹងអ្នកទើបតែរៀបការថ្មីថ្មោង ខ្ញុំសូមអាននូវចម្លើយរបស់គាត់ ហើយសូមឲ្យលោកឆ្លើយតប។ សាក្សីរូបនោះបាននិយាយថា “ក្រោយពេលខ្ញុំរៀបការរួច ឈ្លបមកឃ្លាំមើលខ្ញុំ គេមកលបស្តាប់មើលថាតើ យើងមានចុះដំណោកឬក៏អត់? ប្រសិនបើយើងមិនចុះដំណោកទេ គេនាំយើងយកទៅសម្លាប់ចោល”។ សាក្សីរូបនោះ ក៏បានបញ្ជាក់នៅក្នុងចម្លើយផ្សេងទៀតផងដែរ ថា “គេមកលបស្តាប់ខ្ញុំ និងប្តីខ្ញុំនៅយប់ដំបូង ហើយឈ្លបហ្នឹងតែងតែទៅលបស្តាប់អ្នកដែលទើបរៀបការថ្មីៗទាំងអស់”។ អ៊ីចឹងខ្ញុំចង់ដឹងថា តើក្នុងឃុំរបស់លោកហ្នឹង

យ៉ាងម៉េចដែរ តើឈ្លបមានទទួលភារកិច្ចក្នុងការលបស្តាប់ឬក៏ឃ្លាំមើលអ្នកដែលទើបរៀបការថ្មីៗទេ?

[១៤:៤៣:០៩]

**ឆ៖** បាទ គ្មានទេបាទ និយាយរឿងអ៊ីចឹងៗគឺ វាគ្មាន។ គ្មានអស់លោកណាទៅតាមរឿងអ៊ីចឹងៗ បាទ វាដូចជាមិនសមនឹងលើកឡើងសោះ បាទ។ អានេះកាលខ្ញុំរស់នៅហ្នឹង វាមិនសមនឹងលើកឡើង អារឿងអ៊ីចឹងៗ វាដូចជាថោកណាស់។ អ៊ីចឹងបានថា អ្នកនិយាយហ្នឹង គឺនិយាយមិនបានជាបានច្បាស់ ខ្ញុំនៅហ្នឹងគឺខ្ញុំមិនដឹងដែរ គឺអារឿងគេតាមអ៊ីចឹងៗ ប៉ុន្តែបើចំពោះខ្ញុំវិញ គឺខ្ញុំមិនសៅហ្មងទេ។ អានេះ ដល់យើងវាធ្វើអ៊ីចឹង វាដល់គិតដល់កម្រិតអ៊ីចឹង វាដូចថាវាមិនមែនមនុស្សសោះទេ។ វាគ្មានដឹងយល់ថា សង្គមជាតិយ៉ាងម៉េច ហើយប្រពៃណីយ៉ាងម៉េច គឺអត់ដឹង អត់ស្គាល់ បើមិនស្គាល់ជាតិ មិនស្គាល់ប្រពៃណី មិនដឹងរស់ធ្វើមនុស្សយ៉ាងម៉េចទេបាទ។ ហើយសម័យនោះ បើសិនជាថាៗ យើងមិនស្គាល់ ក៏មិនស្គាល់ មិនស្គាល់ខ្មែរ មិនស្គាល់ឈាមខ្មែរ មិនស្គាល់ជាតិ មិនស្គាល់វត្ត មិនស្គាល់អារាម និងស្គាល់ព្រះសង្ឃហើយចប់ហើយ បាទ។ អ៊ីចឹងហើយបានជាគ្រោះថ្នាក់មនុស្ស ព្រោះយើងវាគ្មានវត្ត គ្មានចាយលុយ គ្មានវត្ត គ្មានអារាម ម្ល៉ោះហើយប្រជាពលរដ្ឋសង្គមជាតិយើងគឺខ្វះវត្ត គឺមនុស្សនោះ គឺកាប់ហើយនិងចាក់។ និយាយរួមដូចសព្វថ្ងៃ ប៉ុនមានវត្តមានអារាម មានលោកសង្ឃទេសរាល់ថ្ងៃ គង់តែកាប់ចាក់ អត់មានស្វាង អត់មានគោរព។ អ៊ីចឹងបាននាំសង្គមនោះ ដែលវាគ្មានសោះអ៊ីចឹង វាវែងមែនទែន វាស្រឡះឆិញ បាទស្រឡះឆិញ។ អ៊ីចឹងបានថា មនុស្សរស់នៅក្នុងជំនាន់នោះ រស់នៅទាល់មកដល់ថ្ងៃនេះ អស់លោកទាំងអស់ត្រូវតែយល់ ត្រូវតែចងចាំ ចងចាំឲ្យច្បាស់ កុំឲ្យចូលអាជំនាន់នឹងទៀត បាទ កុំឲ្យចូលអាជំនាន់នឹងទៀត ព្រោះតែធ្លាក់ទៅជំនាន់នឹងទៀតមនុស្សអត់នៅទេ គឺរលីងឆិញ គឺងាប់។ អ៊ីចឹងបានថា យើងត្រូវស្តាប់ខ្ចីមជំនាន់នោះ ត្រូវស្អប់ខ្ចីមឲ្យខ្លាំងមែនទែន។ ក្មួយៗ ចៅៗ ទាំងអស់ដែលរស់នៅតូចតាចសព្វថ្ងៃ ម៉ែឳក៏ជួយបំពាក់បំប៉នប្រាប់ថា នែ៎! របបនេះវាអ៊ីចេះៗៗ។ វាសាហាវណាស់។ ម៉ែអ្នកព្យាបាលកូន ត្រូវតែរាយរាប់ប្រាប់ និយាយប្រាប់។

[១៤:៤៦:០៨]

**ប្រធានអង្គជំនុំ៖**

បាទ ម៉េចទៅ?

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំគិតថា សក្ខីកម្មរបស់សាក្សីនេះ មិនឆ្លើយតបនឹងសំណួរទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទឥឡូវនេះ ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មេធាវីនាំតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអស់ពេលហើយ។ ម៉ោងបីសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្រាប់សម្រួលផ្ដល់កន្លែងសម្រាក នៅបន្ទប់រងចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្ម រួមទាំងមេធាវីប្រឹក្សារបស់គាត់នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៦ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ បន្តទៅនេះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីជនជាប់ចោទ ដែលដំបូងនេះផ្ដល់ទៅមេធាវីការពារក្ដីជនជាប់ចោទ នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរតិចតួចទេសួរទៅកាន់រូបលោក។ ខ្ញុំស្នូគស្មាញបន្តិចដែរជាមួយនឹងសក្ខីកម្មរបស់លោក អ៊ីចឹងសូមឲ្យលោកបញ្ជាក់ឲ្យបានច្បាស់លាស់បន្តិច។ លោកទើបតែបានឆ្លើយថា លោកបានលួចអង្ករទៅឲ្យប្រជាជនហូបហ្នឹងដោយសារលោកមានចិត្តអាណិតអាសូរដល់ប្រជាជននៅក្នុងភូមិរបស់លោក ហើយប្រជាជននៅក្នុងភូមិរបស់លោកហ្នឹង ទទួលស្គាល់ចំពោះចិត្តសប្បុរសធម៌របស់លោក ប៉ុន្តែនៅពេលជាមួយគ្នានោះ លោកក៏បានប្រឈមមុខជាមួយសក្ខីកម្មរបស់សាក្សីផ្សេងមកពីភូមិរបស់អ្នកឈ្មោះ អ៊ុត សេង។ ហើយសាក្សីរូបនេះ បានផ្ដល់សក្ខីកម្មនៅថ្ងៃទី០៣

ខែមិថុនា -- ខែឧសភា ថ្ងៃទី០៣ ខែឧសភា ដែលថាសំណាងល្អដែរដែលលោកត្រូវបានចាប់ខ្លួន បើមិនដូច្នេះទេ អ្នកភូមិប្រហែលជាគេសម្លាប់លោកចោលបាត់ទៅហើយ។ តើលោកយល់យ៉ាងម៉េចដែរចំពោះចម្លើយរបស់គាត់នេះ ខ្ញុំនឹងអានឱ្យលោកស្តាប់នូវសក្ខីកម្ម៖ "នៅក្នុងឆ្នាំ១៩៧៩ នៅពេលវៀតណាមមកដល់ គាត់ត្រូវបានចាប់ខ្លួន ហើយគេយកទៅដាក់គុក អ៊ីចឹងហើយបានជាគាត់នៅរស់រៀនមានជីវិតដល់សព្វថ្ងៃ បើកុំតែវៀតណាមចាប់យកទៅហ្នឹង កុំអីគឺគេសម្លាប់ចោលបាត់ទៅហើយ"។ តើលោកមានប្រតិកម្មយ៉ាងម៉េចចំពោះសក្ខីកម្មរបស់សាក្សីរូបនេះ – របស់ អ៊ុត សេង?

**លោក យាន លន់៖**

**ឆ៖** បាទ គឺខ្ញុំអត់មានប្រតិកម្មយ៉ាងម៉េចទេ គឺដែល ស្មាមដែលគាត់និយាយ ពាក្យសម្តីដែលគាត់និយាយនោះគឺត្រឹមត្រូវបាទ។

[១៥:០៤:៤៨]

**ស៖** ដូច្នេះជាការពិតទេដែលថានៅក្នុងភូមិនោះគឺថា គេមិនមានចិត្តអាណិតអាសូរលោកទេ បើកុំតែវៀតណាមចាប់ទៅគេសម្លាប់លោកហ្នឹង?

**ឆ៖** អានេះ បើការណ៍ខ្ញុំយល់ ខ្ញុំដឹងគឺ ការស្អប់ហ្នឹងគឺចំពោះបុគ្គលបាទ បើអ្នកទូទៅ គឺភាគច្រើនគេមិនស្អប់ខ្ញុំប៉ុន្មានទេ ប៉ុនចំពោះបុគ្គល ក្នុងជំនាន់នោះគឺគេស្អប់ហើយ ចំពោះបុគ្គល។ បើទូទៅគឺមិនស្អប់ខ្ញុំទេ ភាគច្រើន បើបុគ្គលគេស្អប់។ ការធ្វើការ វាមានប៉ះ មានពាល់ មិនឈប់មិនឈរទេ គឺតិចច្រើន គឺមិនដឹងទេ គឺត្រូវតែមានប៉ះ ដូចគេ -- ដូចគាត់ផ្តល់ព័ត៌មានហ្នឹងគឺត្រូវហើយ។ ខ្ញុំ បើសិនជារត់បើកុំតែរត់ ក៏មិនរស់ដែរ ហើយបើកុំតែគេចាប់យកទៅដាក់គុក ក៏មិនបានរស់ដែរ ព្រោះក្នុងនោះ ព្រោះមនុស្សវាប៉ងប្រាថ្នាសម្លាប់ខ្ញុំ គឺវាគ្រប់ច្រកទាំងអស់។ ដូច្នេះ ប៉ុន្តែខ្ញុំនឹកឃើញថា ទឹកដោះម្តាយខ្ញុំថ្លៃមានគុណដ៏ខ្ពង់ខ្ពស់ ក៏ជីវិតខ្ញុំនៅរស់ទាល់ប៉ុណ្ណោះទៅ។ ដូច្នេះគឺអស់លោកទាំងអស់នេះ គឺបានជ្រាប។

**ស៖** អ៊ុត សេង មិនគ្រាន់តែឆ្លើយថា អ្នកភូមិហ្នឹង គឺគេចង់សម្លាប់លោកដោយការសងសឹកប៉ុណ្ណោះទេ ប៉ុន្តែគាត់ថែមទាំងឆ្លើយបន្ថែមទៀតនៅម៉ោង ០៩:៣២ -- នៅនាទីទី០៩:៣២ ថា លោកគឺជាពេជ្ឈឃាដម្នាក់នៅក្នុងចំណោមពេជ្ឈឃាដជាច្រើននៅក្នុងភូមិហ្នឹង ដែលមានកាំបិត មានដាវប្រឡាក់ទៅដោឈាម ហើយថាលោកហ្នឹង គឺពិតជាពេជ្ឈឃាដមែន ដែលបានសម្លាប់មនុស្សមែន។ តើអ៊ីចឹង ឬក៏អត់ទេ?

[១៥:០៧:១១]

**ឆ៖** បាទ គាត់ថាហ្នឹង គឺខុសខ្លះ ត្រូវខ្លះ។ ដូចខ្ញុំថា ថាហ្នឹងវាខុសខ្លះ ត្រូវខ្លះអ៊ីចឹងទៅ ដូចខ្ញុំថា ស្អប់ចំពោះបុគ្គល គឺបុគ្គលណាស្អប់គឺថាទៅ ទោះបីរឿងហ្នឹងមិនច្បាស់ក៏នៅតែថាទៅ បាទ ផ្សំផ្គុំឱ្យបានធំទៅ អានេះគឺអ៊ីចឹងបាទ។

**ស៖** ប៉ុន្តែគាត់បានហៅលោកថាជាមេពេជ្ឈឃាដ។ តើលោកពិតជាពេជ្ឈឃាដមែនទេ?

**ឆ៖** បាទ ខ្ញុំអត់ទេបាទ ខ្ញុំអត់ទទួលទេបាទ ខ្ញុំអត់មានមេរឿងពេជ្ឈឃាដ គឺអត់ទេ ខ្ញុំអត់ទទួលជាមេពេជ្ឈឃាដអីទេបាទ ព្រោះគាត់មិនដឹងមេ មិនដឹងមេឯណាមេ គាត់ចេះតែថាខ្ញុំមេទៅ អត់ស្គាល់មេគេឯណាផង។

**ស៖** ប៉ុន្តែគាត់បានឆ្លើយថា លោកមានដាវ មានកាំបិត មានដាវប្រឡាក់ទៅដោយឈាម ដែលបញ្ជាក់ថា លោកគឺជាពេជ្ឈឃាដម្នាក់ក្នុងចំណោមពេជ្ឈឃាដជាច្រើនមែន បើគាត់ឆ្លើយថាអ៊ីចឹង តើចម្លើយរបស់លោកគាត់ត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវទេ?

**ឆ៖** បាទ ខ្ញុំអត់ ចម្លើយហ្នឹងគឺខ្ញុំមិនទទួលថាត្រឹមត្រូវទេបាទ ព្រោះបានថាអ៊ីចឹង គឺក្នុងពេលនោះ ជំនាន់នោះ គឺមិនមែនតែខ្ញុំទេគឺធ្វើ។ គឺធ្វើ គឺទាំងអស់គ្នារាប់លាននាក់ដែលរស់នៅក្នុងជំនាន់ហ្នឹង តើមិនមែនតែប្រជាជន គឺកើតឡើងដូចថាតាមដានមនុស្ស សម្លាប់មនុស្ស មិនមែនតែចេះសម្លាប់បានទេ គឺតាមដានគ្រប់ថ្នាក់ទាំងអស់បាទ ជំនាន់ហ្នឹង មនុស្សណាក៏ចេះតាមដាន តាមដានសម្លាប់មនុស្សតាំងពីអ្នករោងបាយ ប្រធានរោងបាយ តាំងពីប្រធានកង ប្រធានក្រុមទាំងអស់បាទ អាហ្នឹងអ៊ីចឹង។ រួចមកនិយាយថា ខ្ញុំម្នាក់ហ្នឹងធ្វើពេជ្ឈឃាដអ៊ីចឹង វា ខ្ញុំអត់ស្របទេបាទ។

[១៥:០៩:៥៨]

**ស៖** លោកត្រូវបានផ្តន្ទាទោស ដោយសារតែអំពើរបស់លោកនៅក្នុងរបបហ្នឹង ត្រូវបានតុលាការខេត្តកំពង់ធំផ្តន្ទាទោសលោក។ តើលោកត្រូវបានតុលាការផ្តន្ទាទោសដាក់គុក១០ឆ្នាំ មែនទេ?

**ឆ៖** បាទ ខ្ញុំជាប់ពី -- ដែលអ្នកទៅស៊ើបអង្កេតហ្នឹងឯង គឺដាក់ខុស។ ខ្ញុំជាប់តាំងពី៧៩ឯណោះដល់គាត់ទៅអ្នកស៊ើបអង្កេតហ្នឹង គឺដាក់ឆ្នាំ១៩៨២។ ខ្ញុំជាប់តាំងពី៧៩មក បាទ។ ជាប់ច្រើនណាស់បាទ។

**ស៖** តើលោកពិតជាត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារអស់រយៈពេល១០ឆ្នាំមែនទេ?

**ឆ៖** បាទ ដាក់មែន។ ក្នុងសៀវភៅខ្ញុំបើកមើល ក្នុងក្រាំងហ្នឹង គេឱ្យបើកមើល១០ឆ្នាំ បាទ ១០ឆ្នាំ ប៉ុន្តែខ្ញុំជាប់នៅក្នុងគុកនោះ គឺដើម្បី គឺនគរបាល ហើយនិងលោកទាំងអស់ដែលនៅធ្វើការហ្នឹង

ដែលខ្ញុំធ្វើការល្អ។ ខ្ញុំមិនចេះវៀចវេរ និងអស់លោក និងប៉ូលិស និងទាហាន នៅតំបន់ នៅកន្លែងគុកក៏ដោយ នៅកន្លែងណាក៏ដោយ។ ដូច្នេះ មួយឆ្នាំ គេសម្រាលឲ្យខ្ញុំមួយឆ្នាំ – មួយឆ្នាំ គេសម្រាលឲ្យខ្ញុំមួយឆ្នាំ។ ដូច្នេះទោសហ្នឹង គឺត្រូវជាប់១០គុក(*ស៊ីក*) មែន បាទ។

**ស៖** តើលោកដឹងថា លោកត្រូវបានតុលាការផ្តន្ទាទោសទៅលើឧក្រិដ្ឋកម្មអីខ្លះ?

**ឆ៖** បាទ គឺសព្វថ្ងៃនេះ ពេលនេះ គឺផ្តន្ទាទោសលើមេដឹកនាំដ៏ធំៗ ថ្នាក់កំពូល។ ម្ល៉ោះហើយគឺក្នុង ដូចតែខ្ញុំរស់នៅតូចតាច។ ដូច្នេះ គឺវាគួរអាណោចអាធ័ម គួរឈឺចាប់។ ត្រង់ហ្នឹង គឺការដឹកនាំពីអង្កាល់នោះ គឺដូចថា វាវេទនាប្រជាពលរដ្ឋខ្លាំងណាស់។ ដូច្នេះគឺខ្ញុំ--

**ប្រធានអង្គជំនុំ៖**

លោកៗឆ្លើយមិនចាំសំណួរទេ លោកស្តាប់សំណួរឲ្យបាន បើលោកស្តាប់មិនយល់ លោក អាចសុំឲ្យអ្នកម្ចាស់សំណួរហ្នឹង រៀបចំសំណួរសួរលោកម្តងទៀត។ សាជាថ្មីឡើងវិញណ៎ះ! លោកស្តាប់សំណួរ ហើយលោកឆ្លើយតបសំណួរមិនចំទេ បានន័យថាលោកស្តាប់សំណួរមិនយល់ទេ។ លោកមេធាវី វ៉ិចទ័រ កូប៉េ តាំងសំណួរចុងក្រោយរបស់លោកសាជាថ្មី ចំពោះសាក្សី។

[១៥:១៣:១៧]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន ខ្ញុំនឹងកែសម្រួលសំណួរ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើតុលាការផ្តន្ទាទោសលោកទៅលើបទល្មើសអ្វីខ្លះ? ឧទាហរណ៍ដោយសារតែអំពើមនុស្សឃាត ការសម្លាប់អ្នកភូមិអ្នកស្រុក។ លោកដឹងទេថា ពេលដែលតុលាការសម្រេចផ្តន្ទាទោសលោកហ្នឹង តើគេផ្តន្ទាទោសលោកទៅលើបទល្មើសអ្វីខ្លះដែរ?

**លោក យាន លន់៖**

**ឆ៖** បាទ ពីអង្កាល់នោះ គេចោទខ្ញុំថា ខ្ញុំមេខ្មែរក្រហម ហើយមេប្រធានភូមិ បាទ។

**ស៖** បទល្មើសដែលចោទប្រកាន់មកលើលោកហ្នឹង តើវាជាបទល្មើស ដូចជាអំពើមនុស្សឃាតគឺការកាប់សម្លាប់អ្នកភូមិអ្នកស្រុកហ្នឹង គឺ -- បាទ បទល្មើសទាំងអស់ហ្នឹង លោកមាននៅចាំទេ? បទល្មើសអីដែលគេផ្តន្ទាទោសលោកដោយតុលាការខេត្តកំពង់ធំកាលនោះ?

**ឆ៖** បាទ អង្កាល់ហ្នឹង គឺគេផ្តន្ទាទោសហ្នឹង គឺអារឿងៗរឿងកាប់សម្លាប់ហ្នឹងហើយ បានគេ

ផ្តន្ទាទោស ដាក់គុកខ្ញុំ។ គេចោទប្រកាន់ខ្ញុំថា ខ្ញុំហ្នឹងមេខ្មែរក្រហម មេសម្លាប់មនុស្សថែមទៀត។ អាហ្នឹងត្រង់ហ្នឹង បានដាក់គុកខ្ញុំហ្នឹងបួនដប់ឆ្នាំ បាទ។

**ស៖** តើតុលាការមានបានផ្តន្ទាទោសលោកដោយបញ្ជាក់អំពីការសម្លាប់មនុស្សណាជាក់លាក់ទេ ឧទាហរណ៍សម្លាប់ឈ្មោះនេះ ឈ្មោះនោះ ពីភូមិរបស់លោក?

**ឆ៖** បាទ អត់មានទេ អត់បញ្ជាក់ គ្មានទេ។

**ស៖** ឥឡូវចូលដល់ការងាររបស់លោកនៅទំនប់ ១មករា។ អ្នកណាជាអ្នកឲ្យលោកទៅធ្វើការនៅទំនប់ ១មករា រយៈពេលបីខែហ្នឹង?

**ឆ៖** បាទ ជំនាន់ហ្នឹងប្រធានឃុំៗ គេឲ្យទៅធ្វើ ចាត់ចែងឲ្យទៅធ្វើទំនប់ ១មករា បាទ។ ចាត់តាំងឲ្យទៅធ្វើ បីខែ ឲ្យរែកដី បីខែ។

[១៥:១៦:២៥]

**ស៖** តើគេណែនាំឲ្យលោកធ្វើអ្វី ឲ្យលោកគិតគូរការងារដោយខ្លួនឯង ឬក៏ឲ្យអ្នកភូមិដែលគេបានជ្រើសរើសអ្នកភូមិទៅធ្វើការនៅឯទំនប់ហ្នឹង? តើគេចាត់តាំងឲ្យលោកធ្វើអី ឬក៏ឲ្យលោកធ្វើការដោយគិតដោយខ្លួនឯង?

**ឆ៖** បាទ កាលហ្នឹង គឺខ្ញុំក្តាប់មនុស្សនៅហ្នឹងភូមិខ្ញុំ គឺធ្វើការហ្នឹង។ ភូមិណាគឺក្តាប់ភូមិហ្នឹង គឺរៀងៗខ្លួន ប្រធានណាគេក្តាប់រៀងៗខ្លួន ដូចថា ភូមិកងសៅ អ៊ីចឹង ខ្ញុំនៅកងសៅ ក្តាប់ភូមិហ្នឹងទៅ។ គេនៅភូមិខ្វែក គេក្តាប់ភូមិខ្វែកទៅបាទ។ អាហ្នឹងគេកំណត់ពីឃុំទៅអ៊ីចឹង គេចាត់ចែងអ៊ីចឹងបាទ។

**ស៖** ដូច្នេះ លោកបានជ្រើសរើសប្រជាជនពីភូមិរបស់លោក។ តើលោកខ្លួនឯងហ្នឹងធ្វើពលកម្មនៅទំនប់ ១មករា ដូចអ្នកដទៃដែរទេ លោកមានកាប់ដី រែកដីដូចគេដែរទេ?

**ឆ៖** បាទ គឺខ្ញុំនេះវា -- អានេះនិយាយទៅក្រែងអស់លោក អត់ជឿ។ ក្នុងជំនាន់នោះ ក្នុងពេលនោះ គឺខ្ញុំធ្វើខ្លាំងណាស់បាទ រែកមិនស្គាល់ស្លាប់ មិនស្គាល់រស់ ដេកដួល មិនថាឈឺ មិនថាបានដឹកនាំប្រជាពលរដ្ឋ។ ក្រែងលោប្រជាពលរដ្ឋខ្ជិលច្រអូសទៅក្រែងគេអ្នកដឹកនាំថ្នាក់លើនេះគេថា រឿងនេះរឿងនោះ ត្រូវការសម្លាប់គ្នាទៀត។ ដូច្នេះ ដឹកនាំ ចេះតែនាំធ្វើទៅ ឥឡូវឲ្យគ្នាដេកដួលទៅ មិនដឹកនាំទៅខ្លាចគេចោទប្រកាន់ត្រង់ហ្នឹង ងាប់អានៅហ្នឹងទៀត បាទ ចេះតែដឹកនាំទៅ។ ប្រធានហើយដឹកនាំមុខគេបាទ រឿងកាប់ដី កាប់អីរែកទាំងអស់តែគ្នាឯង គ្មានប្រធាន ហើយមិនរែកមិនរែកដីទេបាទ កោងខ្នងតែរហូត។

[១៥:១៨:៤០]

**ស៖** ប្រសិនបើលោកធ្វើការលំបាកលំបិនការដ្ឋាន តើ អ៊ុត សេង ពិតជាបានឃើញលោក កាប់ដី រែកដី នៅឯទំនប់នោះ ដែរឬទេ?

**ឆ៖** បាទ កាលនោះ ខ្ញុំមិនដឹង អ៊ុត សេង ឯណា ខ្ញុំមិនស្គាល់ផង ទើបឮនិយាយថា អ៊ុត សេង ខ្ញុំអត់ស្គាល់ផង អត់ដឹង អ៊ុត សេង ណាផង។

**ស៖** បានឆ្លើយនៅក្នុងថ្ងៃដដែលនៅប្រហែលជាម៉ោងប្រាំបួន សាមសិបបួន សូមដកស្រង់៖ "គាត់កម្រទៅការដ្ឋានទំនប់ ១មករា ណាស់។ ភាគច្រើនគាត់នៅភូមិ។ អ៊ីចឹងភាគច្រើនគឺគាត់ស្នាក់នៅភូមិដើម្បីតាមដានប្រជាជន១៧មេសា"។ ហើយមកក្រោមទៀត នៅម៉ោងដប់ប្រាំ សាមសិបប្រាំ "ខ្ញុំបានឃើញគាត់ ជិះកាត់ទៅហ្នឹង គាត់គ្រប់គ្រងប្រជាជននៅភូមិ នៅភាគខាងត្បូង ហើយគាត់ទៅមើលប្រជាជននៅការដ្ឋានហ្នឹងដើម្បីចង់ដឹងថាតើប្រជាជនហ្នឹងធ្វើការឬក៏អត់ ពីភូមិកងសៅហ្នឹង"។ នេះគឺសក្ខីកម្មរបស់គាត់ ពាក់ព័ន្ធទៅនឹងពលកម្មដោយផ្ទាល់ដែររបស់លោកនេះ។ តើការដែលគាត់ឆ្លើយបែបនេះត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវទេ?

**ឆ៖** បាទ គឺគាត់ឆ្លើយរបៀបនេះ គឺមិនត្រឹមត្រូវទេ ព្រោះគាត់ យោបល់គាត់ មតិគាត់ឆ្លើយហ្នឹងគឺមិនត្រឹមត្រូវទេ។ ម្យ៉ាងទៀតគឺគាត់ឃើញតែមួយប្រឡោះៗ។ ខ្ញុំអត់ថាត្រឹមត្រូវទេ។

[១៥:២០:៤០]

**ស៖** ដូច្នេះតើវាត្រឹមត្រូវដែរឬទេថា លោកខ្លួនឯងហ្នឹងគឺជាអ្នកបង្ខំខ្លួនឯងធ្វើការទាំងយប់ទាំងថ្ងៃ ដែលត្រូវរែកកាប់ដីហ្នឹង ៤ម៉ែត្រគូបក្នុងមួយថ្ងៃ អ៊ីចឹងមែនទេ?

**ឆ៖** បាទ គឺកាប់អ៊ីចឹងមែនបាទ។ ប្រជាពលរដ្ឋទាំងអស់ក៏ដឹងឮ ក៏ដឹងច្បាស់ដែរ បាទមិនមែនថាខ្ញុំនិយាយហើយ គេមិនជឿទេបាទ គឺវាអ៊ីចឹងតែម្តង។ រាប់ខេត្ត ក្នុងខេត្តទាំងមូលក៏ពីណាគេដឹងដែរ ផែនការរបស់គេ។ ពិសេសមែនទែន ខ្ញុំអ្នកដែលផ្ទាល់ហ្នឹង គឺទាំងអស់គ្នាប្រជាជននៅហ្នឹង។ អ៊ីចឹងធ្វើហ្នឹងគឺវាច្បាស់ណាស់ អត់មានអង្គណានិយាយថាមិនមែនទេ។ បើនិយាយថាមិនមែនហ្នឹង ភ្នែកហ្នឹងខ្វាក់តែម្តងបាទ។

**ស៖** លោកសាក្សី គឺលោកបានឆ្លើយនូវអ្វីដែលខ្ញុំរៀបនឹងសួរទៅហើយ។ តើលោកដឹងថា មានអ្នកណាម្នាក់រស់រានរហូតដល់សព្វថ្ងៃ ដែលអាចឆ្លើយឲ្យស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់លោក? ថាលោកដើរទៅធ្វើការនៅទំនប់១មករា រែកដីទាំងយប់ទាំងថ្ងៃដូចគេដូចឯង? តើលោកអាចបង្ហាញឈ្មោះ

មនុស្សម្នាក់ដែលរស់រហូតដល់សព្វថ្ងៃ បញ្ជាក់ថាលោកពិតជាធ្វើបែបនេះមែនទេ?

**ឆ៖** បាទ គឺមនុស្សដែលធ្វើជាមួយខ្ញុំសព្វថ្ងៃ គឺស្លាប់ហើយ បាទស្លាប់អស់ហើយ។ ប្រធានភូមិកងសៅគឺស្លាប់អស់ហើយ ដែលធ្វើជាមួយខ្ញុំ ចុះរែកដីជាមួយខ្ញុំ ដែលប្រជាជនគាត់ផ្ទាល់ក្នុងភូមិកងសៅនេះធ្វើជាមួយខ្ញុំ ក៏គាត់ស្លាប់ហើយ អាហ្នឹងរែកដីជាមួយខ្ញុំ។ បើអត់ពីខ្ញុំទៅៗ គាត់រែកទៅៗ បាទរែកទៅ។ អាហ្នឹងអ៊ីចឹង ផ្លាស់ប្តូរគ្នា មិនមែនឲ្យទៅម្នាក់ៗ ជូនអីទៅទាំងអស់គ្នាទៅ។ អ្នកដែលថាខ្ញុំមិនធ្វើ មិនឃើញខ្ញុំទៅហ្នឹង ដូចជាថាមិនច្បាស់ទេ បាទមិនច្បាស់ទេតែម្តង។

[១៥:២៣:១២]

**ស៖** ដូច្នេះចម្លើយរបស់លោក គឺថាអ្នកភូមិម្នាក់ៗដែលធ្វើការជាមួយលោករយៈពេលបីខែនៅទំនប់១មករាហ្នឹង គឺថាឥឡូវនេះស្លាប់អស់ហើយ ហើយមិនមានអ្នកណានៅរស់រានដើម្បីឆ្លើយបញ្ជាក់អំពីចម្លើយរបស់លោកនេះទេ មែនទេ?

**ឆ៖** បាទ គឺស្លាប់អស់ហើយ ដែលគាត់ធ្វើប្រធាននៅនឹងភូមិហ្នឹងជាមួយខ្ញុំហ្នឹង។ គាត់ស្លាប់ហើយ ទាំងបីបួននាក់ហ្នឹងស្លាប់អស់ហើយ បាទ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកៗមេធាវីជាតិការពារក្តីលោក នួន ជា!

**លោក លីវ សុវណ្ណា៖**

បាទ សូមគោរពលោកប្រធាន សូមគោរពលោកចៅក្រម លោក លោកស្រីចៅក្រម សូមគោរពអង្គសវនាការ។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** សូមជម្រាបលោកសាក្សី ខ្ញុំឈ្មោះ លីវ សុវណ្ណា ជាមេធាវីក្រុមការពារក្តីលោក នួន ជា សុំតាំងសំណួរមួយចំនួនបន្ថែម។ នៅក្នុងកំណត់ហេតុយកចម្លើយរបស់លោកដែលមានលេខ D166/156 ត្រង់ ERN ជាភាសាខ្មែរមានលេខ 00321787, ជាភាសាអង់គ្លេសមានលេខ 00350720, ជាភាសាបារាំងមានលេខ 00402983។ លោកបានមានប្រសាសន៍ថា ខ្ញុំត្រូវបានគេ -- ខ្ញុំសូមដកស្រង់៖ "ខ្ញុំត្រូវបានគេបញ្ជូនឲ្យទៅរែកដីនៅការដ្ឋាននោះអស់រយៈពេលបីខែ។ ខ្ញុំមិនចាំថា ខ្ញុំទៅទីនោះនៅពេលណាទេ

ប៉ុន្តែខ្ញុំទៅមុនពេលដែលខ្ញុំចូលធ្វើជាឈ្លបឃុំ"។ អ៊ីចឹងសំណួរខ្ញុំៗសួរថាតើពេលដែលលោកត្រឡប់មកពីទំនប់១មករាវិញនោះ បានប៉ុន្មានខែបានគេជ្រើសរើសលោកធ្វើជាឈ្លបឃុំ?

[១៥:២៥:៣៩]

**លោក យាន លន់៖**

**ឆ៖** អត់យល់ទេបាទ។

**ស៖** បាទ ខ្ញុំសូមតាំងសំណួរជាថ្មី។ លោកបានមានប្រសាសន៍ហើយថា លោកបានទៅធ្វើការនៅទំនប់១មករាហ្នឹង គឺមុនពេលដែលលោកបានធ្វើជាឈ្លបឃុំ អ៊ីចឹងសំណួរខ្ញុំថា រយៈពេលបីខែដែលលោកធ្វើការចប់នៅទំនប់១មករាហើយ ត្រឡប់មកវិញ តើបានប៉ុន្មានខែបានគេជ្រើសរើសលោកឲ្យធ្វើជាឈ្លបឃុំ?

**ឆ៖** ស្តាប់អត់យល់ទេបាទ ស្តាប់អត់បានបាទ។

**ស៖** ចម្លើយៗរបស់លោកដែលខ្ញុំអាន -- បាទ ខ្ញុំសូមតាំងសំណួរសារជាថ្មី។ ចម្លើយរបស់លោកដែលខ្ញុំបានអានជូនលោកស្តាប់អម្បាញ់មិញហ្នឹងថា លោកហ្នឹងត្រូវបានគេបញ្ជូនឲ្យទៅរែកដីនៅការដ្ឋានទំនប់១មករាហ្នឹង អស់រយៈពេលបីខែ ហើយលោកអត់ចាំថាទៅពេលណាទេ គ្រាន់ដឹងថាពេលដែលលោកទៅលើកទំនប់ហ្នឹង គឺមុនពេលដែលលោកត្រូវបានគេជ្រើសតាំងឲ្យធ្វើជាឈ្លបឃុំ។ អ៊ីចឹងខ្ញុំសួរថាតើ ពេលដែលលោក -- មុនពេលដែលគេជ្រើសតាំងឲ្យលោកធ្វើឈ្លបឃុំហ្នឹង លោកទៅរែកដីហ្នឹង បីខែត្រឡប់មកវិញហ្នឹង តើមកវិញ ត្រឡប់មកវិញបានប៉ុន្មានខែ បានគេជ្រើសរើសតាំងលោកជាមេឃុំ -- ជាឈ្លបឃុំបាទ?

[១៥:២៧:៣៤]

**ឆ៖** បាទ ខ្ញុំភ្លេចហើយ បាទ ភ្លេចហើយ វង្វេងវង្វាន់អស់ហើយបាទ មិនដឹងជាប៉ុន្មានខែ ភ្លេចអត់ចាំបាទ។

**ស៖** លោកអាចសាកល្បងរកនឹងមើលថាតើ ពេលដែលលោកត្រឡប់មកពីរែកដីវិញ លោកត្រូវធ្វើអីគេខ្លះ? ហើយបន្ទាប់មកបានធ្វើអីទៀតបាទ?

**ឆ៖** វាភ្លេចហើយបាទ ភ្លេចហើយ ខ្ញុំភ្លេចហើយបាទ អត់ចាំ។

**ស៖** អត់អីអីចឹង បាទអរគុណ អ៊ីចឹងខ្ញុំសូមទៅសំណួរថ្មី។ ហើយនៅក្នុងឯកសារដដែលហ្នឹងដែលមានលេខ ERN ជាភាសាខ្មែរហ្នឹង គឺមានលេខ 00321786, ជាភាសាអង់គ្លេសមានលេខ

00330719, ជាភាសាបារាំងមានលេខ 00402982។ លោកបានឆ្លើយថា ខ្ញុំសូមដកស្រង់៖ “ខ្ញុំធ្លាប់ធ្វើជាសមាជិកឈ្លបឃុំអស់រយៈពេលពីរខែក្នុងឆ្នាំ១៩៧៦”។ អ៊ីចឹងសំណួរខ្ញុំសួរថាតើក្នុងឆ្នាំ១៩៧៦ ដែលគេជ្រើសរើសលោកធ្វើជាសមាជិកឈ្លបឃុំហ្នឹង ក្នុងខែណាដែរបាទ?

**ឆ៖** បាទ ក្នុងខែអត់ចាំបាទ ចាំតែឆ្នាំទេបាទ អត់ចាំខែទេ។

[១៥:២៩:៣៣]

**ស៖** តើពេលហ្នឹងជារដូវប្រាំង ឬក៏រដូវវស្សា?

**ឆ៖** ពេលនោះ ក៏ខ្ញុំភ្លេចដែរ មិនដឹងរដូវប្រាំង មិនដឹងរដូវវស្សាបាទ។ អត់ចាំទេបាទ សូមទោសបាទអត់ចាំ។

**ស៖** បាទ អ៊ីចឹងខ្ញុំសូមបន្តទៀត។ ពេលដែលលោកទៅ អះអាងថាលោកទៅជីកដីនៅទំនប់១មករាហ្នឹង ពេលលោកទៅដល់ហ្នឹង ឃើញគេកំពុងជីកហើយ ឬមួយក៏លោកជាក្រុមទី១ ដែលទៅចាប់ផ្ដើមជីក?

**ឆ៖** បាទ ដំបូងគឺអត់ទាន់មានជីកទេ គឺដំបូងគេបើក ទៅដល់បើកឆាក ដូចថាមេធំៗគេទៅហ្នឹងឲ្យយើងវែកដីសិន អត់ទាន់មានគិតគូប គិតអីទេ ឲ្យគ្រាន់តែវែកដីឲ្យគេឃើញសិន។ បាទដំបូងមកអានេះនិយាយតាមដែលគេធ្វើមក គឺឲ្យនាំប្រជាជនពលរដ្ឋហ្នឹង ទៅវែកឲ្យគេមើលសិន គេទៅឈរមើលហ្នឹង ឲ្យប្រជាពលរដ្ឋហ្នឹង វែករត់ វែកលូនអ៊ីចឹងទៅ អត់ទាន់មានចែកទៅជាគូបអីទេ ដល់រួចទៅបានចែកទៅជាគូបក្រោយទៀតបាទ។

**ស៖** បាទ សំណួរខ្ញុំចង់ដឹងថា តើលោកទៅហ្នឹងគឺជាក្រុមទី១ដែលត្រូវទៅចាប់ផ្ដើមជីកដំបូង ឬពេលដែលលោកទៅហ្នឹង ឃើញគេមានក្រុមផ្សេង គេកំពុងតែជីកទំនប់នោះរួចហើយបាទ?

**ឆ៖** បាទ បើកឆាកដំបូងមិនទាន់មានគេជីកទេបាទ គឺដូចខ្ញុំនិយាយអំមិញហ្នឹង គឺអ្នកធំៗ គេមកឲ្យយើងទៅកាប់ហ្នឹង ឲ្យគេមើលសិន បើកឆាកហ្នឹងឲ្យគេមើលសិន មនុស្សរាប់ម៉ឺន រាប់ពាន់ហ្នឹងឲ្យគេមើលសិន បានថ្ងៃក្រោយ បានគេវាស់ទៅជាគូបៗ គិតគូប គិតរណ្ដៅ គេដាក់កំណត់អ៊ីចឹងហ្នួងបាទ។

[១៥:៣២:០២]

**ស៖** បាទ អរគុណ។ លោកបានផ្ដល់សក្ខីកម្មអំមិញថា លោកត្រូវបានគេឲ្យ បង្គាប់ឲ្យចាប់ខ្លួនមនុស្ស។ តើការចាប់នោះ គឺចាប់នៅទីកន្លែងណាដែរ នៅក្នុងភូមិ ឬមួយចាប់នៅកន្លែងណាផ្សេង?

**ឆ៖** ចាប់នៅហ្នឹងកន្លែងធ្វើការកងចល័ត កងអីហ្នឹង។ ចាប់នោះ មនុស្សខុសសីលធម៌ វាប៉ះពាល់សីលធម៌ដែរ គេឲ្យនាំទៅកន្លែងត្បែងកោង ហើយក៏ ដើម្បីមនុស្សហ្នឹងក៏ត្រឡប់មកវិញមកគេអប់រំ មកផ្ទះវិញមក មិនមែនចាប់ទៅសម្លាប់ទេបាទ។

**ស៖** អ៊ីចឹងលោកដែលឃើញគេចាប់មនុស្សយកទៅសម្លាប់ដែរទេ?

**ឆ៖** បាទ អត់ច្បាស់ម្តងទៀតបាទ សូមទោស។

**ស៖** លោកធ្លាប់ឃើញគេចាប់មនុស្សយកទៅសម្លាប់ផ្ទាល់ភ្នែកដែរឬទេ?

**ឆ៖** បាទ គឺនៅកន្លែងមន្ទីរត្បែងកោង គឺមានឃើញ គេចាប់យកទៅដាក់កន្លែងត្បែងកោងហ្នឹង ប៉ុន្តែមិនដឹងគេយកទៅសម្លាប់ មិនដឹងគេយកទៅណាទេបាទ គេចាប់ ប្រាកដជាចាប់ហើយ ទៅកន្លែងត្បែងកោងហ្នឹងបាទ ឈ្លបគេចាប់យកទៅហើយ ឈ្លបឃុំគេនោះ។

[១៥:៣៤:៣៥]

**ស៖** អ៊ីចឹងបើខ្ញុំសង្ខេបថា លោកបានដឹងថាឃើញគេចាប់ ប៉ុន្តែមិនដឹងថាគេយកទៅណា សម្លាប់ឬមិនសម្លាប់ លោកអត់បានដឹងទេ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ គឺខ្ញុំដឹងតែប៉ុណ្ណឹងបាទ ឃើញគេអ៊ីចឹង គឺថាតែប៉ុណ្ណឹង។

**ស៖** មុននេះលោកបានផ្តល់សក្ខីកម្មថា ការចាប់មនុស្សហ្នឹង គឺចាប់មនុស្សដែលប្រព្រឹត្តកំហុសដូចជាលួច។ អ៊ីចឹងមានន័យថា ការចាប់ហ្នឹង គឺមិនមែនជាការចាប់ដោយសារជាប់និន្នាការ ជាទាហានលន់ លន់ ឬជាគ្រូបង្រៀនក្នុងរបបលន់ នល់ ឬក៏ជាអ្នករាជការក្នុងរបបលន់ នល់ ទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន បាទ។

**លោក លីវ សុវណ្ណា៖**

បាទ ខ្ញុំសូមអរគុណ។ ខ្ញុំបាទអស់សំណួរ បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាចុងក្រោយនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

[១៥:៣៦:១៩]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ហើយខ្ញុំសូមចោទសំណួរមួយចំនួនទៅលោក។ ដើម្បីត្រឡប់មកនិយាយអំពីពេលដែលលោកធ្វើការនៅទំនប់១មករា បើខ្ញុំយល់មិនច្រឡំទេ គឺថាលោកធ្វើការនៅទំនប់នោះ មុនពេលនៅពេលដែលបានគេតែងតាំងលោកធ្វើជាឈ្លប តើអ៊ីចឹងមែនទេ?

**លោក យាន លន់៖**

**ឆ៖** បាទ អត់ទេ គឺខ្ញុំដែលឈ្លបនោះ នៅនឹងភូមិទេ។ អត់មានចូលនឹងឈ្លបឃុំទេ បាទ។ នៅឈ្លបនៅតាមភូមិទេ។ ឈ្លបឃុំគេផ្សេង ដាច់ឡែក ដោយផ្សេងទៅ។

**ស៖** ខ្ញុំសូមអរគុណដែលបានឆ្លើយបំភ្លឺ។ ក៏ប៉ុន្តែអ្វីដែលខ្ញុំចាប់អារម្មណ៍នោះ គឺថាមុននឹងធ្វើជាឈ្លបហ្នឹង គឺលោកបានធ្វើការនៅទំនប់១មករាសិន។ អ៊ីចឹងបានន័យថា ខ្ញុំចង់ដឹងថាលោកធ្វើការនៅទំនប់ហើយ ហើយក្រោយមកបានគេឲ្យលោកធ្វើឈ្លប។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ គឺត្រឹមត្រូវ។

**ស៖** ក្នុងរយៈពេលបីខែហ្នឹងគឺលោកធ្វើការជាមួយប្រជាជន ហើយថែមទាំងធ្វើការលើសប្រជាជនទៀតផង។ តើលោកជាអ្នកទទួលខុសត្រូវ -- ខ្ញុំសូមកែសំណួរខ្ញុំឡើងវិញ។ លោកដែលជាមេកងមនុស្សប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ មេកង ខ្ញុំក្តាប់មួយភូមិខ្ញុំទេបាទ។ មួយភូមិកងសៅ ដែលខ្ញុំក្តាប់ហ្នឹង ខ្ញុំក្តាប់មួយភូមិហ្នឹងទេ។ មួយភូមិណា គឺក្តាប់ភូមិហ្នឹង បាទ។

[១៥:៣៨:៥២]

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែខ្ញុំចង់សួរលោកថាតើក្នុងភូមិរបស់លោកហ្នឹង ដែលលោកជាប្រធានកងហ្នឹង តើកូនក្រុមរបស់លោកមានចំនួនប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ អត់ចាំទេ គឺច្រើនណាស់ បាទ។ គឺប្រជាជនមួយភូមិទៅហើយ គឺភ្លេចទៅហើយ សូមទោស។ ភ្លេចហើយ មិនចាំទេ។

**ស៖** លោកមិនបាច់ឲ្យលេខជាក់លាក់ទេ។ លោកអាចប្រាប់តុលាការថា ប្រហែល១០នាក់ ២០នាក់ ឬ១០០នាក់ ហើយក៏ឲ្យគំលាតតួលេខមើល ពីប៉ុន្មានទៅប៉ុន្មាន ប្រហាក់ប្រហែល?

**ឆ៖** បាទ បើស្មានស្មង់ស្មានទៅ ប្រហែលជា៥០-៦០នាក់ ម៉ាខ្ញុំក្តាប់ហ្នឹង ដែលទៅធ្វើទំនប់

ប្រឡាយហ្នឹង។ ប្រហែលជា៥០នាក់ ៦០នាក់ បាទ។

**ស៖** លោកផ្ទាល់ លោកជាអ្នកទទួលខុសត្រូវលើមនុស្សទាំង៥០-៦០នាក់ហ្នឹង។ អ៊ីចឹងនៅទំនប់ ១មករាហ្នឹង ខ្ញុំសួរលោកថា អ្នកណាជាមេលោក?

**ឆ៖** បាទ ប្រធានឃុំ។

**ស៖** តើជាការត្រឹមត្រូវដែរឬទេ ដែលថាមេឃុំនោះមិនស្ថិតនៅលើទំនប់ ១មករា នោះជាប្រចាំទេដោយសារគាត់មានការងារផ្សេងទៀតនៅក្នុងឃុំ។ អ៊ីចឹងប្រធានភូមិហ្នឹងហើយដែលគ្រប់គ្រងប្រជាជនដែលធ្វើការនៅទំនប់នោះជាប្រចាំ។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ គឺត្រឹមត្រូវ អ៊ីចឹងមែន ព្រោះប្រធានឃុំគេមិនសូវចុះជាប់ទេ គេនៅតែ -- បើប្រធានឃុំខ្លះគេនៅតែហូបស្រាហូបអី នៅមន្ទីរអ៊ីចឹងទៅ រឿងចុះជាប់ជាមួយប្រជាពលរដ្ឋគឺខ្ញុំថាតិចណាស់។ តិចហ្នឹងបានចុះជាប់ណាស់ មានតែប្រធានកង ប្រធានក្រុមអីទេ ចុះជាប់។

**ស៖** នៅក្នុងកងរបស់លោកហ្នឹង តើមានប្រធានក្រុមតូចៗទេ នៅក្នុងកងរបស់លោក ឬនៅក្នុងភូមិលោកហ្នឹង ដែលមានមនុស្ស ៥០-៦០នាក់ហ្នឹង មានក្រុមតូចៗទេ? ហើយបើក្រុមតូចៗ នីមួយៗមានប្រធានកូនក្រុមតូចៗហ្នឹងដែរឬទេ?

**ឆ៖** បាទ គឺបំបែកទៅជាក្រុមៗ ១២នាក់ៗ អ៊ីចឹងធ្វើការតាមក្រុមៗបាទ។ រែកដីចែកតាមក្រុមៗ។ ធ្វើការដកស្ទូងអីក៏ចែកតាមក្រុមៗគ្នា ប៉ុន្តែខ្ញុំ ខ្ញុំក្តាប់រួមនៅហ្នឹងភូមិហ្នឹង ខ្ញុំចុះជាប់រាល់ថ្ងៃដកក៏ដោយ ស្ទូងក៏ដោយ ធ្វើប្រឡាយក៏ដោយ បាទ។

[១៥:៤២:៣៣]

**ស៖** ខ្ញុំមិនដឹងថា ខ្ញុំមានបញ្ហាមិនសូវយល់គ្នាទេ ឥឡូវនេះ ខ្ញុំកំពុងតែនិយាយអំពីរយៈពេលមួយដែលលោកធ្វើការនៅទំនប់ ១មករា តើនៅទំនប់ ១មករា នោះ លោកស្ទូងស្រូវដែរ ឬក៏យ៉ាងណា?

**ឆ៖** បាទ ក្នុងពេលនោះ គឺអត់ទាន់បានស្ទូងទេ គឺប្រយុទ្ធរែកដីសិន។ គឺដល់ពេលទឹកភ្លៀងមកបាននាំបងប្អូនធ្វើស្រែ។ ពេលនោះ ពេលមិនទាន់បានស្ទូងដកទេ គឺធ្វើទំនប់ប្រឡាយសិន។ គេឲ្យធ្វើទំនប់ប្រឡាយ បង្ខំឲ្យធ្វើ។ ដូច្នេះដល់ខែស្រែ បានដកមនុស្សទាំងអស់ហ្នឹង គ្រប់ភូមិទាំងអស់មកធ្វើស្រែចិញ្ចឹមជីវិតវិញ បាទ។

**ស៖** ឥឡូវនេះ ខ្ញុំសូមការបំភ្លឺមួយ លោកបាននិយាយថាលោកបានធ្វើការនៅទំនប់១មករា នោះរយៈពេលបីខែ ហើយបើតាមការចងចាំរបស់ខ្ញុំនោះ គឺថានៅរដូវប្រាំង លោកធ្វើការហ្នឹង។ តើយើង

យល់អ៊ីចឹង ត្រឹមត្រូវដែរឬទេ គឺថាលោកធ្វើការនៅរដូវប្រាំងរយៈពេលបីខែទេ លើទំនប់ ១មករា ហ្នឹង?

**ឆ៖** បាទ គឺធ្វើខែប្រាំង បាទ ធ្វើ គឺធ្វើអ៊ីចឹងហើយល្អ ខែប្រាំង។ ដល់ខែវស្សាមក ដកមកធ្វើស្រែវិញបាទ។

**ស៖** តើរយៈពេលបីខែហ្នឹង ដែលលោកធ្វើការនៅទំនប់ហ្នឹង គឺប្រព្រឹត្តទៅដោយជាប់រហូត ឬក៏មានចន្លោះគ្នាដែរ លោកធ្វើការនៅលើទំនប់ហ្នឹងខ្លះ ក្រោយមកលោកមកស្ទូងខ្លះ ហើយចេញពីស្ទូងទៅ ទៅធ្វើការនៅលើទំនប់ហ្នឹងទៀត ខ្ញុំចង់សួរថាបីខែហ្នឹងធ្វើជាប់រហូត ឬក៏មានអាក់ខានមកស្ទូងដែរ?

**ឆ៖** បាទ ក្នុងបីខែហ្នឹងគឺដកឃ្លាមកស្ទូងខ្លះ ធ្វើបាទ មកដកស្ទូង ក្នុងបីខែហ្នឹងមានដកស្ទូង។ មិនធ្វើជាប់ទាំងបីខែតែម្តងទេបាទ។ ដល់ពេលស្ទូងរួច គឺមានផែនការធ្វើទៅទៀត រែកដីទៀត ច្រូតកាត់អីរួច ប្រមូលផលអីបានរួច ចាប់ផ្តើមទៀត។

[១៥:៤៥:៣៤]

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេ គឺថានៅពេលដែលភ្លៀងធ្លាក់ មិនមានការធ្វើការនៅទំនប់នោះទេ យ៉ាងហោចណាស់ក៏សម្រាប់ប្រជាជននៅក្នុងភូមិលោកដែរ មិនមានអ្នកណាទៅធ្វើការនៅទំនប់ហ្នឹងទេពេលភ្លៀង រដូវភ្លៀង។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែនបាទ។

**ស៖** តើអ្នកណាជាអ្នកឲ្យលោកទៅស្ទូងស្រូវនៅពេលភ្លៀងនោះ?

**ឆ៖** បាទ គឺផែនការគេដាក់ចុះពីឃុំទៅបាទ។ គេឲ្យប្រមូលកម្លាំងមកពលកម្មវិញ ធ្វើស្រែវិញ។

**ស៖** អ៊ីចឹងគឺបានសេចក្តីថា មេឃុំជាអ្នកចេញបញ្ជាឲ្យលោកទៅស្ទូងស្រូវ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែនបាទ។

**ស៖** ពេលលោកឆ្លើយនៅទីនេះ លោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាអន្តរជាតិ -- ជាតិ លោកបាននិយាយថា នៅពេលដែលលោកធ្វើការនៅលើទំនប់នោះ គឺប្រហែលជាក្នុងពាក់កណ្តាលកម្ពុជាប្រជាធិបតេយ្យ។ លោកចង់និយាយយ៉ាងម៉េចដែរ គឺថានៅពេលកណ្តាលរបបកម្ពុជាប្រជាធិបតេយ្យនេះ? លោកអាចពន្យល់បានទេ នៅពេលណា?

**ឆ៖** បាទ គឺពាក់កណ្តាលរបបប្រជាធិបតេយ្យហ្នឹង ការធ្វើការងារចំពោះប្រជាពលរដ្ឋហ្នឹង

ដែលធ្វើហ្នឹងគឺ កន្លែងណាតឹងៗ កន្លែងណាដែលត្រូវធ្វើបង្ខំប្រជាពលរដ្ឋឲ្យធ្វើទាំងយប់ទាំងថ្ងៃ ដកៗក៏យប់ ស្ទូងក៏យប់ បាទមានភ្លើងចន្លុះ ជាក់ស្ដែងគឺភូមិ មិនមែនភូមិ--

[១៥:៤៨:០១]

**ស៖** លោកសាក្សី ខ្ញុំសូមកាត់ផ្ដាច់លោក សូមទោស ព្រោះថាយើងមានពេលវេលាតិចតួច។ ខ្ញុំសូមឲ្យលោកស្ដាប់សំណួរខ្ញុំឲ្យច្បាស់លាស់។ ខ្ញុំសួរ អម្បាញ់មិញនេះខ្ញុំសួរលោកថា តើពេលដែលលោកនិយាយថា នៅពាក់កណ្ដាលរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺមានន័យថាយ៉ាងម៉េច? ពីព្រោះថារបបខ្មែរក្រហមចាប់ផ្ដើមពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ មករា ឆ្នាំ១៩៧៩។ អ៊ីចឹងនៅពេលដែលលោកនិយាយថា ពាក់កណ្ដាលរបបនេះ គឺថានៅចំពាក់កណ្ដាលរបបខ្មែរក្រហមហ្នឹងហើយ ដែលលោកធ្វើការនៅលើទំនប់១មករាហ្នឹង។ អ៊ីចឹងខ្ញុំចង់សួរលោក ថាតើនៅពេលណាឲ្យប្រាកដតែម្ដងនោះ? នៅពេលណាដែរ?

**ឆ៖** អត់ស្ដាប់អត់បាន អត់យល់បាទ។ ម្ដងទៀតបាទ។

**ស៖** អម្បាញ់មិញ នៅពេលដែលលោកឆ្លើយទៅនឹងព្រះរាជអាជ្ញាអន្តរជាតិ លោកបាននិយាយថាលោកបានធ្វើការនៅទំនប់១មករាហ្នឹងប្រហែលជាពាក់កណ្ដាលរបបកម្ពុជាប្រជាធិបតេយ្យ។ ដោយយើងទាំងអស់គ្នាដឹងហើយថា របបខ្មែរក្រហម ឬកម្ពុជាប្រជាធិបតេយ្យហ្នឹងលាតសន្ធឹងពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ មករា ឆ្នាំ១៩៧៩។ អ៊ីចឹងខ្ញុំចង់សួរលោកថា នៅពេលដែលលោកនិយាយថានៅចំពាក់កណ្ដាលរបបកម្ពុជាប្រជាធិបតេយ្យនេះ លោកសំដៅទៅលើពេលណាមួយ? លោកអាចឲ្យរយៈពេលប្រហាក់ប្រហែលបានទេ? កាលបរិច្ឆេទប្រហាក់ប្រហែលនៅពេលណាឲ្យប្រាកដតែម្ដង?

**ឆ៖** បាទ ពេលនោះគឺឆ្នាំ៧៥, ៧៦ ដែលប្រាកដដែលមានការលំបាកខ្លាំងជំនាន់នោះ ៧៥, ៧៦ ពិបាក។ ពិបាកម៉េចទេ? ពិបាកត្រង់ថា ប្រជាពលរដ្ឋប្រមូលដាក់ឆ្នាំងសម្ភារៈតាំងអស់ តាំងពីដើមដូង តាំងពីដើមត្នោត តាំងពីដើម-- តាំងពីស្លឹកគ្រៃ គឺដាក់រួមទាំងអស់បាទ អានេះគឺ--

[១៥:៥០:៣៧]

**ស៖** លោកសាក្សី ខ្ញុំសូមទោស ខ្ញុំសូមកាត់ផ្ដាច់លោកពីព្រោះថាលោកមិនឆ្លើយនឹងសំណួរខ្ញុំទេឥឡូវខ្ញុំសូមរៀបរាប់សំណួរឡើងវិញ។ នៅក្នុងចម្លើយរបស់លោកគឺថា ឯកសារ D166/156, ERN ជាភាសាបារាំងគឺ 00402982, ជាភាសាអង់គ្លេសគឺ 00330719, ជាភាសាខ្មែរ 00321786។

នៅក្នុងឯកសារនេះ លោកបាននិយាយថា៖ "ខ្ញុំជាឈ្លបនៅក្នុងឃុំហ្នឹងរយៈពេលពីរខែ នៅក្នុងឆ្នាំ១៩៧៦" សូមបញ្ចប់ការដកស្រង់។ អ៊ីចឹង ខ្ញុំចង់ដឹងថា នៅពេលដែលលោកឆ្លើយថាលោកជាសមាជិកឈ្លបឃុំ អស់រយៈពេលពីរខែហ្នឹង លោកចង់និយាយសំដៅទៅលើពេលដែលលោកធ្វើជាឈ្លបមែនទេ?

**ឆ៖** បាទ ខ្ញុំធ្វើឈ្លបបានពីរខែ រួចពីហ្នឹងទៅ គេដកខ្ញុំមក ទៅកាប់ឈើធ្វើផ្ទះរបប។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកដដែល នៅទំព័របន្ទាប់នោះគឺជា ERN ជាភាសាបារាំងគឺ 00402983, ជាភាសាអង់គ្លេស 00330720, ជាភាសាខ្មែរគឺ 00321787។ បាទ សំណួរដែលគេចោទសួរទៅលោកនោះគឺថា "តើលោកឈប់ធ្វើជាឈ្លបនៅពេលណា?" ចម្លើយរបស់លោក "ខ្ញុំឈប់ធ្វើឈ្លបនៅឆ្នាំ១៩៧៧ ពីព្រោះថាខ្ញុំមិនបានស្តាប់បញ្ជាដែលគេបញ្ជាឲ្យសម្លាប់មនុស្សនោះ" សូមបញ្ចប់ការដកស្រង់។ សំណួរទី១របស់ខ្ញុំៗ សួរលោកថាតើ លោកឈប់ធ្វើឈ្លបនៅឆ្នាំ១៩៧៧ មែន ឬក៏យ៉ាងណា?

[១៥:៥៣:១៥]

**ឆ៖** បាទ គឺឈប់ឆ្នាំ ឈប់ពីឆ្នាំហ្នឹង។

**ស៖** បាទ ឥឡូវប្រហែលត្រឡប់មកនិយាយអំពីអ្វីដែលលោកបានឆ្លើយពីមុនមក លោកៗបាននិយាយថា លោកធ្វើការនៅទំនប់នោះ មុនពេលធ្វើឈ្លប។ អ៊ីចឹងក្នុងករណីនេះ គឺថាលោកបានធ្វើការមុនឆ្នាំ១៩៧៦ ដែលជាកាលបរិច្ឆេទដែលគេតែងតាំងឲ្យលោកធ្វើឈ្លប។ អ៊ីចឹងមុនឆ្នាំ១៩៧៧ លោកឈប់ធ្វើជាឈ្លប?

**ឆ៖** បាទ ខ្ញុំឈប់ហើយបាទ ឈប់ធ្វើឈ្លបហើយ គេដកខ្ញុំឲ្យទៅកាប់ឈើធ្វើផ្ទះរបប។

**ស៖** លោកបាននិយាយថា គេឲ្យលោកទៅកាប់ឈើដើម្បីធ្វើផ្ទះរបប ប៉ុន្តែនៅទំព័រដដែលនៃកំណត់ហេតុស្តាប់ចម្លើយលោកនេះដែលខ្ញុំទើបនឹងដកស្រង់អម្បាញ់មិញនេះ លោកនិយាយថាលោកបានន័មិនស្តាប់បញ្ជា ហើយលោករត់ចូលព្រៃ។ អ៊ីចឹងសំណួរខ្ញុំចង់ដឹងថា ដោយសារលោកនិយាយថា លោកមិនបានព្រមធ្វើជាឈ្លប មិនព្រមស្តាប់បញ្ជាគេនោះ គេនឹងសម្លាប់លោក លោកឆ្លើយក្នុងសវនាការនេះអំមិញ។ ហើយក្នុងកំណត់ហេតុស្តាប់ចម្លើយលោកលោកថា លោមិនបានស្តាប់បញ្ជាគេ ហើយលោករត់ចូលព្រៃ។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើក្រោយពីពេលរត់ហើយហ្នឹងមានគេគំរាមសម្លាប់លោកទេ?

**ឆ៖** បាទ គេគំរាមខ្ញុំ គេរកសម្លាប់ខ្ញុំ បានខ្ញុំរត់ចូលព្រៃ បើនៅវាស្លាប់ ម្ល៉ោះហើយចេះតែរត់ទៅ

ស្លាប់ក៏ដោយ រស់ក៏ដោយ ស្លាប់ទៅដល់ណាបើវាត្រូវស្លាប់ ក៏ស្លាប់ទៅ គេចបាទ។ អ៊ីចឹងមែនបាទ។

**ស៖** តើលោកនៅក្នុងព្រៃហ្នឹងរហូតដល់ចប់របបហ្នឹងតែម្តង ឬក៏យ៉ាងណា?

**ឆ៖** បាទ នៅទាល់តែចប់។

[១៥:៥៦:៣០]

**ស៖** តើជាការត្រឹមត្រូវដែរឬទេក្នុងការនិយាយថា ដោយសារតែលោកភ័យអំពីការមិនស្តាប់បង្គាប់បញ្ជានេះហើយ ដែលលោកមិនប៊ានត្រឡប់មកចូលក្នុងភូមិវិញនោះ។ តើនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** បើអ៊ីចឹង បើខ្ញុំយល់មិនច្រឡំទេ គឺចាប់ពីឆ្នាំ១៩៧៧ រហូតដល់ឆ្នាំ១៩៧៩នោះ លោកមិនបានត្រឡប់ចូលភូមិវិញទេ គឺលោកចូលព្រៃរហូតដល់ឆ្នាំ១៩៧៩ តែម្តង។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវៗ។

**ស៖** បើអ៊ីចឹង បើខ្ញុំយល់មិនច្រឡំទេ គឺថាលោកមិនត្រឡប់ទៅធ្វើការនៅទំនប់១មករាទេពីព្រោះថាលោកមិនបានចូលភូមិវិញផងនោះ។ អ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ គឺមិនត្រឹមត្រូវទេបាទ។

**ស៖** អ៊ីចឹងបានន័យថា ក្រោយពីរត់ចូលព្រៃហើយហ្នឹង លោកត្រឡប់ចូលភូមិលោកវិញ ឬក៏យ៉ាងណា?

**ឆ៖** បាទ គឺក្រោយពីមក គេហៅមកចូលផ្ទះវិញ គេទៅហៅ ខ្ញុំមិនចង់ប៊ានមកដែរ ភ័យខ្លាចគេល្បួងមកសម្លាប់ហ្នឹងហើយ ខ្ញុំអត់ចង់ប៊ានមកដែរ ទាល់តែម៉ែឪហ្នឹងទៅយក សឹងតែមកប៊ានមកទៀត ក្រាញមិនចង់ប៊ាន ព្រោះកាលគេសម្លាប់ មិនមែនម៉ែឪទទួលខុសត្រូវបានទេ គឺត្រូវគេសម្លាប់អត់មានទទួលខុសត្រូវបាន នេះហើយខ្លាច ទាល់តែម៉ែឪទាំងអស់ទៅបងប្អូន ទៅទទួលយកមក បានប៊ានមកបាន។

**ស៖** ហើយកាលបងប្អូន ម៉ែឪ ទៅតាមលោកនៅក្នុងព្រៃហ្នឹងនៅឆ្នាំណាដែរ?

**ឆ៖** ខ្ញុំភ្លេច ដូចឆ្នាំ១៩៧៨ ភ្លេចហើយបាទ សូមទោស។

[១៥:៥៩:៣៨]

**ស៖** ដោយមិនចាំកាលបរិច្ឆេទច្បាស់លាស់នោះ តើលោកនៅចាំថា លោកនៅក្នុងព្រៃហ្នឹងរយៈ

ពេលប៉ុន្មានដែរ?

**ឆ៖** បាទ ខ្ញុំក៏មិនចាំ ក៏នៅទាល់តែដួលរលំ ប្រល័យពូជសាសន៍ដួលរំលំបានអស់លោក នែ៎ លោក ហេង សំរិន, លោក ជា ស៊ីម, លោក ហ៊ុន សែន ហ្នឹងចូលមក បានខ្ញុំចូលមក។ បានអស់លោករៀបច្បាប់មកទៅ បានខ្ញុំហ៊ានមក។ មិនទាន់រៀបចំបានទេ គឺមក ក៏ខ្ញុំចូលមក ក៏គេចាប់ទៅដាក់គុកទៅទៀត បាទ។ ពេលនោះឯង ចេះតែ--។

**ស៖** ខ្ញុំសូមការបំភ្លឺមួយមុនពេលសម្រាក។ តើលោកត្រឡប់ទៅចូលទៅភូមិលោកវិញតាមលួងលោមរបស់ឪពុកម្ដាយលោក បងប្អូនលោក ក្រោយពីលោកបានរត់ចូលទៅព្រៃ នៅក្នុងឆ្នាំ១៩៧៧។ ឪពុកម្ដាយលោកទៅលួងលោម លោកត្រឡប់មកភូមិវិញ។ តើអ៊ីចឹង ឬមិនអ៊ីចឹងទេ?

**ឆ៖** បាទ អ៊ីចឹងមែន បាទ។

**ស៖** ខ្ញុំនិយាយអំមិញ លោកថាត្រឹមត្រូវ ប៉ុន្តែចម្លើយរបស់លោកអម្បាញ់មិញនេះ វាមានភាពចម្រូងចម្រាស់ ព្រោះថាលោកនិយាយថា ស្ថិតនៅក្នុងព្រៃរហូតដល់ចប់របបខ្មែរក្រហមតែម្ដង។ អ៊ីចឹងខ្ញុំចង់សួរលោកថាតើចម្លើយមួយណាត្រឹមត្រូវ បើម្ដងលោកថា ទាល់តែចប់របបខ្មែរក្រហមបានចូលស្រុក ចូលភូមិវិញ ហើយមុនហ្នឹងលោកថា តែម៉ែឪលោកទៅហៅយកមកវិញ លោកចូលភូមិវិញ។ តើចម្លើយណាត្រឹមត្រូវ?

**ឆ៖** បាទ គឺក្នុងហ្នឹង គឺខ្ញុំវង្វេងហើយ មិនចំណាំទេ សូមទោស។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកសាក្សី ខ្ញុំក៏វង្វេងដែរលោកសាក្សី។

លោកប្រធាន ខ្ញុំសូមបញ្ចប់ការសួរនៅពេលនេះតែម្ដង លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អស់សំណួរនៅ?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន តាមពិតអម្បាញ់មិញនេះ ខ្ញុំចង់និយាយសំដៅសម្រាប់ថ្ងៃហ្នឹងទេ លោកប្រធាន ពីព្រោះអីឃើញថាម៉ោងបួនទៅហើយ។ ហ្នឹងហើយ ប្រហែលស្អែកនៅបន្តទៀត លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ទំនងចំណាយពេលប្រហែលប៉ុន្មានទៅ?

[១៦:០៣:០១]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំត្រូវការរយៈពេលប្រហែលជា៣០នាទីទៀត លោកប្រធាន។ ហើយសហភាតារបស់ខ្ញុំ លោក គង់ សំអុន ក៏គាត់មានសំណួរសួរដែរ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទ មុននឹងសម្រាក អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគី និងសាធារណជន ឲ្យជ្រាប ថា ដោយសារតែបញ្ហាទាក់ទងនឹងការធ្វើដំណើរ អង្គជំនុំជម្រះមិនអាចស្តាប់សក្ខីកម្មសាក្សី ដែលមាន រហស្សនាម 2-TCW-901 នៅស្អែក តាមដែលអង្គជំនុំជម្រះបានជូនដំណឹងដល់ភាគី កាលពីព្រឹកមិញ នោះបានទេ អង្គជំនុំជម្រះបានទទួលព័ត៌មានពីអង្គភាពគាំពារសាក្សីនិងអ្នកជំនាញថា សាក្សី 2-TCW-901 នឹងអាចមកផ្តល់សក្ខីកម្មបាន ហើយចាប់ពីថ្ងៃច័ន្ទ ទី២២ ខែមិថុនា ឆ្នាំ២០១៥ តទៅ។ ហេតុដូច្នេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សី 2-TCW-901 នៅសប្តាហ៍ក្រោយ បន្ទាប់ពីបញ្ចប់ការស្តាប់សក្ខី-កម្មសាក្សីដែលមានរហស្សនាម 2-TCW-943 ហើយលំដាប់លំដោយនៃការស្តាប់សក្ខីកម្មសាក្សីផ្សេង ទៀត គឺនៅរក្សាដដែល។ ដូច្នេះ សូមភាគី និងសាធារណជនជ្រាបជាព័ត៌មាន។

[១៦:០៤:២៥]

សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសកិច្ចដំណើរការសវ-នាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកនៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី១៧ ខែមិថុនា ឆ្នាំ ២០១៥ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការ បន្តស្តាប់សក្ខីកម្មសាក្សី យាន លន់ ទាក់ទងនឹងអង្គហេតុការដ្ឋានទំនប់១មករា បញ្ចប់ និងផ្តើមស្តាប់ សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCW-261 និងអាចផ្តើមស្តាប់សក្ខីកម្មដែល មានរហស្សនាម 2TCW-943 សម្រាប់អង្គហេតុការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាដែលបានកំណត់នេះ។ អង្គជំនុំជម្រះអរគុណដល់លោក យាន លន់ ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោក ក្នុងឋានៈជាសាក្សី នៅមិនទាន់បានចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោង ប្រាំបួន ហើយថ្ងៃស្អែកនេះ -- ឥឡូវនេះ លោកអាចសម្រាកបានហើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សីនិង អ្នកជំនាញជូនលោក យាន លន់ វិលទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញចុះ និងសូមឱ្យអញ្ជើញគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។ ហើយអរគុណលោក មឿន សុវណ្ណ មេធាវីប្រឹក្សាសាក្សី អង្គជំនុំជម្រះអញ្ជើញលោកមកបន្តចូលរួមប្រឹក្សាសាក្សី យាន លន់ នៅព្រឹកថ្ងៃស្អែកទៀតដែលចាប់ផ្តើមពីម៉ោងប្រាំបួន។

ហើយអង្គជំនុំជម្រះបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឱ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការនៅថ្ងៃស្អែកឱ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៦ នាទី)*